# ការសម្ភាសរបស់អ៊ុំស្រី ឌី ធី

**កៈ អ្នកសម្ភាសឈ្មោះជាង ស៊ីអ៊ាវ** **ខៈ អ្នកទទួលការសម្ភាសឈ្មោះឌីធី**

## ការសង្ខេបប្រវត្តិរបស់អ៊ុំស្រី ឌី ធី

ស្រីឌីធីមានអាយុឆ្នាំ៦៥នៅក្នុងឆ្នាំ២០២០ ភេទស្រី មានទីលំនៅបច្ចុប្បន្ននៅភូមិរកា ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំពិភាក្សាជាមួយអ៊ុំទាក់ទងពីប្រវត្តិរបស់អ៊ុំ ហើយការសម្ភាសទាំងអស់ហ្នឹងត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយបានស្គាល់ហ្នឹងបានដឹងជាពិសេសប្រវត្តិរបស់អ៊ុំដែរខ្ញុំបានសម្ភាសអ៊ុំហ្នឹងទុកអោយកូនចៅរបស់អ៊ុំបានដឹងបានស្គាល់ពីប្រវត្តិរបស់អ៊ុំដែរ អ៊ុំបានរៀបរាប់ប្រាប់ចឹងហាសអ៊ុំ?

ខៈ ចាំ!

កៈ បាទចឹងអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសម្ភាសមួយហ្នឹងទៅក្នុងវេបសាយសាលាទេអ៊ុំ?

ខៈ ចាំយល់ព្រមតើហ្នឹងក្មួយបាន។

កៈ អ៊ូបាទអ៊ុំ!

ខៈ តស្ងួហ្នឹងមិនទាន់ហ៊ានដាំបាយដាំទឹកផងចៅឃ្លានប៉ុណ្ណាក៏នៅសិនទៅ។

កៈ បាទអ៊ុំបាទចឹងសំរាប់ខ្ញុំជាអ្នកសម្ភាសអ៊ុំខ្ញុំមានឈ្មោះថាជាង ស៊ីអ៊ាវ?

ខៈ ចាំ!

កះ ហើយថ្ងៃខែដែរខ្ញុំសម្ភាសអ៊ុំគឺនៅថ្ងៃទី២៧ខែ៧ឆ្នាំ២០២០ ហើយការសម្ភាសទាំងអស់ហ្នឹងគឺធ្វើឡើងនៅភូមិទូលរកា ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាមចឹងសំរាប់អ៊ុំឈ្មោះពេញរបស់អ៊ុំទាំងត្រកូលម៉ងឈ្មោះអីគេអ៊ុំ?

ខះ ខ្ញុំឈ្មោះឌីធី។

កះ ឈ្មោះឌីធីហោស?

ខះ ចាំឌីធី។

កះ ចុះមានឈ្មោះហៅក្រៅអត់អ៊ុំ?

ខះ អត់មានទេក្មួយ។

កះ អូ៎!

ខះ ឈ្មោះតែម៉ែឪដាក់មកម៉េចចឹងតែម៉ងហើយ!

កះ អូ៎ចុះកាលពីក្មេងធ្លាប់មានឪពុកម្តាយអីហៅអ៊ុំអីលេងផ្សេងពីហ្នឹងអត់?

ខះ ធម្មតាមាន..។

កះ លក្ខណៈហៅឈ្មោះលេងហាស?

ខះ មានឪពុកខ្ញុំគាត់ហៅហាសគាត់ហៅមីធាៗអូ៎មែនមីធាទេអាវ៉ាត់។

កះ អូ៎!

ខះ គាត់ហៅតែអាវ៉ាត់។

កះ បាទអ៊ុំបាទ!

ខះ តាណុងហៅអាវ៉ាត់។

កះ ចុះ..?

ខះ អើយគ្មាននរណាតែអាវ៉ាត់តែអាធីៗហ្នឹង!

កៈ អ៊ុំបាទអ៊ុំបាទ!

ខៈ ចា៎!

កៈ ចុះអ៊ុំសព្វថ្ងៃអ៊ុំអាយុប៉ុន្មានទៅអ៊ុំ?

ខៈ ខ្ញុំហុកប្រាំហើយអូន។

កៈ អ៊ុំហុកប្រាំហើយអ៊ុំហោស?

ខៈ ចា៎!

កៈ ចុះអ៊ុំកើតនៅថ្ងៃខែឆ្នាំណាអ៊ុំចាំអត់អ៊ុំ?

ខៈ ទេក្មួយសម្លាញ់ហើយដឹងតែអាយុយើងឆ្នាំរកាតែប៉ុណ្ណឹង!

កៈ អ៊ុំ!

ខៈ ចា៎!

កៈ អ៊ុំហុកសិបប្រាំឆ្នាំណោះអ៊ុំណោះ?

ខៈ ចា៎!

កៈ ចឹងមើលហុកហាមួយអ៊ុំកើតនៅឆ្នាំមួយពាន់ប្រាំបួនរយហាប្រាំមួយ?

ខៈ ចា៎!

កៈ ចុះអ៊ុំឆ្នាំច័ន្ទគតិជូត ឆ្លូវ ខាល ថោះអ៊ុំឆ្នាំអីគេអ៊ុំ?

ខៈ ឆ្នាំរកា។

កៈ ឆ្នាំរកាណោះអ៊ុំណោះ?

ខៈ ចា៎!

កៈ ចុះអើអ៊ុំស្រុកកំណើតដែរអ៊ុំកើតម៉ងអ៊ុំកើតនៅណាអ៊ុំ?

ខ៖ ខ្ញុំនៅកោះហោសក្មួយ។

ក៖ អ៊ូនៅកោះហោសអ៊ុំហោស?

ខ៖ ចាំកោះជ្រូក។

ក៖ អ៊ូហ្នឹងនៅណាវិញអ៊ុំ?

ខ៖ ខ្ញុំនៅកោះជ្រូក ឃុំកោះសំរោង។

ក៖ នៅណោះហោស?

ខ៖ ចាំនៅកោះយើងឆ្លងទន្លេចឹងទៅកោះណុងហើយ!

ក៖ អ៊ូ!

ខ៖ ហ្នឹងយើងនៅត្រើយម្ខាងម្នាក់។

ក៖ តែអ៊ុំនៅភូមិណុងម៉ងហោស?

ខ៖ ចាំខ្ញុំនៅភូមិកោះជ្រូក។

ក៖ បាទអ៊ុំបាទ!

ខ៖ ភូមិទីប្រាំមួយ។

ក៖ បាទអ៊ុំចុះអ៊ុំអើដូចជាអ៊ុំមានបងប្អូនបង្កើតចំនួនប៉ុន្មាននាក់ទៅអ៊ុំ?

ខ៖ ខ្ញុំមានប្រាំមួយនាក់។

ក៖ ចុះស្រីប៉ុន្មានប្រុសប៉ុន្មានអ៊ុំ?

ខ៖ ប្រុសប្រាំស្រីមួយ។

ក៖ ស្រីតែអ៊ុំមួយទេ?

ខ៖ ប្រុសហ្នឹងប្រុសមួយស្រីប្រាំ។

ក៖ អ៊ំប្រុសមួយស្រីប្រាំណោះ?

ខ៖ ចាំ!

ក៖ ចុះអើអ៊ុំកូនទីប៉ុន្មាន?

ខ៖ ខ្ញុំកូនទីពីរ។

ក៖ បន្ទាប់បងហោស?

ខ៖ ចាំ!

ក៖ ចុះអើបងរបស់អ៊ុំគាត់ប៉ុន្តែបងប្អូនរបស់អ៊ុំគាតនៅរស់ទាំងអស់គ្នាតើហើតឡូវ?

ខ៖ ចាំអាលែងងាប់អាប្រុសហើយ!

ក៖ ងាប់អ៊ំស្លាប់ប្រុសហោស?

ខ៖ ងាប់ចាំ!

ក៖ ប្រុសទីប៉ុន្មានអ៊ុំ?

ខ៖ អាប្រុសណុងទីបួន។

ក៖ កើតអីបានគាត់ស្លាប់?

ខ៖ អ៊ំនិយាយទីក្មួយអើយក្នុងសង្គមណុងណាប្អូនខ្ញុំវាដូចថាវានៅជាមួយមេមួយជំនាន់នេះណុង មេគេអោយកាន់កាប់ដីមើលកាងដីគេទៅនៅស្រុកលើណុងហាស!

ក៖ បាទអ៊ុំ!

ខ៖ អើគេអោយកាងដីគេណុងយើងចេះតែកាងអោយគេព្រោះយើងស៊ីប្រាក់ខែគេហោស!

ក៖ បាទអ៊ុំបាទ!

ខ៖ រួចបែបគេខឹងថាយើងហ្នឹងកាងយកលោភលន់ដីធ្លីគេគេលួចបាញ់ប្អូនខ្ញុំងាប់ទៅហើយ!

កៈ អូ៎!

ខៈ ចាំ!

កៈ ពេលណុងប៉ុន្មានឆ្នាំហើយអ៊ុំយូរនៅ?

ខៈ ទេមិនបានជាគិតឆ្នាំទេក្មួយដូចជាប្អូនប្រាំឆ្នាំហើយប្អូនប្រាំឆ្នាំមុនហ្នឹងហើយនិយាយល្បីស្រុកលើដីគេកាងៗដីណុងដូចមានអ្នកធំៗណុងគេបើកយកដីប្រជាជណុងហាសចាំ!

កៈ អូ៎ចឹងទើបតែឥឡូវៗថ្មីៗហ្នឹងទេណោះអ៊ុំណោះ?

ខៈ ចាំទើបប្រហែលប្រាំឆ្នាំប្រាំមួយឆ្នាំទៅចុះក្មួយខ្ញុំវាមិនបានជាគិតវិលវល់អស់ហើយហ្នឹងកូនឈឺពិការហ្នឹងហាស!

កៈ បាទអ៊ុំបាទ!

ខៈ ចាំ!

កៈ ចុះអ៊ុំគិតថាអ៊ុំអាចប្រាប់ឈ្មោះបងៗរឺមួយក៏ប្អូនៗបានទេអ៊ុំ?

ខៈ បាន..។

កៈ ថាពួកគាត់ឈ្មោះអីគេខ្លះទៅអ៊ុំ?

ខៈ បងទីមួយឈ្មោះឪណៃហ៊ី។

កៈ ចុះគាត់ធ្វើអីគេទៅអ៊ុំ?

ខៈ អើគ្នាមេម៉ាយឥឡូវហោសឥឡូវមកនៅវត្តមកនៅវត្តឬស្សីពុកនៅអីជិតភ្នំពេញហ្នឹងដែរ។

កៈ អូ៎!

ខៈ វត្តពុកឬស្សីចឹងហើយវត្តណុងហោស!

កៈ វត្តពុកឬស្សី?

ខៈ វត្តពុកឬស្សី។

កៈ នៅខេត្តកណ្ដាលអ៊ុំ?

ខៈ ចាំ!

កៈ ចុះអើប៉ុន្តែគាត់មានគ្រួសារគាត់តើណោះអ៊ុំណោះ?

ខៈ គ្រួសារងាប់ហើយ!

កៈ កូនចៅអត់មានទេហោសអ៊ុំ?

ខៈ កូនចៅមានបីនាក់។

កៈ អូ៎ប៉ុន្តែអើ..?

ខៈ ចាំតែជីវភាពគ្នាពិបាកដែរហោសម្ដាយក៏លះបង់ចិត្តហ្នឹងទៅនៅអឺវត្តទៅដើម្បីបំរើព្រះសង្ឃអីចឹងទៅណាស់។

កៈ អូ៎បាទ!

ខៈ ចាំនៅវត្ត។

កៈ បួសធ្វើដូនជីអីទៅណោះអ៊ុំ?

ខៈ ចាំនៅវត្តណុង។

កៈ អូ៎បាទបន្ទាប់មកអ៊ុំ?

ខៈ បន្ទាប់មកខ្ញុំ។

កៈ ចុះកូនទីបី?

ខៈ កូនទីបីកូនទីពីរខ្ញុំកូនទីបីគេនៅអឺថ្មពេជ្រ។

កៈ នៅណាវិញ?

ខៈ ថ្មពេជ្រទៅយើងទៅពីបឹងព្រួលទៅហោសក្មួយ។

ក៖ នៅខេត្តកំពង់ចាមយើងតើហី?

ខ៖ ខាងណុងត្បូងឃ្មុំទេហី!

ក៖ អ៎ូត្បូងឃ្មុំហោស?

ខ៖ មែនកំពង់ចាមទេចា៎!

ក៖ អ៎ូ!

ខ៖ ត្បូងឃ្មុំកូន។

ក៖ អ៎ូបាទអ៊ុំបាទចុះអើគាត់ធ្វើអីគេនៅណុងអ៊ុំ?

ខ៖ អើយក្មួយទៅធ្វើតែស្រែចំការហ្នឹងយើងអ្នកស្រុកណុងគ្មានទៅធ្វើស្អីណាធំដុំធ្វើតែចឹង។

ក៖ អ៎ូបាទអ៊ុំបាទ!

ខ៖ ធ្វើស្រូវធ្វើចំការ។

ក៖ ចិញ្ចឹមកូនចៅទៅណោះអ៊ុំណោះ?

ខ៖ ចា៎!

ក៖ ចុះគាត់មានកូនប៉ុន្មាននាក់ទៅនៅណុងអ៊ុំ?

ខ៖ ហ៎េមួយណុងកូនប៉ុន្មានទេមួយណុងអើរាប់ពីរអាឆ្នាយៗពីរមើលអាមីដាអាពីរសារក្រោយបីប្រាំមីណាហ្នឹងកូនប្រាំនាក់។

ក៖ ហ្នឹងកូនទីបីណោះអ៊ុំ?

ខ៖ ចា៎កូនប្រាំនាក់។

ក៖ ទីបួនដែរពូដែរស្លាប់មែនអត់?

ខ៖ទីបួនអាស្លាប់ទៅហើយ!

ក៖ ប៉ុន្តែគាត់មានកូនចៅគាត់ដែរ?

ខ៖ មានកូននៅស្រុកលើណោះ។

ក៖ អូ៎!

ខ៖ ចាំនៅស្រុកលើណោះ។

ក៖ ចុះឥឡូវអើកូនចៅគាត់នៅជាមួយប្រពន្ធគាត់?

ខ៖ នៅជាមួយម្ដាយគាត់។

ក៖ នៅជាមួយម្ដាយ?

ខ៖ ចាំ!

ក៖ ម្ដាយធ្វើអីគេទៅអ៊ុំ?

ខ៖ ធ្វើស្រែចំការហ្នឹងក្មួយគ្មានធ្វើអីទេ។

ក៖ អូ៎ធ្វើស្រែចំការដែរហោស?

ខ៖ ចាំ!

ក៖ ចុះទីប្រាំអ៊ុំ?

ខ៖ ទីប្រាំស្រី។

ក៖ គាត់នៅណាទៅអ៊ុំ?

ខ៖ នៅរអាងណោះហ្នឹង!

ក៖ អូ៎គាត់ធ្វើអីគេទៅអ៊ុំ?

ខ៖ ចាំវានៅធ្វើចឹងដែរតើក្មួយមានធ្វើអីវាបានកូនគេចិញ្ចឹមឥឡូវហ្នឹងហាសកូនគេមានប្ដីនៅកូរ៉េ។

កៈ អូ៎ចឹងគាត់ធូរហើយណោះ?

ខៈ ចា៎មានកូនគេចិញ្ចឹមហ្នឹងហើយ!

កៈ ប៉ុន្តែអើបងប្អូនប៉ុន្មានមិញប្រាំមួយនាក់?

ខៈ ប្រាំនាក់។

កៈ ប្រាំ?

ខៈ អូ៎ប្រាំមួយនាក់ទាំងអស់ងាប់ណោះ។

កៈ អូ៎ចុះពៅគេ?

ខៈ ពៅគេមីរអាងណុងហើយ!

កៈ អូ!

ខៈ អូ៎ភ្លេចមីថាមួយទៀតមីណារួចមីថាមីថានៅរអាងណុងដែរ។

កៈ អូ៎ទីប្រាំទីប្រាំមួយហ្នឹងហោសអ៊ុំ?

ខៈ ចា៎ទីប្រាំទីប្រាំមួយហ្នឹងមីថា។

កៈ អូ៎!

ខៈ ភ្លេចមីថា។

កៈ គាត់ធ្វើអីគេអ៊ុំ?

ខៈ ធ្វើស្រែចំការដែរ។

កៈ ធ្វើស្រែចំការដែរ?

ខៈ ដល់ពេលចាស់ទៅឥឡូវមើលតែចៅដូចអ៊ុំចឹងហាសចា៎!

កៈ អូ៎ពួកគាត់មានកូនចៅគ្រប់គ្នាហើយហោស?

ខ៖ ចាំមានកូនចៅគ្រប់គ្នាមើលតែចៅៗហ្នឹង!

ក៖ អូ៎បាទអ៊ុំបាទចុះអើទីបីទីបួនមិញគាត់ឈ្មោះអីគេអ៊ុំ?

ខ៖ ទីបីឈ្មោះទីពីរខ្ញុំឌីធី ទីបីឌីណា ទីបួនឌីស៊ីថា ទីប្រាំឌីសៀងរីងាប់ហើយ!

ក៖ អូ៎!

ខ ទីប្រាំមួយឌី៧។

ក៖ អូ៎!

ខ៖ ចាំ!

ក៖ បាទអ៊ុំបាទ!

ខ៖ ចាំប្រាំនាក់ដៃរណុងហាស!

ក៖ ចុះអ៊ុំដោយសារតែបងប្អូនច្រើនណោះ?

ខ៖ ចាំ!

ក៖ បាទអ៊ុំហើយវាយូរផង?

ខ៖ ចាំ!

ក៖ ចុះអ៊ុំគិតថាអ៊ុំធ្លាប់មានជាអនុស្សាវរីយ៍ដូចជាការចងចាំធ្វើការអីខ្លះជាមួយបងប្អូនចឹងកាលនៅតូចៗអត់អ៊ុំ?

ខ៖ កាលតូចៗក្មួយហោស?

ក៖ បាទគាត់ធ្លាប់ធ្វើអីគេខ្លះជាមួយអ៊ុំអីបងប្អូនអ៊ុំហាស?

ខ៖ អត់ទេបងប្អូនខ្ញុំតូចៗគ្មានអីទេណាខ្ញុំធ្លាប់ដឹងមកបងប្អូនល្អដៃរតើក្មួយអត់មានដៃរទៅឈ្លោះប្រកែកអីគ្នាទេ។

ក៖ អត់ទេលក្ខណ:ថា..?

ខ៖ អត់អើលក្ខណៈបងប្អូនដល់មកស្រុកអាលែងយើងឆ្នាំចិតសិបហ្នឹងស្រុកមានកើតសង្គ្រាមធ្វើរដ្ឋប្រហារអីហ្នឹងទៅក៏លែងបានរៀនលែងបានសូត្រទៅ។

ក៖ អូ៎!

ខ៖ ចាំគ្មានបានរៀនអីណា។

ក៖ បាទអ៊ុំ!

ខ៖ ខ្ញុំបានរៀនតែត្រឹមថ្នាក់ទីបីបើយើងឥឡូវថាទីបីណាបើនៅមួយជំនាន់អ៊ុំគេថាថ្នាក់អាលែងអាទិអាទិ។

ក៖ ថ្នាក់អាទិ?

ខ៖ អើថ្នាក់អាលែងទីមួយហៅថ្នាក់កុមារដ្ឋានទីពីរឥឡូវហ្នឹងគេហៅថ្នាក់បារិអ៊ុំបានរៀនត្រឹមថ្នាក់អាទិទេ។

ក៖ អូ៎បាទអ៊ុំ!

ខ៖ អើបានបីថ្នាក់ដែរ។

ក៖ ប៉ុន្តែអ៊ុំបានរៀនភាសាបារាំងអត់ចឹង?

ខ៖ ភាសាបារាំងជិតបានចូលហើយតើបានរៀនតិចៗហើយប៉ុនមិនទាន់បានចេះចាំអីទេណាស់។

ក៖ បាទអ៊ុំ!

ខ៖ ទទួលស្រុកបាតុកម្មទៅ។

ក៖ លែងបានរៀនទៅ?

ខ៖ លែងបានរៀនទៅក្មួយ។

ក៖ អូ៎បាទអ៊ុំបាទចុះអ៊ុំគិតថាចឹងដូចជាបងប្អូនរបស់អ៊ុំសព្វថ្ងៃគាត់នៅបែកគ្នាទាំងអស់ណោះអ៊ុំណោះ?

ខ៖ បែកគ្នាទាំងអស់តើក្មួយ។

ក៖ អ៎ូបាទអ៊ុំចុះឪពុករបស់អ៊ុំឈ្មោះអីគេអ៊ុំ?

ខ៖ ឪពុកខ្ញុំឈ្មោះដុកតាខ្ញុំឈ្មោះតាដុកចឹងហាសដុកឌី។

ក៖ ដុកឌី?

ខ៖ ចា៎!

ក៖ អ៎ូចុះម្ដាយឈ្មោះអីគេអ៊ុំ?

ខ៖ ម្ដាយខ្ញុំឈ្មោះម៉ៅលាន់។

ក៖ ម៉ៅលាន់?

ខ៖ ចា៎!

ក៖ អ៎ូបាទអ៊ុំចុះឪពុកម្ដាយរបស់អ៊ុំគាត់ដូចជាគាត់អ្នកស្រុកនៅណាអ៊ុំស្រុកនៅហ្នឹងមែន?

ខ៖ អើម៉ែខ្ញុំស្រុកនៅកោះកោះជ្រូកយើងហ្នឹងហាស!

ក៖ បាទអ៊ុំបាទ!

ខ៖ ឃុំកោះសំរោងឪពុកខ្ញុំអ្នកស្រែគ្រានគាត់កូនកំព្រាចា៎!

ក៖ អ៎ូ!

ខ៖ អើជីដូនជីតាខ្ញុំគាត់ខូចចោលគាត់តាំងពីតូចៗម៉េស។

ក៖ បាទអ៊ុំបាទ!

ខ៖ ចា៎!

ក៖ អើ..!

ខ៖ គាត់រស់នៅជាមួយឪពុកមាគាត់។

កៈ បាទអ៊ុំ!

ខៈ ដល់គាត់ធំពេញវ័យអើគាត់ជីតាណុងជីតាមាណុងអោយរៀនអោយសូត្របានចេះបានដឹងដោះស្រាយខ្លួនរួចទៅណាស់។

កៈ បាទអ៊ុំបាទ!

ខៈ រួចទៅតាំងគាត់ភ្ជាប់ដណ្ដឹងម៉ែខ្ញុំអោយទៅ។

កៈ អ៎ូបាទអ៊ុំ!

ខៈ ចាំ!

កៈ ចុះអើឪពុករបស់អ៊ុំកាលពីមុនកាលគាត់នៅរស់គាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតចិញ្ចឹមកូនចៅចិញ្ចឹមអ៊ុំចិញ្ចឹមក្រុមគ្រួសារ?

ខៈ គាត់ធ្វើចំការ។

កៈ អ៎ូ!

ខៈ គាត់ធ្វើចំការថ្នាំនៅស្រុកកោះហាសចំការថ្នាំ។

កៈ បាទអ៊ុំបាទ!

ខៈ ចាំ!

កៈ ប៉ុន្តែគាត់កាចអត់អ៊ុំ?

ខៈ ទេឪពុកខ្ញុំថាកាចក៏បានថាស្លូតក៏បានអើគាត់ល្អ។

កៈ បាទអ៊ុំបាទ!

ខៈ គាត់ដូចថាកូនចៅចឹងបើមានភ្ញៀវឡើងលេងអីចឹងគាត់គ្រាន់តែសំឡឹងតែមុខទេសំឡឹងតែមុខយើងត្រូវថយចេញទៅ បើមិនថយចេញអាហ្នឹងគាត់កត់ត្រាទុកក្នុងខ្លួនគាត់លើកទីមួយហាសណាស់ដល់លើកទីបីអាហ្នឹងបានគាត់វ៉ៃ។

ក៖ អូ៎!

ខ៖ ចា៎!

ក៖ ចឹងទៀតអ៊ុំ?

ខ៖ វ៉ែប៉ុនវ៉ែណុងគាត់ថាយកមកយកចង្កាក់ថ្នាំឡើងមកផងកូនអើយកមកគាត់អោយអង្គុយបត់ជើងយើងដឹងបត់ជើងដឹងពុកវ៉ែហើយ!

ក៖ អូ៎!

ខ៖ ដឹងខ្លួនតើថាយើងធ្វើខុសណាព្រោះយើងដឹងអីក្មេងគាត់ចាស់គាត់កត់សំគាល់ទុកហាសណាស់ ជូនណាគាត់កំពុងតែសំរានអីចឹងទៅយើងដើរលើតែជើងយើងក្តុងក្តាំងអាហ្នឹងគាត់កត់ទុកមួយហើយគាត់ភ្ញាក់គាត់ហោសអាហ្នឹងមួយហើយ ទោសយើងមានមួយហើយទាល់គ្រប់បីដងបានគាត់វ៉ៃម្តង។

ក៖ ចឹងទៀតហោសអ៊ុំ?

ខ៖ ចា៎អត់មានវ៉ៃកូនតាពីសតាពាស់ទេតា។

ក៖ លក្ខណៈថាគាត់គុមយើងទៀត?

ខ៖ គុមយើង។

ក៖ កត់ត្រាយើង?

ខ៖ កត់ត្រាទុក។

ក៖ ចំឡួយហាសណោះអ៊ុំ?

ខ៖ ចា៎អត់មានថាខឹងភ្លាមវ៉ៃភ្លាមទេកត់ទុក។

ក៖ រួចគាត់អត់មានប្រាប់កំហុសយើងថាយើងខុសអី?

ខ៖ ប្រាប់ថាលើកទីមួយចេះមានភ្ញៀវឡើងមកលេងអញ់សំឡឹងមើលមុខអត់ខ្មៀតទេណាស់ អើសំឡឹងមើលមុខអត់ខ្មៀតទេចង់ដឹងណាស់រឿងមនុស្សចាស់ដែរនិយាយគ្នាអត់មានត្រូវការចឹងៗអីទេណាស់ អើកត់ទុកអោយយើងដឹងហាសណាស់។

ក៖ បាទ!

ខ៖ លើកទីពីរទីពីរយើងធ្វើខុសអីមួយដូចថាគាត់កំពុងតែសំរានចឹងហាសរួចយើងឡើងមកលើផ្ទះដើរវៀងលីអីចឹងហាសហ្នឹងគាត់វៀងភ្ញាក់ហាសអាហ្នឹងពីរហើយ អើទីបីដូចថាធ្វើដូចថាយើងទៅណាមកណាអីចឹង..។

ក៖ អត់ប្រាប់គាត់អីចឹងទៅ?

ខ៖ អត់ប្រាប់គាត់អីចឹងទៅហ្នឹងហើយទីបីអើទីបីចឹងទៅគាត់ប្រាប់យើងហើយអើយអាវ៉ាត់ហាស ចាំអើយកចង្កាក់ថ្នាំពីរបីមកអើយើងស្រុកយើងស្រុកចំការធ្វើថ្នាំ។

ក៖ បាទៗអ៊ុំ!

ខ៖ ដោតហាលនៅក្រោមផ្ទះណុងហោស!

ក៖ បាទអ៊ុំ!

ខ៖ កាន់មកពីរអើដឹងតែពុកវ៉ៃហើយបត់ជើងហោសប៉ុនមុនហ្នឹងគាត់វ៉ៃកូនគាត់អោយកូនស៊ីបាយឆ្អែតៗហោសមានចេះវ៉ៃតាពីសតាពាស់ទេ។

ក៖ ចឹងទៀតអ៊ុំ?

ខ៖ ចាំស៊ីបាយឆ្អែតហើយមានហ៉យមានរឿងធ្វើហើយ!

ក៖ អូយស្រួលហាសណោះ?

ខ៖ ចាំវ៉ៃរួចសួរវៀងនៅហាសវ៉ៃហ្នឹងរឿងនៅវៀងតិចថាវៀងប៉ុន្មានឆ្នាំវៀងប៉ុន្មានថ្ងៃទេអត់ព្រមយកទេរឹតតែវ៉ៃមិនដឹងឆ្លើយថាម៉េចទេ បានម៉ែប្រាប់ថាប្រាប់ទៅវៀងមួយជាតិកូនវៀងមួយជាតិមួយជាតិទាល់តែងាប់ហ្នឹងហាសមួយជាតិពុកអើយកូនវៀងមួយជាតិណាស់ពុក ណុងបាន

ឈប់វ៉ៃឆ្លើយថារៀងតាពីសតាពាស់មួយឆ្នាំពីរឆ្នាំអត់រឹតតែវ៉ៃហ្នឹងក្បាលខូចហាសហែងខូចហាសចេះចុះអីហ្នឹងហាស!

ក៖ អូ៎បាទអ៊ឹបាទ!

ខ៖ អើទាល់តែឆ្លើយថារៀងមួយជាតិ។

ក៖ បានឈប់វ៉ៃ?

ខ៖ បានឈប់វ៉ៃមួយជាតិហ្នឹងមួយជាតិចាំណាស់តិចថាមួយជាតិហ្នឹងអោយភ្លេចអាហ្នឹងលើសដើមហើយ!

ក៖ វ៉ៃទៀត?

ខ៖ វ៉ៃទៀត។

ក៖ អូ៎!

ខ៖ មិនដូចសម័យឥឡូវនោះទេសម័យឥឡូវតាពីសតាពាស់ខឹង..។

ក៖ វ៉ៃ?

ខ៖ កំពោលអីទេឪពុកខ្ញុំល្អហាស!

ក៖ បាទអ៊ឹបាទរួចចុះម្ដាយវិញអ៊ឹម្ដាយធ្វើអីគេសំរាប់ចិញ្ចឹមជីវិតកូនចៅអ៊ឹ?

ខ៖ ម្ដាយខ្ញុំគិតទៅម៉ែខ្ញុំយ៉ាប់ហាសនោះរូបថតម៉ែខ្ញុំហោសម៉ែខ្ញុំយ៉ាប់ហាសអូនអើយ ម៉ែខ្ញុំការងារប្រុសក៏ធ្វើការងារស្រីក៏ធ្វើគាត់ជំនាញតែម៉ងឪពុកខ្ញុំទេរៀងស្រួលហោស!

ក៖ អូ៎បាទអ៊ឹ!

ខ៖ ឪពុកខ្ញុំនៅក្រុងកូនមើលខុសត្រូវកូនម៉ែខ្ញុំនឿយ។

ក៖ អូ៎គាត់ធ្វើការហាត់ហោស?

ខ៖ ចាំនឿយណាស់គាត់រពិសដៃហាសគាត់ចេះតែធ្វើទៅខែដាំថ្នាំចឹងទៅកូនថ្នាំគាត់ហ្នឹងដកលក់អោយគេហ្នឹងមិនគ្រប់មិនគ្រាន់គាត់ដូចថាម៉ូយមានដូចថាគាត់ដើរទៅទិញកូនថ្នាំនៅស្រុកណាៗដាក់កាណ្ឌូតទៅតាមគេទាំងកញ្ជេៗមក យកមកលក់អោយគេអីចឹងទៅគាត់រកស៊ីម៉ែខ្ញុំហាស!

ក៖ បាទអ៊ុំ!

ខ៖ ចាំចឹងចាំ!

ក៖ បាទអ៊ុំបាទ!

ខ៖ រួចបុកអង្ករមួយជំនាន់ណុងកិនស្រូវបុកតែអង្ករកូនខ្ញុំអត់ចេះណាក្មួយម៉ែខ្ញុំអត់អោយធ្វើទេកំពប់កូនកំពប់អ៊ុំអត់ចេះរែងអីទេ អត់ចេះទេម៉ែមិនអោយធ្វើ។

ក៖ គាត់..?

ខ៖ គាត់ខ្លាចកំពប់ប៉ុនម៉ែខ្ញុំបុកកិនបុកអើយខ្ទីសៗម៉ែខ្ញុំល្អណាស់ធ្វើ។

ក៖ ប៉ុនគាត់អ្នករ៉ាប់រងទាំងអស់?

ខ៖ គាត់អ្នករ៉ាប់រងទាំងអស់ល្អហាសម៉ែខ្ញុំ។

ក៖ បាទអ៊ុំ!

ខ៖ ខ្ញុំទើបមានប្ដីទេនេះមកនៅប្ដីទេប្ដីគេបង្រៀនហោសចេះអ៊ុំចេះស្ដីហាសនៅជាមួយម៉ែខ្ញុំខ្ញុំអត់ចេះទេ។

ក៖ គាត់អត់ដែរបង្រៀនទេណោះអ៊ុំ?

ខ៖ ម៉ែខ្ញុំមិនអោយធ្វើទេ។

ក៖ អូ៎!

ខ៖ កូនហោសគ្រាន់ប្រាប់។

ក៖ រួចចុះគាត់កាចអត់អ៊ុំ?

ខ៖ ម៉ែអត់ទេម៉ែមិនដែរចេះរ៉ៃកូនទេបើខឹងគាត់ជេរតែម៉ង។

ក៖ គ្រាន់តែជេរទេណេះអ៊ុំ?

ខ៖ មីចោលគេបាញ់មីចោលស្អីហែងចង្រៃហាសចេះៗចឹងទៅគាត់អត់ដែររ៉ៃកូនទេយាយហ្នឹងចេះជេរ។

ក៖ អូ៎ប៉ុន្តែបើឪពុកឪពុករ៉ៃ?

ខ៖ ឪពុករ៉ៃ។

ក៖ ប៉ុន្តែរ៉ៃទាល់តែគាត់មានកំណត់ដែរ?

ខ៖ មានកំណត់គាត់ដែរគាត់មិនចេះរ៉ៃយើងតាពីសតាពាសទេ។

ក៖ អូ៎!

ខ៖ ឪពុកខ្ញុំហោស!

ក៖ បាទអ៊ុំបាទល្អ!

ខ៖ ចា៎!

ក៖ ចុះអ៊ុំគិតថាអ៊ុំធ្លាប់មានអនុស្សាវរីយ៍រឺមួយការចងចាំអ៊ុំធ្លាប់ធ្វើការងារអីគេខ្លះជាមួយឪពុកម្តាយអត់អ៊ុំកាលនៅតូចៗហាស?

ខ៖ ខ្ញុំហោសម៉ែខ្ញុំធ្វើចំការខ្ញុំទៅជួយខ្ញុំទៅជួយកាចខ្នែងថ្នាំខ្នែងអីគាត់ក្អួយខ្នែងថ្នាំហាសទាល់ៗត្រួយថ្នាំទាល់អីខ្នែងៗវាតាមធាងហោស!

ក៖ បាទអ៊ុំបាទ!

ខ៖ ក្អួយអើយខ្ញុំនិហាយៗខ្ញុំកាចត្រួយថ្នាំធំក្រពុលត្រួយថ្នាំអីណុងខ្ញុំដូចវាពិបាកក្នុងខ្លួនខ្ញុំ យូរៗទៅឪពុកខ្ញុំអោយទៅចំការទេហែងពិបាកហាសកូនកូនឯងកុំទៅចំការមើលទៅដូចអាយ៉ាំដូចថានឿយហ្នឹងធំក្លិនថ្នាំណុងហោស!

ក៖ បាទអ៊ុំបាទ!

ខ៖ អើកូនឯងនៅចាំបាយដាំទឹកអោយគេស៊ីទៅកូនមិនបាច់ទៅចំការទេអើខែថ្នាំខ្ញុំអត់បានទៅទេ។

ក៖ អូ៎!

ខ៖ តែបងៗទេគេទៅកាចថ្នាំកាចអីហ្នឹងខ្ញុំនៅចាំតែរៀបថ្នាំអីហ្នឹងសកថ្នាំអូនៅផ្ទះដាំបាយដាំទឹកហ្នឹង!

ក៖ ស្រួលហាសណោះអ៊ុំចឹង?

ខ៖ ព្រលឹមឡើងណុងខ្ញុំឡើងទៅកោះលួងហោសទៅទិញត្រីទិញអីគេយកមកធ្វើម្ហូប។

ក៖ អូ៎បាទអ៊ុំបាទ!

ខ៖ រួចពុកសរសើរអើយកូនចេះធ្វើស៊ីឆ្ងាញ់អីចឹងហាសណាស់។

ក៖ បាទអ៊ុំ!

ខ៖ តែនៅផ្ទះទេរួចខែលូក៏ខ្ញុំអត់ចេះច្រូតលូដៃរធំក្រពុលលូខ្លាចដង្កូវលូ ចឹងពុកខ្ញុំអត់អោយខ្ញុំធ្វើគាត់អោយខ្ញុំនៅការងារផ្ទះ។

ក៖ អូ៎!

ខ៖ អើខ្ញុំរៀបការងារផ្ទះ។

ក៖ ចឹងមានន័យថាអ៊ុំគឺអត់ធ្វើការងារដូចបងៗទេ?

ខ៖ អត់ហាត់ដូចបងៗបានទេខ្ញុំយ៉ាប់ម៉ងរឿងចឹងចង់ធ្វើដែរប៉ុនទាល់ត្រួយថ្នាំកាចខ្ទែងថ្នាំដូចគេកាចស្អីក្នុងព្រលឹងស្អីក្នុងខ្លួនយើងចឹងហាស!

ក៖ បាទអ៊ុំ!

ខ៖ រួចទៅធំជ័យថ្នាំហ្នឹងក្រពុលខ្ញុំអត់ចេះ។

ក៖ អូ៎ៗ

ខ៖ ចិត្តចង់ធ្វើដែរប៉ុនទៅមិនរួច។

ក៖ បាទអ៊ុំបាទ!

ខ៖ ទៅមិនរួចដល់ទង្វើយើងមិនរួចឪពុកខ្ញុំមើលឃើញគាត់អត់អោយទៅ។

ក៖ គាត់ឈប់អោយទៅទៅ?

ខ៖ ឈប់អោយទៅកូនឯងនៅតែផ្ទះទៅកូន។

ក៖ បាទអ៊ុំបាទ!

ខ៖ ដាំតែបាយទឹកអោយគេស៊ីទៅ។

ក៖ អ៊ូបាទអ៊ុំ!

ខ៖ ចាំ!

ក៖ ចុះអើឪពុកគាត់ធ្លាប់ប្រាប់ពីប្រវត្តិកាលគាត់នៅក្មេងទៅអ៊ុំអត់?

ខ៖ ប្រាប់គាត់ថា..។

ក៖ ពីមុន..?

ខ៖ ប្រាប់ថាហោសកូនកំព្រាកូនហាស..!

ក៖ បាទៗ!

ខ៖ កំព្រាប៉ុនកំព្រារបស់ឪពុកហ្នឹងហាសកំព្រាបងប្អូនស្រឡាញ់គ្នាណាស់ ហោសបងប្អូនពុកស្រឡាញ់គ្នាណាស់អត់ចេះដើរស្អប់បងប្អូនស្អីបងវ៉ៃអីបងប្អូនទេកូនឯងក៏ចឹងដែរត្រូវតែស្រឡាញ់បងប្អូនណាស់ អើបើកូនឯងចេះស្រឡាញ់បងប្អូនឪពុកសប្បាយចិត្តបើកូនឯងចេះឈ្លោះចេះប្រកែកគ្នាឪពុកពិបាកចិត្តណាស់កូន។

ក៖ បាទ!

ខ៖ រឿងធំៗហាសណាស់។

កៈ បាទអុឹ!

ខៈ អើកាលណុងមួយជំនាន់ណុងយើងទើបស្រុកមានសង្គ្រាមហ្នឹងមិនយើងគេលែងអោយស្លៀកហើយសារ៉ុងចឹងអីហោស យើងគេអត់ទាន់មានប្រដាប់ខ្មៅអីធ្វើអោយយើងចែកអោយយើងទេនេះច្រលូកហោសច្រលូកសារ៉ុងច្រលូកអីហ្នឹងម៉ាក្លៀបុកច្រលូកសារ៉ុងអីហ្នឹង រួចទៅខ្ញុំវាអត់ទាន់មានបងខ្ញុំចែអឹមានរួចខ្ញុំសុំចែអឹងសារ៉ុងច្រើនហាសហើយទៅច្រលូកសំពត់ខ្មៅបានច្រើនហាសរួចទៅខ្ញុំសុំមួយមកគេនិយមស្លៀកសំពត់ខ្មៅហើយណាស់។

កៈ បាទអុឹ!

ខៈ ចឹងអត់អោយខ្ញុំទេរួចទៅលឺដល់ពុកលឺដល់ពុកពុកថាកុំធ្វើចឹងកូនបើបងមានប្អូនគ្មានចែកគ្នាទៅប្អូនគ្មានប្អូនមានបងមានចែកទៅបងទៅកូនឯងធ្វើចឹងឪពុកម្តាយសប្បាយចិត្តណាស់កូន បើកូនឯងអាម៉ុងអាខាំងគ្នាអត់ចេះចែកបងប្អូនឪពុកពិបាកចិត្តណាស់។

កៈ បាទអុឹបាទ!

ខៈ អើឪពុកខ្ញុំពូកែផ្គាំអនុស្សាវរីយ៍មានតែប៉ុណ្ណឹងខ្ញុំចាំឪពុកខ្ញុំ។

កៈ អូ៎!

ខៈ ឪពុកខ្ញុំល្អមែនក្មួយកុំចង់និយាយខ្ញុំនឹកឪពុកខ្ញុំនឹកមែន ហើយខ្ញុំអត់មានរូបថតមួយជំនាន់ស្រុកកើតសង្គ្រាមយើងចេះតែរត់ទីណាត់ទីណែងវាមិនស្រួលដូចយើងនៅផ្ទះតែមួយណាក្មួយ។

កៈ បាទៗ!

ខៈ ស្រុកកើតសង្គ្រាមគ្រាប់បន្តក់គ្រាប់ផ្លោងយើងចេះតែរត់ទៅ។

កៈ អូ៎!

ខៈ វាជ្រុះនេះជ្រុះនោះអស់ហើយកុំថាជ្រុះតែរបស់តែមាសប្រាក់អីក៏យើងភ្លេចភ្លាំងជ្រុះអស់មានអីទេ។

កៈ អូ៎!

ខ៖ ស្រុកកើតសង្គ្រាមសង្គ្រាមមែនណុងនិយាយមែនទែនហាស!

ក៖ បាទអ៊ុំបាទ!

ខ៖ ម៉ាជំនាន់អ៊ុំណុងជំនាន់ចិតសិបរដ្ឋប្រហារទំលាក់សម្ដេចឪយើងយកអាលែងលុនណុលធ្វើរដ្ឋប្រហារទំលាក់សម្ដេចឪយើងពិបាកហាសបង។

ក៖ ចាំពិបាកណាស់បាទៗ!

ខ៖ ចាំ!

ក៖ ចុះអើ..?

ខ៖ ខ្ញុំចាំអនុស្សាវរីយ៍ឪពុកខ្ញុំតែប៉ុណ្ណឹងខ្ញុំចាំ។

ក៖ បាទអ៊ុំ!

ខ៖ ចឹងបានខ្ញុំប្រដៅចៅៗខ្ញុំត។

ក៖ ត្រូវអ៊ុំត្រូវ!

ខ៖ ប្រដៅចៅៗតកុំចេះឈ្លោះគ្នាណាស់ចៅ។

ក៖ បាទអ៊ុំបាទ!

ខ៖ បងប្អូនពីរបីនាក់ហ្នឹងចេះស្រឡាញ់គ្នាលេងតែជាមួយបងប្អូនយើងបានហើយមិនបាច់លេងជាមួយអ្នកក្រៅទេខ្ញុំប្រដៅចឹង។

ក៖ បាទ!

ខ៖ អត់មានទេមានតែទឹកក្ដៅអត់ទាន់មានពីណាបានដាំ។

ក៖ ចុះអ៊ុំគិតថាអើទាក់ទងពីម្ដាយរបស់អ៊ុំវិញគាត់ធ្លាប់ប្រាប់ពីប្រវត្តិកាលគាត់នៅក្មេងទៅអ៊ុំអត់អ៊ុំ?

ខ៖ ម៉ែហោស?

កៈ បាទអ៊ុំបាទ!

ខៈ ម៉ែខ្ញុំនិយាយម៉ែខ្ញុំដូចធម្មតាម៉ែខ្ញុំធម្មតាទេក្មួយម៉ែខ្ញុំធម្មតាគាត់មិនទេគាត់ដូចនឹកមើលនឹក ទៅគាត់មិនដូចអត់ប្រដៅកូនផងគាត់អត់ទេគាត់ធម្មតា ប៉ុនគាត់អត់រើកូនតែប៉ុណ្ណឹង!

កៈ បាទអ៊ុំបាទ!

ខៈ អើម៉ែដូចអត់មានប្រដៅអីទេប្រដៅម៉ែតែការងារស្រីគាត់គាត់អោយចេះតែកូនមើលជូតផ្ទះ ថែផ្ទះថែផ្ទះសំបែងអីចឹងទៅ អើដាំស្លដាំអីចឹងទៅកូនអើយអាហ្នឹងហើយការងារស្រីគាត់ថាចឹ ងហាស!

កៈ បាទអ៊ុំ!

ខៈ អើកូនឯងការងារស្រីមានតែប៉ុណ្ណឹងកុំអាលែងបានពីព្រៃមកផ្ទះអស់អើ ខ្លាំងអាគេមនុស្ស ប្រុសតើបានពីព្រៃមកផ្ទះអស់ហ្នឹងកូនការងារស្រីយើងអត់ដូចប្រុសទេណាស់ចេះទុកចេះដាក់ ចេះរៀបចេះចំប៉ុណ្ណឹងទៅបានហើយ!

កៈ បាទអ៊ុំ!

ខៈ ចាំ!

កៈ ចុះអ៊ុំគិតថាយាយតាខាងឪពុកអ៊ុំស្គាល់ឈ្មោះគាត់អត់?

ខៈ ស្គាល់តើប៉ុនអត់បានជួបមុខគាត់ទេ។

កៈ អ៊ុំអត់ទាន់ទេណេះ?

ខៈ អត់ទាន់ទេព្រោះពុកខ្ញុំកូនកំព្រា។

កៈ អូ៎!

ខៈ ចាំពុកខ្ញុំកូនកំព្រាតាំងពីតូចៗម៉េស។

កៈ បាទអ៊ុំចុះគាត់ឈ្មោះអីគេអ៊ុំយាយតាខាងឪពុក?

ខៈ តាតាខ្ញុំឈ្មោះតាដុកអើ..!

ក៖ តាដុក?

ខ៖ យាយឈ្មោះយាយកៀន។

ក៖ យាយកៀន?

ខ៖ ចាំ!

ក៖ ចុះយាយតាខាងម្ដាយអ៊ុំ?

ខ៖ តាខាងម្ដាយតាខ្ញុំឈ្មោះតាម៉ៅ។

ក៖ ចុះយាយ?

ខ៖ យាយខ្ញុំឈ្មោះយាយតាង។

ក៖ យាយតាង?

ខ៖ ចាំ!

ក៖ ចុះយាយតាខាងឪពុកហ្នឹងយាយតាខាងម្ដាយគាត់អ្នកស្រុកនៅណាយាយ?

ខ៖ ខាងឪពុកខ្ញុំយាយតាខាងឪពុកខ្ញុំអ្នកនៅជ្រាន។

ក៖ អូ៎អ្នកនៅជ្រាន?

ខ៖ អ្នកនៅជ្រានជនាងចាំ!

ក៖ អូ៎កមពង់ចាមយើងដែរ?

ខ៖ ចាំ!

ក៖ ចុះយាយតាខាងម្ដាយ?

ខ៖ នៅកោះ។

ក៖ នៅកោះ?

ខ៖ចាំ!

ក៖ កោះជ្រូកហ្នឹងហោស?

ខ៖ កោះជ្រូក។

ក៖ អូ៎បាទអ៊ុំ!

ខ៖ ចាំ!

ក៖ ចុះអើប៉ុន្តែអ៊ុំអត់ទាន់ពួកគាត់ទាំងអស់ម៉ងមែនអ៊ុំ?

ខ៖ ខ្ញុំទាន់បានតែយាយខ្ញុំមួយ។

ក៖ យាយខាងណាអ៊ុំ?

ខ៖ យាយខាងម៉ែខ្ញុំ។

ក៖ អូ៎បាទអ៊ុំ!

ខ៖ យាយខាងម៉ែខ្ញុំស្អាតហាសដូចបារាំងចឹង។

ក៖ អូ៎!

ខ៖ ស្អាតហាសគាត់និយាយទៅអើគាត់ដូចថាជីវភាពរស់នៅរបស់គាត់គាត់សមរម្យមួយគាត់មិនជាអ្នកពិបាកទេអាហ្នឹងម៉ែខាងម៉ែខ្ញុំហាស!

ក៖ បាទអ៊ុំបាទ!

ខ៖ ចាំ!

ក៖ រួចទៅ..?

ខ៖ ខ្ញុំដេកតែជាមួយគាត់ហ្នឹងគាត់បង្រៀនតែធម៌។

ក៖ អូ៎!

ខ៖ ខ្ញុំដេកតែជាមួយយាយហ្នឹង!

ក៖ បាទអ៊ុំរួចទៅបើយាយតាខាងឪពុក?

ខ៖ អត់ទាន់ផងខ្ញុំអត់ទាន់ណាតែពុកខ្ញុំគាត់កូនកំព្រាហើយខ្ញុំបានអីខ្ញុំទាន់។

ក៖ អ៊ូ!

ខ៖ ចាំ!

ក៖ បាទអ៊ុំបាទចុះអើអ៊ុំគិតថាអ៊ុំមករស់នៅហ្នឹងយូរអស់រយះពេលប៉ុន្មានឆ្នាំហើយអ៊ុំពេលនៅហ្នឹង?

ខ៖ នៅហ្នឹងហោស?

ក៖ បាទ!

ខ៖ ខ្ញុំគេធ្វើអាលែងស្រុកចប់សង្គ្រាមរួចមិនយើងបានចូលស្រុកចូលទេសវិញ។

ក៖ បាទអ៊ុំ!

ខ៖ អើឆ្នាំវ៉ៃដាច់រួចខ្ញុំតាខ្ញុំតាពេជ្រហ្នឹងមេម៉ាយតើទៅដណ្ដឹងខ្ញុំហ្នឹង!

ក៖ អ៊ូ!

ខ៖ ព្រោះម៉ែខ្ញុំកូនស្រីមានប្រាំនាក់ណាស់ក្មួយហាស!

ក៖ បាទអ៊ុំ!

ខ៖ គាត់ថាកូនស្រីរួចទៅគាត់ចេះតែអោយទៅប្ដីមេម៉ាយក៏ដោយមិនត្រូវក៏ដោយ។

ក៖ ដោយសារយើងកូនច្រើនណេះអ៊ុំ?

ខ៖ ចាំដោយសារយើងកូនច្រើនគាត់មនុស្សស្រីគាត់ក្ដោបក្ដាប់កូនមិនបាន..។

ក៖ ទាំងអស់ទេ?

ខ៖ ល្អទេ។

ក៖ បាទ!

ខ៖ ចាំខ្លាចអ្នកដទៃវាមើលងាយមើលថោកកូនហាស!

ក៖ បាទអ៊ុំ!

ខ៖ ចឹងមានគេណាគេដណ្ដឹងហើយត្រឹមត្រូវហើយដូចថាមើលទៅអ្នកសមរម្យគាត់អោយហើយ!

ក៖ យកទៅ..?

ខ៖ ចាំ!

ក៖ បាទល្អអ៊ុំ!

ខ៖ ចាំ!

ក៖ ប៉ុន្តែពីមុនហ្នឹងអ៊ុំនៅហ្នឹងអ៊ុំនៅកោះជ្រូក?

ខ៖ ខ្ញុំនៅកោះជ្រូកតើក្មួយ។

ក៖ អូ៎បាទអ៊ុំចឹងនៅពេលអ៊ុំការហើយនៅខាងប្ដី?

ខ៖ ចាំមកនៅខាងប្ដី។

ក៖ អូ៎បាទចុះអើអ៊ុំមានបងប្អូនកូនចៅណាដែរទៅរស់នៅក្រៅប្រទេសអត់អ៊ុំ?

ខ៖ សព្វថ្ងៃហ្នឹងហោស?

ក៖ បាទ!

ខ៖ ខ្ញុំបានកូនមួយ។

ក៖ គាត់..?

ខ៖ និយាយខ្ញុំហ្នឹងហាសចំណាស់ខ្ញុំហ្នឹងបានកូនមួយទៅនៅស្រុកបារាំងដែរទៅនៅប្រទេសបារាំង។

ក៖ អូ៎!

ខ៖ ចាំ!

ក៖ កូនបង្កើតម៉ងហោស?

ខ៖ ចាំកូនខ្ញុំយកតាពេជ្រហ្នឹងហាស!

ក៖ អូ៎!

ខ៖ បានមួយហ្នឹងដែរ។

ក៖ គាត់ធ្វើអីគេនៅណុងអុំ?

ខ៖ គ្នាមានធ្វើអីគ្នាគ្មានបានរៀនណាចេះដឹងជ្រៅជ្រះទៅធ្វើដៅកែអីណាគេគេធ្វើការងាររដ្ឋហ្នឹងណាស់ក្មួយ។

ក៖ អូ៎ធ្វើការងារ..?

ខ៖ ចាំការងារ..។

ក៖ ស៊ីឈ្នួល..?

ខ៖ ស៊ីឈ្នួលគេនៅប្រទេសគេហ្នឹងហាសចាំ!

ក៖ អូ៎ម៉េចបានគាត់បានទៅអុំ?

ខ៖ តាមរយះអាលែងនេះកូនអាលែងកុងឈាន កុងឈានហ្នឹងមិនយកយាយសុកហ្នឹងយាយសុកហ្នឹងម៉ែតាខ្ញុំតាពេជ្រហាស!

ក៖ បាទអុំ!

ខ៖ ចាំម៉ែតាពេជ្រហ្នឹងប៉ុនតារីនហ្នឹងប្អូនតាឌីហ្នឹងខ្ញុំយកជីដូនមួយណាស់ក្មួយណាស់ហ្នឹងហាស!

ក៖ បាទអ៊ុំ!

ខ៖ តាឌីហើយតារីនបងប្អូនបង្កើតរួចដល់តារីនហ្នឹងគាត់ខូចទៅយាយហ្នឹងមិនគាត់យកកុងចៀន។

ក៖ បាទអ៊ុំបាទ!

ខ៖ កុងចៀនយាយអយហោសស្គាល់ទេណុងអើយកកុងចៀនហ្នឹងចឹងរយះហ្នឹងរយះខ្សែខាងកុងចៀនហាស!

ក៖ គេទៅនៅណុងម៉ងហោស?

ខ៖ ចាំគេនៅភ្នំពេញហោសគេសុទ្ធតែអ្នកធំឥឡូវគេសុទ្ធអ្នកធំ។

ក៖ អូ៎!

ខ៖ ចាំរួចទៅយាយទូចណុងម៉ែប្អូនកុងចៀនណុងស្រឡាញ់តាពេជ្រណុងហាសគាត់ថាហែងមានកូនប៉ុន្មាននាក់ហើយឥឡូវអាពេជ្រ រួចទៅថាខ្ញុំកូនប្រាំនាក់កូនហែងធំៗហើយហោសហ្នឹងកូនខ្ញុំបានដូចថាវាចេះជួយធ្វើការងារអីដៃជើងអីឪពុកម្តាយហើយ ចឹងហែងអោយអញ់ម្នាក់ពីរនាក់មកអោយទៅនៅគាត់ណុងហាស!

ក៖ បាទ!

ខ៖ អោយទៅហ្នឹងគាត់ទៅគេមើលចរឹតរឹកពារកូនខ្ញុំហ្នឹងវាល្អមីស៊ីរខេងហ្នឹងហាស!

ក៖ បាទអ៊ុំ!

ខ៖ ល្អកូនហ្នឹងហាសអ្នកមានគេសុទ្ធតែមើលខែឆ្នាំកូនយើងអាកូនយើងហ្នឹងខែឆ្នាំយកទៅចំរុងចំរើនគ្រួសារគេអាណុងគេយក។

ក៖ អូ៎!

ខ៖ ចាំគេយកកូនខ្ញុំទៅបារាំងទៅ។

ក៖ ទាល់ឥឡូវហ្នឹង?

ខ៖ ទាល់ឥឡូវហ្នឹងទៅឥឡូវកូនខ្ញុំបានកូនបីនាក់ហើយ!

ក៖ នៅបារាំងណុង?

ខ៖ ចាំ!

ក៖ គាត់យកប្ដីនៅបារាំងណុងម៉ងហោស?

ខ៖ វាយកប្ដីនៅបារាំងហោសប៉ុនប្ដីវាចិនទេចិននៅស្រុកបារាំង។

ក៖ អូ៎!

ខ៖ ចាំ!

ក៖ រួចចុះអើគាត់មានដៃរមកលេងយើងអីអត់?

ខ៖ កាលខ្ញុំនៅភ្នំពេញមកបានពីរដងដៃរដល់មកធ្វើផ្ទះនៅហ្នឹងអត់ទាន់បានមកទេក្មួយ។

ក៖ គាត់ទៅអស់រយះពេលប៉ុន្មានឆ្នាំហើយអ៊ុំ?

ខ៖ អឺទៅយូរដែរហើយតើជាងម្ភៃឆ្នាំហើយហោសម្ភៃឆ្នាំហើយ!

ក៖ អូ៎!

ខ៖ ចាំទៅយូរហើយតាំងពីអាយុវាដប់បួនឆ្នាំហើយម៉េស។

ក៖ បាទអ៊ុំ!

ខ៖ ចាំគេយកទៅណុងហាស!

ក៖ គាត់ទៅធ្វើអីគេនៅណុងទៅអ៊ុំ?

ខ៖ ចាំ!

កះ គាត់ទៅធ្វើអីគេនៅបារាំងណុងទៅកូនអ៊ុំ?

ខះ កាលនៅតូចហ្នឹងនៅបំរើផ្ទះគេហ្នឹងហាសនៅមើលខុសត្រូវដូចថាជាងឈ្នួលគេចុះណាស់។

កះ នៅបារាំងណុង?

ខះ នៅបារាំងណុងយើងនៅមើលថែរក្សាផ្ទះសំបែងគេហ្នឹងចាំបងងងុយណេះសំរាន។

កះ អត់អីទេអ៊ុំ!

ខះ ចាំ!

កះ អត់អីទេ!

ខះ នៅចឹងហាសក្មួយម៉េចគេហៅជើងឈ្នួលគេគេយកទៅបំរើគេហ្នឹងហាស!

កះ បាទអ៊ុំបាទ!

ខះ អើល្មមបានគេបើកសិទ្ធិដើរនៅប្រទេសគេទាល់តែយើងដើរហាសបានយើងមានហាស!

កះ បាទអ៊ុំបាទ!

ខះ មែនដូចខ្មែរយើងគ្រាន់គេមើលឃើញចូលដណ្ដឹងអីចឹងណាមិនចឹងហីក្មួយហេស!

កះ បាទត្រូវអ៊ុំ!

ខះ ចាំបំរើគេសព្វគ្រប់អត់ដូចថាឆ្អែតឆ្អន់ទៅគេក៏អោយយើងមានដើរលេងទៅ កូនប្រសារខ្ញុំមើលឃើញទៅគេដណ្ដឹងទៅ។

កះ អូ៎!

ខះ ចាំ!

កះ ប៉ុន្តែគ្រាន់ថាគាត់នៅតែធ្វើរលុយអោយយើងចាយ?

ខះ បានក្មួយអោយកាលម្និកគ្នានៅជាមួយគេណុងវាយូរឆ្នាំដែរហើយមិនដែរមានអីទេណាស់។

កៈ បាទ!

ខៈ ដល់ពេលគ្នាមានប្ដីទៅមាន។

កៈ ប្ដីគាត់មានដែរណេះ?

ខៈ ទេមិនមានទេ។

កៈ តែប្ដីគាត់ធ្វើអីគេនៅណុងអ៊ុំ?

ខៈ មិនមានទេធ្វើការចឹងដែរតើក្មួយ។

កៈ ធ្វើអី?

ខៈ ខ្ញុំមិនបានសួរដេញដោលស្អីកូនច្រើនទេ។

កៈ អូ៎!

ខៈ ប៉ុនគ្រាន់ថាប្ដីធ្វើការមានប្រាក់ខែអីចឹងហាស!

កៈ បាទអ៊ុំបាទ!

ខៈ ចាំការងារអីខ្ញុំ..។

កៈ គាត់មានផ្ទះអីមានឡានអីចឹងទៅ?

ខៈ ជួលគេដែរទេក្មួយមិនទាន់មានទេ។

កៈ អូ៎ចឹងហោស?

ខៈ ជួលផ្ទះគេទេ។

កៈ ឥឡូវហោស?

ខៈ ហ្នឹងហើយចា!

កៈ ប៉ុន្តែអេីគាត់តែងតែតេមករកអ៊ុំ?

ខ៖ ចាំតេ។

ក៖ តេមករាល់ថ្ងៃចឹងទៅ?

ខ៖ ចាំៗយូរៗដូចថាមួយខែអីចឹងតេមកលេងសួរសុខទុក្ខម្ដាយចឹងមាន។

ក៖ អូ៎ប៉ុន្តែគ្រាន់ថា..?

ខ៖ ខ្ញុំបានកូនណាងហើយថាគេចិញ្ចឹមដូចថាអោយមានរុសរាននមានជីវិតហ្នឹងហាសក្មួយហាស!

ក៖ ចឹងហោសអ៊ុំ?

ខ៖ បន្តក់ៗមកប៉ុនគ្រាន់ថាមិនអោយមានទេណាស់ចិញ្ចឹមម្ដាយគេចិញ្ចឹម។

ក៖ គ្រាន់ថា..?

ខ៖ ចិញ្ចឹមមែនចាំ!

ក៖ យើងមានលុយចាយគ្រប់គ្រាន់?

ខ៖ ចាំបានគ្រាន់ថាគេមិនអោយយើងសំបុសសំបូរហូរហៀរទេ មើតែយើងជិតអស់មកដល់ទៀតហើយអើ!

ក៖ អូ៎!

ខ៖ ចាំពីររយពីរអីចឹងមកក្មួយឥឡូវជិតអស់ទៀតហើយ!

ក៖ អូ៎ចឹងគាត់ផ្ញើរមកចឹង?

ខ៖ ផ្ញើរចាំ!

ក៖ អូ៎!

ខ៖ កូនណាងល្អហាសកូនណាងហោស!

ក៖ បាទអ៊ុំបាទ!

ខ៖ ចាំ!

ក៖ ចុះអើក្រៅពីហ្នឹងនៅខ្មែរទាំងអស់?

ខ៖ នៅខ្មែរ។

ក៖ ចុះអើមានអ្នកនៅខេត្តផ្សេងជៀសពីខេត្តកំពង់ចាមអត់អ៊ុំ?

ខ៖ មានកូនខ្ញុំណុងហោស?

ក៖ បាទអ៊ុំ!

ខ៖ និយាយរឿងពីកូនហោសកូនពីការដប់ពីរនាក់ហើយកូនខ្ញុំតែប្រាំនាកើទេណាស់ក្មួយហាស!

ក៖ បាទអ៊ុំ!

ខ៖ អើដល់ពីការពីរហើយយើងខ្ជិលនិយាយ។

ក៖ បាទ!

ខ៖ យើងនិយាយតែបីនាក់បានហើយម្នាក់ទៀតនៅស្រុកក្រៅដៃរខ្ញុំនិយាយខាងកើណុងហាស!

ក៖ បាទ!

ខ៖ រួចពីរនាក់ទៀតវាទៅរកស៊ីនៅភ្នំពេញណុងធ្វើបាយធ្វើសំលលក់ទៅកំប៉េកកំប៉ុកនៅក្នុងការដ្ឋានគេ។

ក៖ អូ៎!

ខ៖ រួចអាមួយហោសអាទីមួយឈ្មោះអាប៉ូ ខ្ញុំកូនប្រុសបីបានរួចអាបងមួយហាសផុតពីក្រញាំដៃដើរវាធ្វើបាបទាញសរសៃកូនខ្ញុំហ្នឹងបានរួចតែអាបងណុងមួយទេ។

ក៖ ក្រៅពីរហ្នឹងពីរនាក់ប្រុសៗ?

ខ៖ ក្រៅពីហ្នឹងបងប្រុសៗហ្នឹងទៅហើយ!

ក៖ តែស្រីៗអត់អីទេ?

ខ៖ ចាំស្រីៗអត់អីទេអាណុងនៅជាមួយមេគេហោស!

ក៖ បាទអ៊ុំ!

ខ៖ ទេកូនខ្ញុំនៅជាមួយមេ។

ក៖ អូ៎!

ខ៖ ចាំគេអោយមើលការខុសត្រូវវាដូចថាវាធ្វើមេការអីចឹងមើលរ៉ាប់រងអ្នកក្រោមៗវាហ្នឹងហាស ជួយធ្វើការអោយមេគេណុងហាស!

ក៖ អូ៎បាទអ៊ុំបាទ!

ខ៖ ចាំ!

ក៖ ប៉ុន្តែអើគាត់មានកូនចៅគាត់?

ខ៖ អើ!

ក៖ មានប្រពន្ធមានកូនចៅ?

ខ៖ មានក្មួយអើយមាន។

ក៖ អូ៎!

ខ៖ មានបានថានិយាយបើថានិយាយចូលក្នុងហ្នឹងយើងនិយាយអោយអស់ចុះណាស់យើងមិនសមនិយាយទេ អើពេលហ្នឹងយើងនិយាយចុះអាណិតអាកូនហ្នឹងវាឆ្លាតហ្នឹងរកស៊ីចិញ្ចឹមក្មួកជេក្លូកអីហ្នឹងវាបានលុយបានកាក់បានអីចឹងបានថាគ្រង់មនុស្សប្រុសវារកបានទៅវាដើរកាវ៉ាអូខេទៅមានស្រីមានញីអីចឹងហាស!

ក៖ អូ៎យើងហោស?

ខ៖ កូនខ្ញុំប្រុសហ្នឹងហាស!

ក៖ អុំបាទ!

ខ៖ ប៉ុនគ្រាន់ថាវាមិនចោលទេប្រពន្ធកូននោះ។

ក៖ អុំបាទអុំបាទ!

ខ៖ ចាំមិនចោលទេប៉ុនតែដល់យូរៗទៅវារកបានមកវាដើរតែចឹងវាធ្វើតែចឹងប៉ុនវាមិនចោលប្រពន្ធកូន។

ក៖ មិនសូវអោយយើងទេ?

ខ៖ អោយតើប្រពន្ធកូនហាស!

ក៖ អុំ!

ខ៖ ប្រពន្ធកូនវាអោយប៉ុនត្រង់ថាយូរៗទៅមនុស្សស្រីហ្នឹងវាមនុស្សស្រីមានចង់មានចង់បានវាខឹងប្តីវាធ្វើទង្វើវាមិនព្រមកែខ្លួនដូចថាខ្លួនហ្នឹងនៅតែធ្វើទៅអារបៀបចឹងៗចឹងហាសគេខឹង។

ក៖ បាទអុំ!

ខ៖ ខឹងទៅក្មួយអើយគេលែងទៅគេដាច់ខាតត្រូវតែលែង។

ក៖ ឥឡូវហ្នឹងហោស?

ខ៖ លែងលែងហ្នឹងខ្ញុំបានចៅបួននាក់ដែរ។

ក៖ អុំ!

ខ៖ នោះចៅទីមួយមីរូធូបថតនោះកូនអើយមើលខ្ញុំយកអោយមើល។

ក៖ អុំបាទអុំបាទ!

ខ៖ ហ្នឹងហាសកូនហានឹងស្អាតៗណាស់ក្មួយ។

ក៖ អុំ!

ខ៖ ចឹងបានខ្ញុំអាណិតកូនអាណិតចៅ។

ក៖ អូ៎ចៅធំហើយហោស?

ខ៖ ចៅអូ៎ឥឡូវធំហើយអាហ្នឹងវានៅពីតូចហ្នឹងហាសហ្នឹងកាលវានៅហ្នឹងឪពុកម្ដាយនៅជុំគ្នាទេហ្នឹងហាស!

ក៖ អូ៎!

ខ៖ ឪពុកម្ដាយជុំគ្នារូបកូនវាស្អាតៗហាសមីភ្លោះពីរដូចកូរ៉េ។

ក៖ អូ៎!

ខ៖ ហ្នឹងមីទីមួយដល់កើតបានទីពីរវាបានបីនាក់។

ក៖ ភ្លោះណោះអុី?

ខ៖ ភ្លោះ។

ក៖ អូ៎!

ខ៖ សុទ្ធតែស្រីកូនស្អាតៗណាស់។

ក៖ កូនបង?

ខ៖ ខ្ញុំកូនមីហ្នឹងកូនបងហ្នឹងនៅរៀនទេថ្នាក់ទីដប់ពីរហើយឥឡូវហោស!

ក៖ នៅណានៅភ្នំពេញហ្នឹង?

ខ៖ នៅភ្នំពេញ។

ក៖ អូ៎!

ខ៖ រៀនឥឡូវលែងម៉ាក់យាយវាហ្នឹងហាសម៉ាក់យាយឡាប់ផេងហ្នឹងហាសគាត់អោយនៅជាមួយគាត់ហាសហ្នឹងហាស!

ក៖ បាទអុីបាទ!

ខ៖ នៅជាមួយទីគាត់គ្រប់គ្រងយើងទៅតែរៀនយកចំណេះវិជ្ជាទៅ។

ក៖ អ៊ុំស្រួល?

ខ៖ ណុងបែកបាក់ឪពុកណុងបានយាយណុងទាញចៅណុងយកទៅមួយ។

ក៖ បាទអ៊ុំបាទ!

ខ៖ អើបានតែមួយហើយកូន។

ក៖ ប៉ុន្តែអើចឹងនៅពេលពួកគាត់បែកបាក់គ្នាពួកគាត់អើអ៊ុំបានដូចជាយកចៅមកទាំងអស់?

ខ៖ ចៅមុនខ្ញុំនៅខ្ញុំនៅចិញ្ចឹមវាទាល់តែប៉ុណ្ណឹងៗហាស!

ក៖ បាទអ៊ុំ!

ខ៖ ចាំនៅចិញ្ចឹមតើនៅលើខ្ញុំទាំងអស់តើចៅៗហ្នឹង!

ក៖ អ៊ុំ!

ខ៖ ទទួលអាណុងអត់ទាន់បែកគ្នាទេណាស់។

ក៖ បាទ!

ខ៖ ដល់ពេលបែកគ្នាម៉ែគេទាញយកអស់ទៅ រួចខ្ញុំក៏អត់ទាញយកដែរខ្ញុំថាអោយវានៅជុំម៉ែវាទៅណាស់។

ក៖ បាទ!

ខ៖ អោយវានៅជុំបងប្អូនវាទៅ។

ក៖ ចឹងមានន័យថាឥឡូវហ្នឹងនៅខាងប្រពន្ធទាំងអស់?

ខ៖ ឥឡូវនៅខាងប្រពន្ធដើមវាទាំងអស់។

ក៖ ចុះអើកូនរបស់អ៊ុំមានប្រពន្ធថ្មីទៀត?

ខ៖ អើមានប្រពន្ធថ្មីហ្នឹងទៅ។

ក៖ ចឹងមានកូនប៉ុន្មាននាក់ទៀតទៅ?

ខ៖ អត់មានទេ។

ក៖ អត់មានទេហោស?

ខ៖ អើអត់មានទេ។

ក៖ ឥឡូវរាល់ថ្ងៃគាត់នៅភ្នំពេញ?

ខ៖ ចាំប៉ុនគ្រាន់តែវាហ្នឹងវាធម្មមេត្តាអូនអាកូនប្រុសខ្ញុំហ្នឹងហាស!

ក៖ បាទអ៊ុំ!

ខ៖ អោយតែមានលុយបានដល់កូនហើយពេលណាគ្មានគ្នាមានបានអីអោយតែមានអោយហើយគិតថាខ្លួនវាមិនមានទេហីទៅវាអត់ខ្វល់។

ក៖ អ្ហ៎!

ខ៖ វាធ្វើម៉េចដើម្បីតែកូនវាដើម្បីតែម្ដាយខ្លួនខ្ញុំចឹងដែរវាអោយខ្ញុំតើ!

ក៖ ប៉ុន្តែអើ..?

ខ៖ កាលណាវារកបានវាអោយម៉ែហើយ!

ក៖ បាទអ៊ុំ!

ខ៖ បើវាគ្មានទេមិនបាច់មើលផ្លូវទេវាអត់មានហើយណុងហោស!

ក៖ បាទអ៊ុំ!

ខ៖ អើ!

ក៖ ប៉ុន្តែអើកូនគាត់នៅតែទៅលេងគាត់ធម្មតាទៅ?

ខ៖ មានអីកូនកូនវាមិនបានទៅលេងទេកូនប្រឹងតែរៀន។

ក៖ អូ៎!

ខ៖ រៀនតើ!

ក៖ ប៉ុន្តែនៅខាងម្តាយទៅ?

ខ៖ នៅខាងម្តាយ។

ក៖ អូ៎បាទអ៊ុំ!

ខ៖ ម្តាយហ្នឹងវាល្អដែរខ្លះអត់ពីប្តីទៅលំបេកលំបាកហាសណាស់កូនណាស់។

ក៖ បាទអ៊ុំ!

ខ៖ អើខ្វាត់ខ្វាយគ្មានបានចេះដឹងអីទេអានេះកូនហ្នឹងកូនប្រសារខ្ញុំហ្នឹងវាល្អ វាបានអោយវាកូនចេះដឹងនៅរៀនសូត្រទាំងអស់។

ក៖ អូ៎បាទ!

ខ៖ ចាំហើយវាហ្នឹងក៏វាអត់បធិសេដចោលខ្ញុំដែរវានៅតែខ្ញុំហ្នឹងម៉ែវារហូត។

ក៖ កូនប្រសារហោស?

ខ៖ ម៉ែនៅក្នុងបេះដូងអើម៉ែ។

ក៖ កូនប្រសារអ៊ុំ?

ខ៖ ចាំ!

ក៖ អូ៎!

ខ៖ ម៉ែនៅក្នុងបេះដូងអើខ្ញុំឡើងផ្ទះហ្នឹងក្មួយអើយខ្ញុំធ្វើផ្ទះអស់លុយរលីងគ្មានទេអស់រលីងហើយ ដល់ពេលធ្វើយើងត្រូវឡើងផ្ទះយើងមិនត្រូវធ្វើពិធីឡើងផ្ទះ។

ក៖ បាទអ៊ុំបាទ!

ខ៖ ដើម្បីជំរាបម្ចាស់ទឹកម្ចាស់ដីយើងមកឡើងផ្ទះថ្មី។

ក៖ ត្រូវអ៊ុំ!

ខ៖ បានមីកូនប្រសារហ្នឹងគេម៉ែជូនម៉ែមួយលានហ្នឹង!

ក៖ គាត់មកដែរហោស?

ខ៖ អត់មកទេម៉ែអើយរវល់ណាស់ខ្ញុំហោស ខ្ញុំបានតែផ្ញើរលុយជូនម៉ែតាមវីងហ្នឹងមួយលាន។

ក៖ ពេលដែរគាត់ពេលដែរអ៊ុំធ្វើផ្ទះហើយឡើងផ្ទះហ្នឹងពួកគាត់បែកបាក់គ្នាហើយ?

ខ៖ បែកបាក់មុនហ្នឹងហើយបែកបាក់ហើយ!

ក៖ អូ៎!

ខ៖ បែកបាក់ហើយកូន។

ក៖ ប៉ុន្តែឥឡូវគាត់នៅតែទាក់ទងយើងវីមួយក៏អត់ទេ?

ខ៖ នៅទាក់ទងទាក់ទងអោយលុយឡើងផ្ទះហ្នឹងទៅយើងធ្វើសង់ក្រទានអីទៅចិញ្ចឹមប្អូនវាអាពិការហ្នឹងទៅ មានទៅវាអោយទៅមីកូនប្រសារខ្ញុំមុនហ្នឹងហាស!

ក៖ ទាល់ឥឡូវហ្នឹង?

ខ៖ ទាល់ឥឡូវហ្នឹងហាស!

ក៖ ចឹងមានន័យថា..?

ខ៖ ថាពីរខែមុនមកផ្ទះហ្នឹង!

ក៖ ចឹងមានន័យថាអើប្តីប្រពន្ធគាត់គ្រាន់តែបែកគ្នាទេប៉ុន្តែគាត់នៅរ៉ាប់រង?

ខ៖ គ្រាន់តែបែកទេគាត់នៅរ៉ាប់រង។

ក៖ នៅស្គាល់យើងដែរ?

ខ៖ចាំស្គាល់ៗ។

ក៖ អ៊ុំបើអ្នកខ្លះបែកបាក់..?

ខ៖ ចាំអត់ទេ។

ក៖ ពីរនាក់ប្តីប្រពន្ធចឹងលែងស្គាល់ម៉ែឪ?

ខ៖ ព្រោះម៉ែហ្នឹងមានធម្មមេត្តាល្អហ្នឹងវាកាលវានៅជុំកូនយើងហាស!

ក៖ បាទអ៊ុំ!

ខ៖ កូនខ្វះខាតស្អីខ្ញុំក៏គ្មានដែរកូនខ្ញុំគ្មានអីជួលអស្ចារ្យទេ ប៉ុនគ្រាន់ថាយើងមានប៉ុណ្ណាកូនរកទៅចេះតែអោយកូន។

ក៖ បាទអ៊ុំបាទ!

ខ៖ ចេះតែអោយកូនអើត្រង់ហ្នឹងហើយដៃរទង្វើយើងដឹងកូនហៅ ដល់កូនវាម៉េចម៉ាទៅមើលកូនគេនៅរាប់អានយើងតើក្មួយ។

ក៖ បាទអ៊ុំបាទ!

ខ៖ រាប់អានចាំចឹងបានអ្នកស្រុកថាអូយអ៊ុំនេះល្អហាស អ៊ីនេះល្អហាសណោះកូនគាត់មើលណោះបែកបាក់គ្នាហើយនៅតែទទួលស្គាល់។

ក៖ បាទៗ!

ខ៖ គេយកអង្ករគេយកលុយគេយកអីមកសំពះជូនយើងហ្នឹងហាសកូន។

ក៖ អ៊ុំត្រូវ!

ខ៖ ចាំជូន។

ក៖ ចុះអើអ៊ុំគិតថាចឹងទាក់ទងពីកូនទីពីរនៅបារាំងមែនអត់អ៊ុំ?

ខ៖ ចាំកូនទីបី។

កៈ អូ៎កូនទីបីហោស?

ខៈ អានេះទីពីរអានេះ។

កៈ អូ៎បាទ!

ខៈ ទីពីរចាំ!

កៈ ហើយកូនទីបីនៅបារាំង?

ខៈ ចាំ!

កៈ ចុះទីប្អូនស្រីមួយទៀតហោស?

ខៈ កូនទីប្អូនស្រីមួយទៀត។

កៈ ចុះគាត់នៅណា?

ខៈ អាហ្នឹងកូនវាថៅវានៅហ្នឹងខ្ញុំហ្នឹងកូនវាហ្នឹងៗ!

កៈ ចុះគាត់ទៅណាហើយ?

ខៈ ហ្នឹងកូនបីនាក់ហ្នឹងវានៅរកស៊ីនៅលក់បាយលក់សំលនៅអឺភ្នំពេញហោស!

កៈ អូ៎!

ខៈ ចាំលក់ក្នុងការដ្ឋាន។

កៈ ចឹងគាត់យកកូនមកទំលាក់នៅហ្នឹងទាំងអស់?

ខៈ ចាំ!

កៈ ដល់ពេលហើយ..?

ខៈ ក្នុងការដ្ឋានខ្ញុំពីមុនមកខ្ញុំទៅនៅជាមួយអាលែងជំទាវឡោកហេងហ្នឹងហាស!

កៈ បាទអឺុបាទ!

ខ៖ ខ្ញុំមើលដីមើលធ្លីអោយគេហ្នឹងក្មួយខ្ញុំមើលអោយគេតាខ្ញុំមើលការខុសត្រូវអោយគេសព្វបែបសព្វយ៉ាងហ្នឹង គាត់ក៏គ្មានអោយអីដែរដល់ដីគាត់បើកការដ្ឋានទៅយើងនៅរកស៊ីហ្នឹងគាត់ក៏អត់ថាអីដែរ។

ក៖ អូ៎!

ខ៖ ហ្នឹងហើយចាំ!

ក៖ ចុះអ៊ុំគិតថាអើចឹងដល់ពេលដែរគាត់ផ្ញើរលុយអោយរាល់ខែអោយមើលចៅៗអីចឹងទៅណោះអ៊ុំណោះ?

ខ៖ ចាំគេអោយជូនណាខ្ញុំអើគ្មានក៏វាដឹងថាម្ដាយល្អដែរ ម៉ែមិនដែរទៅពិសារអីតាពីសតាពាសទេម៉ែទិញតែម្ហូបទិញតែនុំអោយតែកូនស៊ីថៃរក្សាដូចថាកូនវាឈឺទៅម៉ែរត់រកពេទ្យរកអីចឹងទៅវាមើលឃើញទង្វើរបស់យើងចឹងទៅ គ្រាន់តែយើងថាស្មីអើយអញ់ជិតអស់លុយហើតកូនហាសម៉ែអស់លុយហើយណាស់កូនណាស់។

ក៖ បាទ!

ខ៖ អើអត់មានអីអោយចៅទេណាស់ចាំគេមិនដែរធ្ងន់ស្រាលអីទេណាស់ ចាំម៉ែខ្ញុំដឹងដែរតើម៉ែ។

ក៖ អូ៎!

ខ៖ អើហ្នឹងហើយខ្ញុំដឹងដែរតើម៉ែអើទៅដប់ប្រាំម៉ឺនមកម្ភៃម៉ឺនមក។

ក៖ ស្រួលហាសណោះអ៊ុំណោះ?

ខ៖ ចាំគេមើលថាម៉ែយ៉ាប់ហាសម៉ែមើលកូនអោយម៉ែឯងពិសារអីផងម៉ែឯងរួចក្មួយឯងអត់មានឃ្លានអីទេមើលឃើញតែកូនហ្នឹងចៅហ្នឹងស៊ីទៅវាមើលទៅខ្ញុំដូចជាឆ្អែតតាមកូនតាមចៅមែនតើ!

ក៖ អូ៎!

ខ៖ ឆ្អែត។

កៈ តែគាត់កូនបីណោះ?

ខៈ កូនបី។

កៈ ផ្ញើរនៅអុំ?

ខៈ កូនបីអើ!

កៈ អូ៎បាទអុំ!

ខៈ បានអាលែងគ្នាអូជូនណាអាទីមួយហ្នឹងគេផ្ញើរអោយប្អូនចឹងទៅ។

កៈ អូ៎!

ខៈ អើគែជួយជ្រុំជ្រែងសព្វដែរតើហ្នឹងហាសក្មួយហាស ប៉ុនគ្រាន់ថាគ្មានលុយសល់ទេមើលតែអស់ហ្នឹងបានមកទៀតមក។

កៈ អូ៎ស្រួលអុំចុះអើចឹងកូនទីពីរហើយហានឹងកូណពៅគាត់កើតអីបានគាត់ពិសារចឹង?

ខៈ កូនទីពីឬហើយហ្នឹងកូណពៅហ្នឹងហាសក្មួយហាសហោសអត់អីទេក្មួយ។

កៈ គាត់..?

ខៈ សរសៃទាញយកគ្នាតែម៉ងអើបួស។

កៈ ទើបតែឥឡូវតើហីអុំ?

ខៈ អើទើបឥឡូវហ្នឹងបួសបានប្រាំមួយវស្សាណាស់បួសបានប្រាំមួយវស្សាបួសបានបំពេញធឹកហើយតើ!

កៈ អូ៎!

ខៈ បំពេញធឹកឈ្មោះលោកប៉េងណុងហាសឈ្មោះប៉េង។

កៈ រួចដល់ដល់ពេលហើយសរសៃទាញយកម៉ង?

ខ៖ សរសៃទាញមើលមិនយល់វាមើលខ្លួនវាមើលកាលបួសណុង បួសណុងនៅជាព្រះសង្ឃណុងក៏ធ្លាប់មើលខ្លួនឯងដែរមើលៗមិនជារួចទៅខ្ញុំក៏ហ៊ានប៉ាវាហ្នឹងទៅសឹកទៅដើម្បីបានម្ដាយអីកាន់ហាស បើយើងដូចជាលោកនៅជាព្រះសង្ឃយើងជាយើងមនុស្សស្រីកាន់សាច់កាន់ឈាមលោកមិនបានទេណាស់។

ក៖ បាទអ៊ឺ!

ខ៖ អើចឹងទៅសឹកកូនមកដើម្បីយកកូនមកមើល។

ក៖ អូ៎!

ខ៖ មើលហ្នឹងគ្រាន់បានចឹងច្របាច់ឈ្លីចឹងអីអោយកូនលេបថ្នាំលេបសង្កូវអីចឹងហាសអោយគ្រូណាពូកែទៅហើយកូនអើយ!

ក៖ ប៉ុន្តែយើងអត់ដឹងថាកើតអីអោយច្បាស់ទេ?

ខ៖ កើតអីដឹងតែសរសៃទាញហ្នឹងសរសៃទាញហ្នឹងជំងឺអត់មានគ្រុនក្ដៅរងាអីក្ដីអីសរសៃទាញយក..។

ក៖ គាត់សុខៗចឹងម៉ង..?

ខ៖ មួយឆ្នាំតិចៗ។

ក៖ អូ៎ៗ

ខ៖ ខ្មែរក៏មើលពេទ្យក៏មើលមើលសព្វមើលគ្រប់។

ក៖ អូ៎!

ខ៖ មើលមិនជារួចមកអាទីប្រាំហ្នឹងបាននិស្សិតទីពីរណាស់ក្មួយហាស!

ក៖ បាទអ៊ឺបាទ!

ខ៖ ជិះម៉ូតូលេងកើតហាសបានឈប់រៀនហាស!

ក៖ អូ៎!

ខ៖ ណុងហាសបើសិនជាកូនខ្ញុំបាននៅរៀនសុទ្ធតែមានការងារធ្វើណាស់ក្មួយ។

ក៖ បាទអ៊ុំ!

ខ៖ រួចនេះមិននេះទេបួសហ្នឹងបួសដណ្តើមទាមទារទៅអនាគត់ហ្នឹង នៅព្រះសង្ឃហ្នឹងហើយដើម្បីព្រះពុទ្ធសាសនាហ្នឹងហើយអត់មានកែប្រែមកព្រះសក់វិញទេ។

ក៖ បាទអ៊ុំ!

ខ៖ អើក្មួយ..។

ក៖ រួចចុះកូនៗពៅហ្នឹងឥឡូវគាត់នៅណា?

ខ៖ នៅភ្នំពេញនៅជាមួយម៉ែវាហ្នឹងហាស!

ក៖ អូ៎!

ខ៖ នៅអង្គុយហ្នឹងតុហ្នឹងទៅឥវ៉ាន់គេដាក់ជិតខ្លួនហ្នឹងទៅមានទូទឹកកកមានអីចឹងទៅ មីបងធ្វើបាយធ្វើទឹកលក់ទៅអាប្អូនមាននុំចំណីអីចឹងទៅកម្មករគេចូលទិញអីចឹងទៅនរណាទិញអោយលុយទៅនរណាជំពាក់កត់ឈ្មោះគេទៅ។

ក៖ អូ៎!

ខ៖ គ្រាន់នៅអង្គុយលើតុកត់ឈ្មោះអោយគេទៅ។

ក៖ គាត់នៅសរសេរបានអីបាន?

ខ៖ ចាំបាន។

ក៖ ប៉ុនគ្រាន់គាត់អត់ដូចបងប្រុសទេ?

ខ៖ នៅនៅមាំជាងហ្នឹងបន្តិច។

ក៖ អូ៎!

ខ៖ ចាំក្មួយ។

កៈ ចឹងអ៊ុំនៅកូនប្រាំនាក់ហ្នឹងណេះអ៊ុំណេះ?

ខៈ កូនប្រាំ។

កៈ អូ៎បានអ៊ុំចុះអើប្ដីរបស់អ៊ុំឈ្មោះអីគេអ៊ុំ?

ខៈ ឈ្មោះរីនពេជ្រ។

កៈ តែគាត់អើគាត់ធ្វើអីគេ?

ខៈ គាត់ធ្វើអីនៅជាមួយជំទាវឡោកហេងហ្នឹងហាស!

កៈ ឥឡូវហ្នឹងហោស?

ខៈ ចា៎នៅហ្នឹងគេមានអោយធ្វើអីទេគ្រាន់អោយនៅតែផ្ទះហ្នឹង អើថ្ងៃណាត្រូវធ្វើអីការងារតិចតួចចឹងហាសគាត់ប្អូនគាត់ក៏មិនចង់ប្រើមនុស្សចាស់ដែរគាត់អាណិតបងប្អូនគាត់។

កៈ អូ៎!

ខៈ គាត់មិនអោយមកទេមកនៅស្រុកស្រែយ៉ាប់។

កៈ ចឹងមានន័យថា..?

ខៈ នៅជិតគាត់ទៅគ្រាន់បានជិតពេទ្យជិតម៉ហើយគ្រាន់គាត់បានមកអើតមកឆ្ងកអីចឹងទៅមាននុំមានចំណីអោយបងគាត់ពិសារចឹងទៅដើម្បីជួយអាយុជីវិតបងគាត់អាយុវែងចឹងទៅណាស់។

កៈ បាទអ៊ុំបាទ!

ខៈ មកនៅហ្នឹងយ៉ាងក្មួយខ្ញុំដឹងតែខ្លួនយ៉ាប់មួយហើយនេះ។

កៈ អូ៎!

ខៈ មកហ្នឹងហោស!

កៈ ចឹង..?

ខៈ ចា៎!

កៈ អើប្អូនគាត់ម៉ងហោសអោយគាត់..?

ខៈ ប្អូនណុងមែនប្អូនទេប្អូនខ្សែកុងចៀនប្ដីម៉ែខ្ញុំហ្នឹងហាសម៉ែសុកហ្នឹងហាសម៉ែក្មេកហ្នឹងហាស!

កៈ បាទអ៊ុំបាទ!

ខៈ ប៉ុនគាត់ទទួលស្គាល់ដូចតែបងប្អូនជីដូនមួយគាត់ចឹងដែរ។

កៈ អូ៎!

ខៈ ប៉ុន្តែយើងឪពុកគាត់តារីនមែនតាចៀនទេណាស់។

កៈ បាទអ៊ុំបាទ!

ខៈ អើហ្នឹងហើយ!

កៈ អូ៎ល្អ!

ខៈ ហ្នឹងហើយចា៎!

កៈ ចុះអ៊ុំគិតថាអ៊ុំរៀបអាពាហ៍ពិពាហ៍អស់រយះពេលប៉ុន្មានឆ្នាំហើយអ៊ុំ?

ខៈ អូ៎ខ្ញុំក្មួយហេ៎ក្មួយឯងជួយគិតអ៊ុំមើលណារ៉ែដាច់រួចឆ្នាំចិតសិបប្រាំបួនហ្នឹងហាស!

កៈ បាទអ៊ុំ!

ខៈ ណុងហាសឆ្នាំចិតសិបប្រាំបួនណុងហាស!

កៈ ចឹងមានន័យថាអ៊ុំការអស់សែសិបមួយឆ្នាំហើយ?

ខៈ ចា៎!

កៈ អូ៎យូរដែរហើយណោះអ៊ុំណោះ?

ខៈ ចា៎!

កះ ដោយសារអ៊ុំការហើយអ៊ុំមានកូនម៉ងរឺមួយអ៊ុំនៅទំនេរពោះសិន?

ខះ អត់ទំនេរទេក្មួយការហើយមានតែម៉ងហ្នឹង!

កះ អូ៎!

ខះ មាន។

កះ ចឹងមានន័យថាកូនទីមួយរបស់អ៊ុំហ្នឹងអាយុប៉ុន្មានទៅ?

ខះ ទេវាណុងសែមួយហលយទេហោ៎ស!

កះ សែមួយ?

ខះ សែមួយហើយមានចោលពោះណា។

កះ អូ៎បាទអ៊ុំចុះនៅពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍ហ្នឹងដូចជាអ៊ុំដូចជាពីមុនអ៊ុំស្គាល់គ្នាហើយនៅរឺមួយក៏អ៊ុំសុទ្ធ..?

ខះ អត់កូនហាសអត់សោះតាហ្នឹងហើយខ្ញុំជីដូនមួយបង្កើតហាសប៉ុនអត់ស្គាល់គ្នាទេ។

កះ អូ៎នៅស្រុកភូមិតានៅហ្នឹងអ៊ុំនៅកោះជ្រូក?

ខះ តានៅហ្នឹងខ្ញុំនៅកោះខ្ញុំមិនដែរស្គាល់តាហ្នឹងម៉េចផងតាហ្នឹងក៏មិនដែរស្គាល់ខ្ញុំម៉េចដែរ។

កះ អូ៎!

ខះ អត់ស្គាល់ទេ។

កះ ឪពុកម្តាយអ្នករៀបចំអោយហោស?

ខះ ម្តាយឪពុកអ្នករៀបចំអោយនឹកឃើញថាអើដាំដូងដាំស្លាម៉ែឪទុកដាក់ត្រឹមណានៅត្រង់ណុងទៅអត់ដឹងដូចក្មេងឥឡូវទេក្មួយ។

កះ បាទអ៊ុំបាទ!

ខះ អត់ដឹងទេ។

ក៖ អូ!

ខ៖ អើ!

ក៖ ប៉ុន្តែកាលជំនាន់ណុងមានជាថ្លៃបណ្ណាការថ្លៃជំនូនអត់អុំ?

ខ៖ អត់ទេខាងប្ដីខ្ញុំហ្នឹងគេអត់អោយខ្ញុំអីទេគេចេញមកទាំងអស់ម៉ងខ្ញុំគេម៉ាដូចថាយើងប្រាប់ភ្ញៀវប៉ុន្មានប្រាប់ទៅគេរ៉ាប់រងមួយចប់តែម៉ង។

ក៖ អូ!

ខ៖ ចាំខ្ញុំអត់មានអស់អីទេ។

ក៖ អូចឹងមានន័យថាគ្រាន់តែគេអត់..?

ខ៖ ស៊ីលើខាងគេទាំងអស់។

ក៖ គេអត់បង្គាប់ទេប៉ុន្តែគ្រាន់ថាគេផ្គាប់លើស៊ីនៅខាងគេទាំងអស់?

ខ៖ ចាំម៉ែខ្ញុំថាស៊ីលើគេទាំងអស់។

ក៖ អូ!

ខ៖ ហើយគេទិញខោអាវខោអីអោយលើខ្ញុំទៀត។

ក៖ អូ!

ខ៖ អើ!

ក៖ មានន័យថាតាពីមុនគាត់មានដៃរណោះ?

ខ៖ អត់មានទេអត់មានដៃរប៉ុនគាត់ត្រូវការម៉ែខ្ញុំគាត់មេម៉ាយ។

ក៖ អូ!

ខ៖ រួចប្ដីខ្ញុំណុងមេម៉ាយណុង។

កៈ បាទអ៊ុំ!

ខៈ ចឹងម៉ែខ្ញុំថាម៉ែខ្ញុំថាសុំស៊ីលើខាងប្រុសទាំងអស់ហើយហ្នឹងសុំខោអាវអោយកូនខ្ញុំមួយកំភ្លេ ម៉ែខ្ញុំថាចឹង។

កៈ អូ៎បាទអ៊ុំបាទប៉ុន្តែចឹងមានន័យថាយើងអត់ស្គាល់គ្នាពីមុនទេណេះអ៊ុំណេះ?

ខៈ អត់ស្គាល់ទេ។

កៈ អូ៎!

ខៈ ជីដូនមួយប៉ុនអត់ដែរស្គាល់គ្នាផង។

កៈ អូ៎បាទអ៊ុំចុះអ៊ុំគិតថាចឹងសំរាប់អ៊ុំការជំនាន់អ៊ុំរៀនហ្នឹងអ៊ុំរៀនបានប៉ុន្មានអ៊ុំរៀនបានថ្នាក់ទីបី ណេះអ៊ុំណេះ?

ខៈ ថ្នាក់ទីបី។

កៈ អ៊ុំធ្លាប់មានមិត្តភក្តិដែរស្និទ្ធិស្នាលធំធាត់មកជាមួយគ្នាអត់អ៊ុំដូចលក្ខណៈថាមិត្តភក្តិដើរ លេងអីជាមួយគ្នានៅរៀនអីចឹងហាសណាស់ធ្លាប់មានអត់អ៊ុំ?

ខៈ ទេក្មួយសម្លាញ់ហាសអត់ទេត្រង់ផ្លូវល្អណាស់មក..។

កៈ ប៉ុន្តែ..?

ខៈ ពីរៀនមកមកផ្ទះ។

កៈ ប៉ុន្តែលក្ខណៈយើងធ្លាប់មានមិត្តភក្តិលក្ខណៈយើងរៀនជាមួយគ្នាយើងអីដែរយើងធ្លាប់ លេងជាមួយគ្នានៅសាលាអីដែរមានអត់អ៊ុំ?

ខៈ មានៗ។

កៈ អូ៎!

ខៈ ប៉ុនមិនដូចសម័យឥឡូវហ្នឹងមិត្តភក្តិគេដើរលេងអីណារហោតរហូតអត់មានរៀនសូត្រទេ ណាស់។

កៈ បាទអ៊ុំ!

ខៈ មិត្តភក្តិស្គាល់គ្នាស្គាល់ប៉ុណ្ណឹងស្គាល់នៅក្នុងការរៀនសូត្រទេ។

កៈ អូ៎!

ខៈ មកវិញមកក្នុងផ្ទះយើងហើយ..!

កៈ រៀងខ្លួនទៅណោះអ៊ុំណោះ?

ខៈ រៀងខ្លួនហើយតាមម៉ែតាមឪហើយ!

កៈ អូ៎!

ខៈ ចាំ!

កៈ បាទអ៊ុំបាទ!

ខៈ វាខុសពីក្មេងសម័យឥឡូវហ្នឹងខ្លាំងហាសក្មួយអត់ដូចក្មេងសម័យហ្នឹងទេ។

កៈ ត្រូវអ៊ុំ!

ខៈ ចាំ!

កៈ ចុះអ៊ុំគិតថាស្រែចំការអ៊ុំធ្លាប់ធ្វើទេ?

ខៈ ចាំ!

កៈ ចំការអ៊ុំធ្លាប់ធ្វើចំការថ្នាំណោះអ៊ុំណោះ?

ខៈ ធ្លាប់ធ្វើចំការថ្នាំ។

កៈ ចុះស្រែអ៊ុំ?

ខៈ ស្រែក្មួយហាសដល់មកមានប្តីប្តីធ្វើស្រែ។

កៈ អូ៎!

ខ៖ អត់ប្រឹងចេះតែតែម៉ងគេមួយផ្លូនខ្ញុំក៏មួយផ្លូនដៃរកណ្តាប់។

ក៖ អ៊ូ!

ខ៖ ចាំចឹង..!

ក៖ ធ្វើស្រែប្រាំងអ៊ុំណេះ?

ខ៖ ខ្លាចគេនិយាយដើមយើងហាសប្រឹងហាស!

ក៖ បាទៗ!

ខ៖ ស្រែវស្សាក៏ធ្វើប្រាំងក៏ធ្វើចាំ!

ក៖ អ៊ូចឹងអ៊ុំធ្វើពីររដូវម៉ង?

ខ៖ ធ្វើពីររដូវហ្នឹងស្រុកហ្នឹងស្រុកយើងហ្នឹងខ្ញុំធ្វើពីររដូវហាស!

ក៖ ឥឡូវហ្នឹងហោស?

ខ៖ ចាំ!

ក៖ អ៊ូចឹងមានន័យថា..?

ខ៖ កាលខ្ញុំមានប្ដីហើយហ្នឹងធ្វើពីររដូវណាស់ក្មួយ។

ក៖ អ៊ូចឹងមានន័យថាអើអង្ករអីអត់សូវខ្វះហូបទេណេះអ៊ុំណេះមានជាប់រហូត?

ខ៖ អើវានៅចុងខែតិចតួចទៅណាស់ដាច់ប្រហែលមួយខែអីស្រូវស្រែយើងកំពុងតែចេញហើយ ចេញស្រុះអស់ហើយ!

ក៖ អ៊ូបាទ!

ខ៖ ប៉ុនយើងដាច់ពេលណុងតិចហ្នឹងហាស!

ក៖ បាទអ៊ុំបាទ!

ខ៖ ចាំចឹងយើងទិញអង្កមួយប៉េពីរប៉េអីចឹងវាដល់ហើយដល់ស្រូវយើងហើយក្មួយ។

ក៖ យើងទុំល្មម?

ខ៖ ចាំហ្នឹងហើយ!

ក៖ អូ៎បាទអ៊ុំ!

ខ៖ ចាំ!

ក៖ ចុះអ៊ុំគិតថាចឹងសំរាប់ទាក់ទងពីលក់ដូរវិញអ៊ុំធ្លាប់លក់ដូរពីមុនទេអ៊ុំ?

ខ៖ ធ្លាប់តើក្មួយ។

ក៖ អ៊ុំធ្លាប់លក់អីខ្លះអ៊ុំ?

ខ៖ ធ្លាប់ដូចថាឃើញចេះប្ដីយើងធ្វើនេះទៅស្រែអីចឹងទៅគាត់មនុស្សប្រុសគាត់ដើរប៉ាវាគាត់ទៅលេងភ្លេងការភ្លេងអីចឹងទៅតាមអកកេសលេងភ្លេងការហោស រួចខ្ញុំនៅផ្ទះមើលអាចេកណាទុំអីចឹងទៅខ្ញុំអាំងអន្សមអាំងអីលក់ខ្ញុំចេះដែរតើក្មួយ។

ក៖ អូ៎!

ខ៖ អាំងអន្សមអាំងអីចឹងទៅឃើញចេកទុំចេកអីខ្ញុំធ្វើលក់ទៅ។

ក៖ អូ៎!

ខ៖ ចាំដើម្បីចិញ្ចឹមកូនចិញ្ចឹមចៅព្រោះកូនតាណុងបួននាក់ហើយណាស់កូនហាស!

ក៖ បាទអ៊ុំបាទ!

ខ៖ តាណុងមេម៉ាយកូនបួនហាស!

ក៖ អូ៎!

ខ៖ បើក្មួយឯងនៅហ្នឹងសឹងស្គាល់ដែរទេហី?

ក៖ ខ្ញុំអត់ដឹងដែរ។

ខ៖ ចឹងទេហោសអ៊ំពួកវាណុងអាយុច្រើនៗដែរតើអើមិនស្គាល់ណោះ។

ក៖ ខ្ញុំទើបតែសាមហ្នឹង?

ខ៖ អើពួកវាហ្នឹងបែបចូលសែអិហើយ!

ក៖ អ៊ំ!

ខ៖ ប៉ុនវាងាប់អីហើយឥឡូវហោស!

ក៖ ចឹងហោស?

ខ៖ ចាំមកចិញ្ចឹមខ្ញុំចិញ្ចឹមកូននាក់ហាសក្មួយពិបាកវេទនាហាសណាស់។

ក៖ ចឹងមានន័យថា..?

ខ៖ ប៉ុនខ្ញុំខ្ញុំលរាប់រៀបច្រើនតាចឹងចាំ!

ក៖ ចឹងមានន័យថាអ៊ុំមានកូនប្រាំនាក់ផ្សេងហើយតាមានកូនបួននាក់ផ្សេងទៀត?

ខ៖ បួននាក់ហាសកូនដើមគាត់បួននាក់ណាស់។

ក៖ ចឹងកូនប្រាំនាក់ហ្នឹងកូនរបស់អ៊ុំផ្សេងទៀតអ៊ំ?

ខ៖ ចាំខ្ញុំយកតាហ្នឹងបានប្រាំ។

ក៖ អ៊ំ!

ខ៖ ប៉ុនកូនគាត់មុនណុងបួននាក់។

ក៖ ចឹងតាកូនប្រាំបួននាក់ហើយចឹង?

ខ៖ ប្រាំបួន។

ក៖ អ៊ំកូនក៏ច្រើន?

ខ៖ ចាំ!

កៈ ប៉ុន្តែអើចង់និយាយថាទាក់ទងពីកូនតាអ៊ុំនៅតែរាប់រកដូចកូនចៅចឹងអ៊ុំហេស?

ខៈ រាប់រកតើក្មួយមាននរណាអោយវាស៊ី។

កៈ អូ៎!

ខៈ មានតែខ្ញុំហើយជាម្ដាយចុងណុងមើលការខុសត្រូវហ្នឹង!

កៈ បាទអ៊ុំបាទ!

ខៈ បាយទឹកអាលិបចំណីហ្នឹង!

កៈ អូ៎!

ខៈ រួចច្រើនតែជីដូនវាប្រចេះអីចឹងទៅហែងឡើងស៊ីបាយរួចទៅដើរមកផ្ទះអញ់អីមកយើងមានបានប្រើអីវា យើងធ្វើតែខ្លួនយើងបុកស្រូវបុកអង្ករអីទៅតែខ្លួនយើងខ្ញុំនៅជាមួយម៉ែខ្ញុំខ្ញុំមានចេះអីដល់ពេលមានប្ដីខ្ញុំចេះ។

កៈ អូ៎!

ខៈ ស្រូវអង្ករខ្ញុំបុកខ្ញុំអ៊ុំខ្ញុំស្ដីក្មួយខ្ញុំចេះចាំ!

កៈ ប៉ុន្តែអើ..?

ខៈ មើល។

កៈ ប៉ុន្តែអ៊ុំឥឡូវកូនដើមគាត់នៅណាទៅ?

ខៈ កូនដើមវាងាប់អស់ពីរហើយនៅពីរមួយនៅភូមិថ្មីមួយណោះទៅនៅអីស្ដីហោស!

កៈ អូ៎!

ខៈ ចាំ!

កៈ ប៉ុន្តែគាត់នៅតែទាក់ទងមកយើងចឹង?

ខៈ ទាក់ទងមានអីចាំ!

កៈ អ៊ុំល្អអ៊ុំ!

ខៈ ចា៎!

កៈ ចុះអ៊ុំគិតថាចឹងទាក់ទងពីចិញ្ចឹមសត្វវិញអ៊ុំធ្លាប់ចិញ្ចឹមសត្វពីមុនទេអ៊ុំដូចមាន់ ទា ជ្រូក គោ ក្របី?

ខៈ មានចិញ្ចឹមអ៊ុំចិញ្ចឹមណាស់ក្មួយបើមិនចិញ្ចឹមការងាររបស់ទាំងហ្នឹងយើងបានអីជួយផ្គល់។

កៈ ត្រូវអ៊ុំត្រូវ!

ខៈ បើយើងអ្នកស្រែអ្នកចំការអ៊ុំមិនស្ដាយប៉ុនអ៊ុំចាស់ណាស់ អ៊ុំសុំសិល្ប៍ហើយឥឡូវអ៊ុំស្ដាយតើស្ដាយជ្រូកបានថ្លៃហាសណាស់កាលអ៊ុំចិញ្ចឹមថោកៗហាសណាស់។

កៈ បាទអ៊ុំ!

ខៈ អ៊ុំចិញ្ចឹមណោះលីដើមចេកពីដើមអំពិលអីមកហោស!

កៈ អ៊ុំ!

ខៈ ទំនេរទៅទិញដើមចេកអើកាលណុងអ៊ុំមិនទាន់មានកង់អីណាជិះត្រឹមត្រូវសុទ្ធតែលីណាស់ក្មួយហាស!

កៈ បាទអ៊ុំ!

ខៈ រួចយកមកហាន់យកមកបុកអោយជ្រូកស៊ីហាសរួចអ៊ុំមានអីអើយកមកអារបស់ហ្នឹងហើយដែរយើងដោះស្រាយរឿងជីវិតរបស់យើងដូចជាអង្ករជាទឹកត្រីសព្វបែបសព្វយ៉ាងហ្នឹងទិញស្អីៗហ្នឹងបានសត្វហ្នឹងហើយបានលក់ទៅហោស!

កៈ អ៊ុំ!

ខៈ ចា៎អ៊ុំចិញ្ចឹមហាសអ៊ុំចិញ្ចឹមហាសក្មួយ។

កៈ បាទអ៊ុំបាទ!

ខៈ ចិញ្ចឹមជ្រូក។

កៈ ចុះ..?

ខៈ ចិញ្ចឹមម្តងប្អូនហ្នឹងហាសផ្ទះហ្នឹងប្អូន។

កៈ អូ៎បាទអ៊ុំចុះអ៊ុំគិតថាតាំងពីក្មេងរហូតមកដល់ឥឡូវការងារអីគេខ្លះដែរអ៊ុំធ្លាប់ធ្វើរហូតមកដល់ឥឡូវអ៊ុំ អ៊ុំធ្លាប់ធ្វើការងារអីគេខ្លះពីក្មេងកាលអ៊ុំនៅជាមួយឪពុកម្តាយអ៊ុំធ្លាប់ធ្វើតែចំការថ្នាំហ្នឹងរឺមួយ..?

ខៈ ចាំ!

កៈ ក៏ធ្វើអីផ្សេងទៀតអត់?

ខៈ អត់ទេខ្ញុំធ្លាប់ធ្វើតែចំការថ្នាំទេតែប៉ុណ្ណឹងទេ។

កៈ អូ៎ដល់ពេលអ៊ុំមកមានក្រុមគ្រួសារមក..?

ខៈ ដល់មានប្តី។

កៈ អ៊ុំចេះធ្វើស្រែធ្វើអីទៀត?

ខៈ ចេះធ្វើស្រែធ្វើចំការហ្នឹងក៏ចេះធ្វើដែរបើយើងអ្នកចំការហើយ!

កៈ អូ៎បាទអ៊ុំបាទ!

ខៈ បើចេះរកស៊ីអាលក់អាដូរហ្នឹងចេះតើអ៊ុំចេះតើ!

កៈ ចេះគ្រប់សព្វម៉ងហោស?

ខៈ អ៊ុំចេះរកស៊ីអារកស៊ីអាលក់អាដូរចិញ្ចឹមកូនគេមុនៗហ្នឹង!

កៈ បាទអ៊ុំ!

ខៈ អ្នកឯងដឹងខ្ញុំក៏ដឹងទៅអ្នកឯងមិនដឹងខ្ញុំក៏ខ្ញុំអត់ថាអីដែរខ្ញុំចិញ្ចឹមគេហាសស្រុកវែដាច់មកក្មួយមានអី មានតែអង្ករតិចតួចហ្នឹងបាយលាយពោតបាយលាយក្តួចហ្នឹង!

កៈ អូ៎!

ខ៖ ចាំ!

ក៖ បាទអ៊ុំចុះអ៊ុំគិតថាជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរអីគេខ្លះទៅអ៊ុំតាំងពីក្មេងរហូតមកដល់ឥឡូវហោស?

ខ៖ ផ្លាស់ប្តូរហោសក្មួយផ្លាស់ប្តូរអ៊ុំដល់ចាស់ទៅអ៊ុំដូចរៀងស្រួលតិចដែរ ព្រោះទង្វើរបស់អ៊ុំកាលអ៊ុំនៅក្មេងអ៊ុំដឹងកូនដឹងចៅមើលចិញ្ចឹមថែរក្សាគេដល់អ៊ុំចាស់ទៅកូនចៅក៏វាជួយយើងវិញតាមសមត្ថភាពរបស់វាក្មួយ។

ក៖ បាទអ៊ុំ!

ខ៖ វាមានទៅវាបន្តក់មកវាគ្មានទេវានៅទៅចឹងទៅ។

ក៖ អូ៎!

ខ៖ បានដូចថាកូនវាគោរពម៉ែឪចឹងដែរ។

ក៖ បាទអ៊ុំបាទ!

ខ៖ ចាំព្រោះខ្ញុំពីក្មេងមកខ្ញុំហាត់ណាស់ក្មួយខ្ញុំហាត់។

ក៖ អូ៎!

ខ៖ ចាំ!

ក៖ ចុះអ៊ុំគិតថាចឹងទាំងជីវភាពទាំងសុខភាពក្រុមគ្រួសារអីឥឡូវម៉េចដែរអ៊ុំ?

ខ៖ ជីវភាពហោស?

ក៖ បាទ!

ខ៖ ជីវភាពរាល់ថ្ងៃហ្នឹងមានអីក្មួយបានកូនចិញ្ចឹមហើយ!

ក៖ អូ៎!

ខ៖ ប៉ុនសុខភាពអ៊ុំអាឈឺ។

ក៖ ដោយសារអ៊ុំរៀងចាស់ដែរហើយណោះអ៊ុំ?

ខ៖ ចាំឈឺតើ!

ក៖ អូ៎!

ខ៖ ទៅជួសឈោមជួសអីមើលហ្នឹងសុំលុយកូនជួសឈោមទៅអោយដឹងពីរោគាំរបស់យើងទៅណាស់។

ក៖ បាទអ៊ុំ!

ខ៖ ចាំឈឺអ៊ុំទៀត។

ក៖ អូ៎បាទអ៊ុំ!

ខ៖ ចាំ!

ក៖ ចុះអើទាក់ទងពីម្ហូបអាហារភាគច្រើនអ៊ុំចូលចិត្តហូបម្ហូបអីគេអ៊ុំ?

ខ៖ ខ្ញុំក្មួយអើយម្ហូបខ្មែរយើងហ្នឹងវាគ្មានទៅណាគួរអស្ចារ្យណាច្រើនសព្វបែបយ៉ាងទេមានតែសំលកកូរ សំលប្រហើរ សំលម្ជូរយួន ម្ជូរគ្រឿងអីហ្នឹងអ៊ុំចេះធ្វើទាំងអស់។

ក៖ អូ៎!

ខ៖ ថ្ងៃណាអ៊ុំចង់ចឹងទៅអ៊ុំធ្វើទៅបើថាអោយចូលចិត្តមុខអីមួយអ៊ុំធម្មតា។

ក៖ បាទអ៊ុំ!

ខ៖ បើអ៊ុំឃ្លានមុខអីអើថ្ងៃហ្នឹងជូនឃ្លានទឹកគ្រឿងហាសណាស់អោយឃ្លានធ្វើទឹកគ្រឿងស៊ីទៅអើថ្ងៃហ្នឹងអញ់ដូចឃ្លានសម្លកកូរធ្វើតាមហ្នឹងទៅដូចថាអ៊ុំនឹកហ្នឹងហាស!

ក៖ នឹកឃើញអីធ្វើណុងទៅ?

ខ៖ អើអញ់ដូចឃ្លានឆាខ្ញីហាសណាស់អើទៅទិញយកមកធ្វើស៊ីចឹងទៅណាស់កូន។

ក៖ អូ៎ស្រួលណោះអ៊ុំ?

ខ៖ ចាំតាមយើងនឹកឃើញទេ។

ក៖ បាទអ៊ំ!

ខ៖ បើអ៊ុំចេះធ្វើតែម្ហូបខ្មែរហ្នឹងទេក្មួយ។

ក៖ អូ៎!

ខ៖ ចាំ!

ក៖ ប៉ុន្តែអើសព្វថ្ងៃហ្នឹងអ៊ុំនៅប៉ុន្មានអើនៅជាមួយចៅបីនាក់ហ្នឹងកូនម្នាក់?

ខ៖ ចៅបីហ្នឹងកូនពិការហ្នឹងមួយក្មួយ។

ក៖ អូ៎នៅតែប្រាំនក់ហ្នឹងទេហោស?

ខ៖ ចាំទៅហើយទាំងឈឺទាំងជាចៅឈឺទៅទៅហើយយកទៅពេទ្យទៅអីទៅអន្ត្រាក់ៗហាត់ មកវិញមើលរៀបចំបាយទឹកចៅអើចៅឯងកុំអោយតែឈ្លោះគ្នាណាស់អើស៊ីលើយាយនៅស្ងៀមយាយធ្វើអោយចៅឯងញ៉ាំ អើខោអាវស្លៀកពាក់ទៅទុកម្ដុំទៅយាយបោកអោយកុំអោយតែចៅឈ្លោះចៅខំប្រឹងរៀនប្រដៅចៅតែប៉ុណ្ណឹងហាសក្មួយ។

ក៖ អូ៎!

ខ៖ ប្រឹងតែរៀនល្ងង់ពិបាកណាស់ចៅ។

ក៖ បាទយាយត្រូវ!

ខ៖ ចេះបានស្រួលណាស់ចៅណាស់។

ក៖ បាទ!

ខ៖ ចៅឯងយាយសួរណោះអាធ្វើផ្លូវថ្នល់ណុងហ៊ានអាគេធ្វើការក្នុងម៉ាស៊ីនត្រជាក់យកមួយណាសួរវាចឹងណាស់។

ក៖ អូ៎បាទ!

ខ៖ ចាំហ៎ខ្ញុំនៅត្រជាក់អើបើនៅត្រជាក់ប្រឹងទៅអើធ្វើថ្នល់ហាសគេធ្វើហាលថ្ងៃហាសក្ដៅកាលណាបានកាលល្អកាលណុងហាសពីមុនធ្វើទឹកហ្នឹងភ្លើងហ្នឹងទឹកភ្លៀងហ្នឹងមេឃស្រទុំរលឹមទេណាស់ចៅ។

ក៖ បាទអ៊ុំបាទ!

ខ៖ ថ្នល់ចាក់ប៉ាតុងណុងណាស់។

ក៖ បាទអ៊ុំ!

ខ៖ និយាយពន្យល់វាចឹង។

ក៖ អូ៎ល្អចឹង!

ខ៖ ចាំ!

ក៖ ចុះអ៊ុំគិតថាចឹងសំរាប់ដូចជាល្បែងប្រជាប្រិយ៍អ៊ុំធ្លាប់លេងល្បែងប្រជាប្រិយ៍អីពូនមុនអ៊ុំដូចលក្ខណៈបោះអង្គុញ ចោលឈូង លាក់កន្សែង ទាញព្រាត់?

ខ៖ ក្មួយអើយអ៊ុំមួយជំនាន់វ៉ៃដាច់ហាស វ៉ៃដាច់ហ្នឹងមិនស្រុកវាសន្តិភាពគ្នាពួកទាហ៊ានបានជ័យជំនះហោស!

ក៖ បាទអ៊ុំ!

ខ៖ លេងរាំលេងរណុងជួសអាបោះអង្គុញបោះអីហ្នឹងហាសបោះអង្គុញចឹងទៅអាអង្គុញជួសអីចឹងទៅ អូយអ៊ុំសប្បាយអាមួយជំនាន់ណុងអាទើបមកឆ្នាំណុងសប្បាយៗហ្នឹងបោះអង្គុញបោះអីហ្នឹងបោះគ្រាប់អ៊ុំមិនសូវចូលចិត្តទេ។

ក៖ អូ៎!

ខ៖ ចាំបោះអង្គុញបោះអីហៅណោះបោះឈូងបោះអីហ្នឹងហាស អើចោលទៅចំអ្នកណាអីហ្នឹងអីចឹងទៅពង្រាត់ទៅអីចឹងនាំគ្នាតែប៉ុនណុងរួចឥឡូវអ៊ុំអស់សប្បាយអីហើយ!

ក៖ ចាស់ហើយណោះអ៊ុំ?

ខ៖ ចាស៎ហើយលេងបានតែម្ដងណុងសប្បាយសប្បាយផ្ដាំចាស់សប្បាយមែនសប្បាយៗដល់ថ្នាក់ស្អកខ្លួន។

ក៖ អូ៎!

ខ៖ អើឥឡូវលែងហើយក្ដួយដល់ស្រុកស្រួលបួលទៅអ៊ុំអត់មានទេធម្មតា។

ក៖ បាទអ៊ុំ!

ខ៖ ធម្មតា។

ក៖ ចុះអ៊ុំទាក់ទងពីអើដូចជាចឹងច្រៀងក៏អ៊ុំអត់សូវចូលចិត្តដែរណោះអ៊ុំណោះ?

ខ៖ ចូលតើចូលចិត្តតើ!

ក៖ អ៊ុំចូលចិត្តច្រៀង?

ខ៖ ចា៎!

ក៖ ប៉ុន្តែអត់សូវចូលចិត្តរាំ?

ខ៖ ចា៎ច្រៀងចូលចិត្តអាលែងអាចំរៀងសងឌីម៉ង។

ក៖ អូ៎!

ខ៖ កំសត់ៗល្អមើល។

ក៖ ឥឡូវហ្នឹងហោសអ៊ុំ?

ខ៖ ចា៎ចូលចិត្តតើចូលចិត្តអើកូនបើកចឹងទៅយើងក្រេបជញ្ជក់ពាក្យក្នុងន័យចំរៀងហ្នឹងទៅកំសត់ហាស!

ក៖ បាទអ៊ុំបាទ!

ខ៖ រួចអាកូនថាម៉ែមិនដឹងស្អីទេចំរៀងសោះហីចំរៀងគេមានអត្ថន័យគេអ្នកនិពន្ធមកវាសុទ្ធតែការពិតហាសម៉េចនិយាយចឹង។

ក៖ បាទអ៊ុំត្រូវចុះអើដូចជាល្ខោនយីកេអាយ៉ៃអ៊ុំចូលចិត្តមើលទេអ៊ុំ?

ខ៖ ចូលចិត្តមើលតើក្មួយមើលតើ!

ក៖ ឥឡូវនៅតែចូលចិត្តចឹង?

ខ៖ ឥឡូវហ្នឹងៗបើគ្មានល្ខោនណាមកលេងផងបានអីចូលចិត្ត។

ក៖ ល្ខោន?

ខ៖ ល្ខោនពីដើមពិរោះហាសណាស់ក្មួយហាសមិនដូចឥឡូវទេពីដើមពិរោះណាស់រួចទៅអ៊ុំ ចូលចិត្តណាស់អង្គុយជិតអ្នកលេងតែសើច នៅអង្គុយជាមួយអ្នកដែរអត់ចេះសើចហ្នឹងងងុយ ដេកបើនៅជិតជាមួយអ្នកគេចេះតាមដានរឿងណុងអ្នកសើចណុងអត់ទេអត់ងងុយដេកទេ មួយយប់ទាល់ភ្លឺក៏ល្អមើលដែរ។

ក៖ អ៊ូ!

ខ៖ អើអ្នកសើចគេសើចក្អាកក្អាយវាមានអារម្មណ៍ភ្លេចងងុយដេកហាស!

ក៖ បាទអ៊ុំ!

ខ៖ អើមានអារម្មណ៍អត់ងងុយដេកទេ។

ក៖ ចុះអ៊ុំទាក់ទងពីចឹងអ៊ុំលក្ខណៈថាអ៊ុំសុំសិល្ប៍នៅ?

ខ៖ ខ្ញុំសុំសិល្ប៍ហើយតើក្មួយ។

ក៖ ចឹងហោសអ៊ុំ?

ខ៖ ចាំមកហ្នឹងភ្លាមខ្ញុំសុំសិល្ប៍ភ្លាម។

ក៖ អ៊ូឥឡូវសិល្ប៍ប៉ុន្មានហើយអ៊ុំ?

ខ៖ អើខ្ញុំសុំសិល្ប៍ប្រាំចុះក្មួយបានសិល្ប៍ប្រាំបីណា។

ក៖ អ៊ូ!

ខ៖ អើសិល្ប៍អើបើកូនចៅសុទ្ធតែចឹងពឹងពាក់លើយើងទាំងអស់ហ្នឹងក្មួយឯងទៅរកសិល្ប៍ណាច្រើន។

ក៖ អូ៎បាទ!

ខ៖ បានត្រឹមសិល្ប៍ប្រាំបានហើយគ្រាប់យើងបានមកថារំងាប់ដូចថារំងាប់ចិត្តយើងអោយស្ងប់ៗកុំចង់បានអីហួសដូចថាកុំឃើញគេមានគេបានយើងខ្វាករខ្វាអីគឺអ៊ុំស្ងប់។

ក៖ បាទអ៊ុំបាទ!

ខ៖ ស្ងប់អស់ហើយអត់អីទេ។

ក៖ អូ៎បាទអ៊ុំ!

ខ៖ អើដើម្បីសុខភាពខ្លួនយើងដើម្បីគ្រួសារយើងរកសេចក្ដីល្អៗទៅចង់នរណានិយាយថាម៉េចនិយាយទៅ។

ក៖ ត្រូវអ៊ុំត្រូវ!

ខ៖ អត់ខ្វល់កុំអោយតែពេលស៊ីយើងទៅសួររកគេអត់ខ្វល់ពីអ្នកឯងនិយាយពីអញ់ថាម៉េចនិយាយទៅអត់ខ្វល់។

ក៖ អូ៎បាទអ៊ុំចុះអ៊ុំទាក់ទងពីអើចឹងអ៊ុំមានបងប្អូនកូនចៅណារីមួយក៏កូនក្មួយណាដែរចេះលេងឧបករណ៍ភ្លេងអត់អ៊ុំដូចលក្ខណៈថាភ្លេងសៀម ភ្លេងខ្មែរភ្លេងពិនពាត?

ខ៖ ទេដូចគ្មានទេ។

ក៖ អត់មានទេណោះអ៊ុំ?

ខ៖ អត់មានទេខ្ញុំហោសអត់មានទេ។

ក៖ អូ៎បាទអ៊ុំចុះអ៊ុំអើទាក់ទងពីអើផ្ទះរបស់អ៊ុំមានលក្ខណៈបែបណាអ៊ុំកាលអ៊ុំនៅជាមួយឪពុកម្ដាយផ្ទះម៉េចដល់ពេលឥឡូវអ៊ុំមកនៅជាមួយកូនចៅផ្ទះបែបណាអ៊ុំ?

ខ៖ ខ្ញុំផ្ទះឪពុកម្ដាយរបស់ខ្ញុំផ្ទះក្បឿងដែរ។

កៈ អុំ!

ខៈ ប៉ុនផ្ទះពីដើមមិនធ្វើដូចយើងសម័យឥឡូវចេញម៉ូតទេណាស់។

កៈ បាទអុំ!

ខៈ ផ្ទះពីដើមសំបូរផ្ទះរោងដោល។

កៈ អុំ!

ខៈ អើផ្ទះពីដើមហាសផ្ទះបុរាណ។

កៈ បាទអុំបាទ!

ខៈ ប៉ុនសសរល្អៗណាស់សសរពីដើមសសរផ្ទះម៉ែខ្ញុំដូចសសរវិហារៗចឹង ចាំនៅកោះហាស នៅស្រុកកោះណុងហាស!

កៈ បាទអុំ!

ខៈ ចាំមានជីវភាពដូចថាខ្ញុំកើតមកដូចវាទំនងសមរម្យមួយដែរ ប៉ុនដល់ខ្ញុំមានប្តីប្រវេកពិបាក ដែរក្មួយប្រវេកពិបាកហាសពិបាកមែន។

កៈ អុំ!

ខៈ ចិញ្ចឹមកូនចិញ្ចឹមចៅគេមិនគេគេច្រើនតិចទៀនអោយយើង យើងម្តាយចុងមិនថាយើងល្អ ដូចម៉ែគេទេណាស់ក្មួយហាស!

កៈ បាទអុំបាទ!

ខៈ ភាពជាម្តាយចុងម៉ែបង្កើតទោះជេរថាវ៉ៃប៉ុណ្ណាក៏ម៉ែគេគ្មាននរណានិយាយដែរជឿទេក្មួយ?

កៈ បាទត្រូវ!

ខៈ អ្នកណានិយាយពីយើងម៉ែបង្កើតបានទេណាស់។

កៈ បាទៗ!

ខ៖ ម៉ែចុងមិនបាច់ដល់វ៉ៃទេត្រឹមតែនិយាយហែងរឹងណាស់ចេះៗក៏គេនិយាយដើមយើងដែរណាស់ក្មួយ គេថាយើងចិត្តមិនបានហ្នឹងកូនគេចៅគេហាសក្មួយឯងជឿទេ?

ក៖ បាទត្រូវ!

ខ៖ អើមានមានភាពពិបាកដែរខ្ញុំពិបាកធ្វើម៉ែចុងគេខ្ញុំពិបាកហាសណាស់ក្មួយ។

ក៖ បាទអ៊ុំបាទ!

ខ៖ ម៉ែខ្ញុំចែកមកចឹងខ្ញុំអើយក្មួយខ្ញុំនិយាយអោយអស់ ខ្ញុំនិយាយអោយក្មួយឯងអោយអស់ណោះសារ៉ុងមានតែមួយហ្នឹងទេណាស់មានតែមួយទេណាស់បោកទឹកអណ្តូងហោសនោះអណ្តូងទីនេះពីដើមហាស ខ្ញុំយកស្អីៗទៅដងទឹកដាក់ទឹកចឹងទៅខ្ញុំបោកប៉ុនសារ៉ុងខ្ញុំខ្ញុំបោកមុនហាសណាស់ខ្ញុំបោកដាក់ហាលថ្ងៃចឹងរួចខ្ញុំបោកញីៗញួកអីផ្សេងៗលាងនេះលាងនោះផ្សេងៗទៅ មើលតែសារ៉ុងខ្ញុំស្ងួតបានយកសារ៉ុងស្ងួតណុងមកស្លៀកវិញហាសក្មួយហាស!

ក៖ អូ៎!

ខ៖ ខ្ញុំកំសត់ហាសចាំប៉ុនកំសត់ខ្ញុំអត់ភ្លេចទេប្រវត្តិខ្ញុំហោសកំសត់ណាស់ក្មួយ។

ក៖ បាទអ៊ុំបាទ!

ខ៖ ប៉ុនខ្ញុំបានម៉ាសមរម្យមកសព្វថ្ងៃនេះបានកូនខ្ញុំមីស៊ីវខេងហ្នឹងទេណាស់មកជួយលុយដែរមានលុយតែកំលាំងអ៊ុំផ្សំគ្នាបានជាផ្ទះហ្នឹងមួយទៅ។

ក៖ អូ៎!

ខ៖ បើសិនជាអ៊ុំហ្នឹងដូចថាអូ៎មិនចង់ធ្វើទេផ្ទះហោសទុកលុយចាយ ទុកលុយធ្វើមាសធ្វើប្រាក់ហោសអ៊ុំក៏អត់មានផ្ទះនៅដែរ។

ក៖ ក៏អត់មានផ្ទះនៅដែរ?

ខ៖ ណាស់ក្មួយ។

ក៖ បាទត្រូវអ៊ុំ?

ខ៖ និយាយតាមត្រង់។

ក៖ បាទ!

ខ៖ ចឹងមិនអោយបាត់លុយកូនមិនអោយបាត់លុយកំលាំងអ៊ុំដែរអ៊ុំខំរកស៊ីមកហ្នឹងសឹកបាតដៃអស់ហើយក្ស័យណាស់ ចឹងលុយហ្នឹងផ្សំគ្នាបានផ្ទះហ្នឹងមួយទុកដំណែលអោយចៅៗមើលថាយាយអញ់តាអញ់មានផ្ទះទុកអោយអញ់ដែរ។

ក៖ អ៊ំបាទអ៊ុំត្រូវ!

ខ៖ ចាំ!

ក៖ ចុះអ៊ុំគិតថាចឹងអាហ្នឹងផ្ទះហ្នឹងយើងហ៊ុនគ្នាជាមួយកូនមួយជាអីណោះអ៊ុំ?

ខ៖ ចាំជាមួយកូនកូនគេជួយលុយប៉ុណ្ណឹងប៉ុនកូនគេមិនមកនៅទេគេធ្វើហ្នឹងគេធ្វើអោយម៉ែនៅហើយ!

ក៖ បាទអ៊ុំ!

ខ៖ ម៉ែមកនៅស្រុកវិញទៅម៉ែកុំនៅហ្នឹងគេគេមិនអោយអីម៉ែដែរម៉ែនៅធ្វើអីទៀត។

ក៖ ត្រូវអ៊ុំ!

ខ៖ ចាំ!

ក៖ អត់មានអត់ដែរថាគាត់ចង់ធានាយើងទៅនៅជាមួយគាត់នៅបារាំងអីអត់ទេ?

ខ៖ ណោះប៉ាស្ព័រធ្វើរួចស្រេចប៉ុនខ្ញុំមិនទៅ។

ក៖ កើតអីអ៊ុំ?

ខ៖ ប៉ាស្ព័រខ្ញុំដល់អាយុដល់កំណត់ហួសកំណត់ខែឆ្នាំម្ភៃប្រាំហោស!

ក៖ អ៊ំ!

ខ៖ ហោសស្អីគ្មានពីណាមើល។

កៈ អ៊ូ!

ខៈ កូនពិការនោះពីណាមើល។

កៈ ចឹង!

ខៈ ទៅសប្បាយភ្នែកហ្នឹងកូនមាំទាំធ្វើអីកូនមាំទាំហ្នឹងចង់អោយម្ដាយទៅឃើញប្រទេសគេណាស់។

កៈ ត្រូវអ៊ុំត្រូវ!

ខៈ ប៉ុនម្ដាយនេះដាច់ចិត្តក្មួយនេះខ្ញុំយំហាសខ្ញុំយំរាល់យប់ហាស ក្មួយពិបាកហាសណាស់ពិបាកណាស់គ្នាលើកជើងលើកដៃមិនរួចរួចទៅវិញ្ញាណគ្នាមើលឃើញសព្វគ្រប់អស់ហើយ អើវាធូន់ខ្លួនវាយូរឆ្នាំណាស់ហើយហោស!

កៈ បាទយាយ!

ខៈ ម៉ែអើម៉ែវាមកទៀតហើយហោសវាអោយឃើញមិនថាខ្មោចអីទេវាមើលឃើញថាមនុស្សហាស!

កៈ បាទ!

ខៈ ខ្ញុំថាដេកទៅគ្មានមនុស្សណាមកធ្វើអីកូនឯងទេកូនមានតែវិញ្ញាណកូនឯងទេធូន់ខ្លួនកូនឃើញចេះចុះហោស!

កៈ បាទអ៊ុំ!

ខៈ អ៊ូឯងមើលវាស្អាតតើថាមកអោយឃើញថាខ្ញុំហ្នឹងកខ្វក់ណាស់ស្អុយណាស់ ខ្ញុំថាគេថាម៉េចថាទៅអ្នកណាថាអ្នកណាជេរអោយធ្លាក់ទៅលើគេទៅណាស់កូនណាស់បណ្ដុះៗទៅគេទៅ។

កៈ បាទអ៊ុំបាទត្រូវ!

ខៈ អោយកូនបានចូលទៅក្នុងរូបរាង្គកាយរបស់កូន កូនពិការមែនពិតប៉ុន្តែកូនកុំអោយខ្លួនកូនឈឺដុនដាបទៅទៀតអោយកូនសុខភាពកូនអោយល្អម៉ែរាល់ថ្ងៃម៉ែសុំចិត្តកូនអោយកូនប្រឹងស៊ី

ប្រឹងចុកម៉ែអត់មានថាអីទេ ម៉ែអោយតែកូនបានអាយុវែងម៉ែអត់ចង់អោយកូនទៅណាឆ្ងាយពីកូនទេធ្វើម៉េចអាហ្នឹងកម្មម៉ែតើ!

កៈ បាទអ៊ុំ!

ខៈ អើកម្មខ្ញុំហាសអើម៉ែអើយមកទៀតហើយម៉ែគប់ណោះមើលវាគប់ហោសអើមានពីណាគប់។

កៈ អូ៎!

ខៈ គេអោយឃើញហ្នឹងហាសគេអោយឃើញ។

កៈ បាទអ៊ុំបាទ!

ខៈ ឈឺម្ដងហើយតើឈឺហ្នឹងឈឺងាប់ហើយគេយកទៅហើយតើ ខ្ញុំតេទៅកូនខ្ញុំទៅម៉ែវាហ្នឹងហោសម៉ែវាហ្នឹងហោសគេចេះលេងអាហ្វេសបុគគេចេះស្អីផ្ញើរសារម៉េចស្អីគេទៅ បងប្អូនគេដឹងទាំងអស់មកសំរូលវិញបងៗអើមីបារាំងអើបងបើមានជាតិក្រោយខ្ញុំសុំធ្វើប្អូនបងទៀតណាជាបងប្រឹងឡើងអីឡើងអីចឹងៗ អើបងចាំខ្ញុំអាលែងសង្ឃកទានអោយបងជាទៅអាខ្ញុំថាលែងប្រពន្ធអីហ្នឹងគេជួយជ្រុំជ្រែងអើអញ់អាទិត្យហាសអាទិត្យប្រឹងឡើងណាស់អូនអូនេងកុំទៅណាមកណាបងគាំទ្រអូនឯង អូនឯងប្រឹងឡើងអីឡើងណាស់ចាំបងហ្នឹងមីសុខខេងគេធ្វើបុណ្យជូនអូនឯងអីឯងកុំតូចចិត្តថាអូនឯងគ្មានបងប្អូនគាំទ្រាំគេគាំទ្រអូនឯងតើ ប្រឹងឡើងអូនប្រឹងប្រឹងបានជាថាគេមកយកហើយគេមកហើយប៉ុនមានយាយមួយថាកុំយកគេតាពីសតាពាសត្បិតតែគេពិការទុកជីវិតគេវិញ។

កៈ អូ៎!

ខៈ បានគេយកទៅមែនហាសអ៊ុំទៅជិតដេកចឹងហេសទៅហ៎លោកកូនៗថាម៉ែៗម៉ែកុំយំម៉ែៗខ្ញុំរត់ហៅហៅអ្នកជិតខាងអីហ្នឹងមករួចទៅបានស្វាបសោរអើយមើលទៅបែបទៅមុខហើយ អើរួចមើលម៉េចទៅយើងស្ងាត់ហាសអ្នកស្រុកយើងប៉ុណ្ណឹងបងប្អូនយើងប៉ុណ្ណឹងហាស អញ់នៅចាំវារួចអូនឯងទៅណាទេខ្ញុំទៅហៅអាចារ្យចុះសោរឯងនៅមើលទៅនិយាយតែចឹងលឺដល់កូនខ្ញុំអាបងណុងហាស ឆ្កួតៗឡូបៗចាស់ហើយភ្លើៗមិននាំគ្នាច្របាច់ដៃច្របាច់ជើងមិននាំគ្នាបបរអីបញ្ចុះបបរបញ្ចុះអីទេរកតែតាអាចារ្យអោយតែងាប់ អូ៎យអាវ៉ាអើយអញ់អើយអញ់ភ្លើអស់ហើយកូនអើយកូនមកដាក់បបរដាក់បបបរភ្លាម គេស្រែកតាមហ្នឹងហាសដាក់បបរភ្លាមអើបបរបោទចឹ

ងរឹតប្រេងកូឡាឡើងបីដើរសព្វគ្រប់ឡើងនាំគ្នាជំនុំតែរឿងយកអាចារ្យ អាចារ្យណុងយកមកងាប់ភ្លាមណុងហាសវា១..។

ក៖ គាត់ក៏..?

ខ៖ អើ?

ក៖ រស់វិញទៅ!

ខ៖ រស់វិទៅ។

ក៖ អូ៎!

ខ៖ គេមកគេធ្វើបុណ្យធ្វើទានអោយវិញទៅ។

ក៖ អូ៎!

ខ៖ ដល់ពាក្យគេនិយាយជាមួយហើយហោស!

ក៖ បាទ!

ខ៖ អើបងអាបងណុងអាបងដៃរប្រពន្ធណុងហ្នឹងមីងប្អូននៅស្រុកក្រៅហ្នឹងវាផ្ញើរលុយមកអាបងមកដល់ផ្ទះសំបែងហ្នឹងគេធ្វើបុណ្យជូនទៅលាមាត់លាករអោយប្អូនគេបានអាយុវែងហាសឈប់មកធ្វើចឹង១ទៀតទៅ។

ក៖ អូ៎!

ខ៖ ចាំហ្នឹងវាធ្វើបុណ្យអោយបានម្តងដៃរអូន។

ក៖ អូ៎ប៉ុន្តែអើកូនចៅរបស់អ៊ុំអត់មាននរណាគេចេះធ្វើផ្ទះទេណោះអ៊ុំណោះ?

ខ៖ អត់មានទេកូនអត់មាននរណាចេះធ្វើផ្ទះទេ។

ក៖ អូ៎បាទអ៊ុំចុះអើអ៊ុំគិតថាអើដូចជាឪពុកម្តាយរបស់អ៊ុំធ្លាប់បង្រៀនពីជំនាញអីទៅអ៊ុំអត់អ៊ុំជំនាញអីមួយធ្វើស្រែធ្វើអីមួយ អ៊ុំចេះធ្វើតែស្រែតើហីអ៊ុំរឺធ្វើអីមួយវេញវល្លិ៍ កូរស្ករធ្វើផ្តៅ..?

ខ៖ កូនហាសកូនជំរាបកូនអោយច្បាស់ទៅខ្ញុំទើបពុកខ្ញុំស្លាប់ជំទង់ដឹងតែឪពុកខ្ញុំប៉ុនមីថៅមិញហ្នឹងហោស ឪពុកប្រដៅហ្នឹងហាសឪពុកប្រដៅថាកូនចេះស្រឡាញ់បងប្អូនអីហ្នឹងហាស!

ក៖ បាទអ៊ុំ!

ខ៖ ដល់ស្រុកអាលែងកើតសង្រ្គាមទៅឪពុកខ្ញុំធ្វើអាលែងណោះហៅស្រីគេថាស្អីទេស៊ីបាយរោងបាយតែមួយណុងអាហ្នឹងគេហៅស្អីស៊ីបាយរោងបាយជាមួយគ្នាហ្នឹងស្អីណុងខ្ញុំភ្លេចទៅណោះបង អត់ស៊ីបាយតាមផ្ទះទេស៊ីបាយកន្លែងរោងបាយហើយមួយជំនាន់ណុងហោស?

ក៖ ស៊ីបាយរួមហើយ!

ខ៖ អាណុងគេហៅស្អីទេ។

ក៖ ជំនាន់ប៉ុលពតណុង?

ខ៖ ចាំពុកខ្ញុំក៏ទៅធ្វើគេអោយចាត់តាំងទៅភ្ជួរដីភ្ជួរស្រែអីចឹងហាស!

ក៖ បាទអ៊ុំ!

ខ៖ មកភ្លៀងខ្យល់គាត់ដឹកគោដឹងគោមកផ្ទះវិញមកចងកន្លែងរួមណុងវិញមករន្ទះបាញ់ងាប់ពុកខ្ញុំទៅ។

ក៖ អ៊ូ!

ខ៖ រួចឪពុកខ្ញុំហ្នឹងខ្ញុំទៅតាមមុខព្រួញការដ្ឋានហើយ ខ្ញុំជីកទំនប់នេះអាទំនប់ជីវនេះគេហៅទំនប់ស្អីគេទេទំនប់ហ្នឹងធំហាសណាស់ក្មួយហាស!

ក៖ បាទអ៊ុំ!

ខ៖ ទទឹងសាមសិបម៉ែត្រអាជើងក្រោមវាហាសិបហោស។

ក៖ បាទអ៊ុំបាទ!

ខ៖ ខ្ញុំចេះតែបញ្ជូនធ្វើអាណុងហើយខ្ញុំគេបញ្ជូនទៅតំបែរគោកស្រុកទៀតហោសកងចល័តខ្ញុំចូលកងចល័តហើយ!

កៈ អ៎ូ!

ខៈ បានដឹងដំណើងអាលែងអ្នកអាលែងស្មៀងដឹកអង្គតដឹកបន្លែអីហ្នឹងហាស យកទៅហាស គេថាអើមិត្តនារីហៅពូងាប់ហើយអ៎ូយក្មួយអើយក្មួយយំៗបោកខ្លួនយំពុកខ្ញុំងាប់ណុងខ្ញុំយំរួចគេមិនអោយមកណាម៉ាជំនាន់អាពតណុងហោស គេមិនអោយមកឃើញឪពុកយើងងាប់ទេ។

កៈ អ៎ូបាទ!

ខៈ យើងដឹងតែធ្វើការទេៗទាល់ដឹងគាត់ងាប់គាត់អីចឹងគេគិតគូរគាត់ហើយណាស់។

កៈ បាទអ៊ុំ!

ខៈ យំមីថាខ្ញុំយំដល់ថ្នាក់សន្លប់គេបញ្ជូនទៅពេទ្យយំសុទ្ធតែយំអើខ្ញុំកូនកំព្រាយូរហើយណុងក្មួយ។

កៈ បាទអ៊ុំ!

ខៈ គ្មានថាចេះជំនាញស្អីអត់ដឹងទេក្មួយកូនកំព្រាហោស!

កៈ អ៎ូបាទអ៊ុំបាទ!

ខៈ កំព្រាឪពុកនៅតែម្តាយ។

កៈ ហើយ..?

ខៈ ចឹងបានខ្ញុំថានៅតែម្តាយម្តាយចេះតែអោយមានប្តីទៅកុំអោយកូនដើចគេយំកុំអោយកូនមានប្រុសណាមើលងាយមើលថោកកូនមេម៉ាយអីគាត់ចេះតែលើកទុកលើកដាក់អោយគេទៅ។

កៈ បាទអ៊ុំ!

ខៈ អើមានគេដណ្តឹងចេះតែអោយទៅ។

កៈ អ៎ូល្អអ៊ុំ!

ខៈ ចាំហ្នឹងហាសក្មួយបានអីអ៊ុំដឹងចឹងៗអត់។

ក៖ ចឹងម្ដាយក៏អត់ធ្លាប់បង្រៀនអីដែរណោះអ៊ុំណោះ?

ខ៖ ម៉ែខ្ញុំគ្មានបង្រៀនអីទេបង្រៀនដូចខ្ញុំថាចឹងការងារមេផ្ទះគាត់អោយចេះតែទុកចេះតែដាក់ការងារប្ដីរកបានមកចេះទុកចេះដាក់កុំឈរៗឈឺមៗស្រីអត់កើតគេហៅស្រីម៉េចស្រីកញ្ជើធ្លុះហោសអីចឹងទៅ។

ក៖ បាទអ៊ុំបាទ!

ខ៖ ម៉ែខ្ញុំគាត់និយាយចឹងម៉ែខ្ញុំថានាងរត់រកនាក់គាត់និយាយចឹងខ្ញុំចាំពាក្យម៉ែខ្ញុំនាងរត់រកនាក់។

ក៖ អ្ហ៎!

ខ៖ មីខាតល័ក្ខរត់រកអាក្រវ៉ាកសារណាស់កូនជំទាវគេរត់រកឧកញ៉ាខ្ញុំចាំពាក្យស្លោកម៉ែខ្ញុំចឹង។

ក៖ អ្ហ៎!

ខ៖ អើជំទាវគេរត់រកឧកញ៉ាហើយរួចមីលេចរត់រកអាលួងគេនិយាយចឹងខ្ញុំថាសើចអើយសើចមីលេចត្រឹមជង្គង់អាលង់ត្រឹមចង្កេះរួចយើងយកពាក្យណាមិនយើងយកពាក្យអាល្អៗ។

ក៖ បាទអ៊ុំ!

ខ៖ នាងរត់រកនាក់ទៅ។

ក៖ អ្ហ៎!

ខ៖ អើម៉ែប្រដៅបានប៉ុណ្ណឹងខ្ញុំចាំពាក្យម៉ែខ្ញុំប្រដៅតែចឹងអត់មានប្រដៅអីទេ។

ក៖ បាទអ៊ុំបាទ!

ខ៖ ចាំ!

ក៖ ចុះអ៊ុំគិតថាចឹងអើសុំសួរអ៊ុំទាក់ទងពីជំនាន់អើដែរអ៊ុំកើតទាន់វិញដូចជាជំនាន់អីសាវ៉ាក់អ៊ុំទាន់អត់?

ខ៖ អត់ទេអត់ទាន់ទេទើបទាន់ជំនាន់លុនណុលណុងទេកូន។

កៈ ចុះព្រៃម៉ាក់គីហោសអ៊ុំ?

ខៈ ព្រៃម៉ាក់គីហ្នឹងអត់ទាន់ទេប្ដីខ្ញុំទេបានទាន់។

កៈ ប៉ុន្ដែអ៊ុំអត់ដឹងទេណោះអ៊ុំ?

ខៈ អត់ដឹងទេ។

កៈ អ៊ុំលឺតែគេនិយាយណេះ?

ខៈ ខ្ញុំលឺតែគេនិយាយប៉ុនខ្ញុំយាយដឹងទាំងអស់ហោស!

កៈ អូ៎!

ខៈ តាខ្ញុំដឹងទាំងអស់ហោសគាត់ធ្វើស្អីៗគាត់ដឹងទាំងអស់ហោស!

កៈ អូ៎បាទ!

ខៈ ជំនាន់ណុងគាត់តស៊ូបើក្មួយឯងសម្ភាសចំគាត់ងាប់ហើយស្ដាប់គាត់ណុងបានច្បាស់ជាងខ្ញុំ។

កៈ អូ៎ព្រោះថាឥឡូវគាត់នៅ..?

ខៈ ព្រោះខ្ញុំសុទ្ធតែកូនកំព្រាខ្ញុំមិនសូវចេះស្ដាប់ដឹងអីវែងឆ្ងាយអីទេ។

កៈ អូ៎បាទអ៊ុំ!

ខៈ ខ្ញុំដឹងតែឆ្នាំចិតសិបបាតុកម្មណុងពុកខ្ញុំរត់ឡើងលើស្ពាកជ័យោសម្ដេចឪអាណាមិនទៅកាប់ចោល ខ្ញុំដឹងតែឪពុកខ្ញុំរត់ឡើងលើស្ពាកខ្លាចគេហាសអើរួចទៅគេដើរឆែកមើលតាមផ្ទះចឹងទៅណោះគាត់នៅលើស្ពាកនៅផ្ទះចឹងមួយជំនាន់ណុង។

កៈ ចុះអ៊ុំគិតថាអើជំនាន់លុនណុលនៅជំនាន់លុនណុលអ៊ុំនៅណាអ៊ុំ?

ខៈ ជំនាន់លុនណុលខ្ញុំនៅកោះតើ!

កៈ នៅកោះជ្រូកហោស?

ខ៖ ចាំណុងខ្ញុំនៅអើថាក្រមុំហើយនៅកោះជ្រូកណុង។

ក៖ អូ៎!

ខ៖ ចាំ!

ក៖ អ៊ុំធំហើយណោះ?

ខ៖ ធំដែរហើយ!

ក៖ ពេលណុងអ៊ុំធ្វើអីទៅអ៊ុំជំនាន់លុនណុល?

ខ៖ ទេ..។

ក៖ លុនណុលជំនាន់គ្រាប់ផ្លោងផ្ទុះគ្រាប់ផ្លោង?

ខ៖ គ្រាប់ផ្លោងផ្ទុះណុងណុងយើងមានធ្វើអីនៅក្នុងគ្រួសារមានតែម៉ែមានតែកូនណុង កូនកំព្រាម៉ែមេម៉ាយមានទៅធ្វើអីណាបានក្បោះក្បាយដូចគេកូន។

ក៖ អូ៎!

ខ៖ ចាំ!

ក៖ ប៉ុន្តែអើលក្ខណៈថាពេលហ្នឹងយើងធ្វើការអីយើងនៅតែធ្វើស្រែចំការដដែរតើហីអ៊ុំហេស?

ខ៖ ចាំធ្វើបណ្តើរប៉ុនគ្រាន់តែយើងមិនទៅធ្លាក់ខ្លួនដើរស៊ីឈ្នួលគេអត់ទេណាស់ម៉ែគាត់ គ្រប់គ្រងដូចខ្ញុំប្រាប់ចឹងហាស ម៉ែខ្ញុំគ្រប់គ្រងកូនណាស់។

ក៖ អូ៎!

ខ៖ តែអង្ករណុងគាត់មិនអោយបុកអើអ៊ុំស្តីហ្នឹងក៏គាត់មិនអោយយើងអ៊ុំស្តីដែរគាត់ខ្លាចកំពុប អង្ករគាត់។

ក៖ បាទ!

ខ៖ ព្រោះគាត់បានមកពិបាករកណាស់កូនឯងចេះបុកទៅមិនស្រួលទៅកំពុបអង្គរអញ់អោយហើយ អញ់បានកូនអោះចឹងហាសគាត់សន្សំសំចៃចឹងហាសចាំ!

ក៖ បាទអ៊ំបាទ!

ខ៖ អើចឹងក្មួយ។

ក៖ ចុះអើចឹងអើប៉ុន្តែពេលជំនាន់ណុងយើងជីកត្រង់សេយើងជីកអីចឹងទៅណោះ?

ខ៖ ជីកៗក្មួយជីក។

ក៖ ប៉ុន្តែពេលណុងយើងនៅណាយើងនៅកោះជ្រូកហ្នឹងមែន?

ខ៖ ខ្ញុំនៅកោះជ្រូកណុង។

ក៖ រួចទៅអើអត់សូវបានធ្វើការអីណាហីអ៊ុំហេសដោយសារតែអាលែងរត់គេចពីគ្រាប់ផ្លោងគ្រាប់អី?

ខ៖ រត់គេចគ្រាប់ផ្លោង។

ក៖ ក្រុមគ្រួសារយើងអត់សូវបានធ្វើអីទេ?

ខ៖ ចាំអត់សូវបានធ្វើអីទេ។

ក៖ ចុះ..?

ខ៖ មានបានធ្វើអី។

ក៖ ចុះជំនាន់ណុងដូចជា..?

ខ៖ ចេញតែគោទាំងក្រោលៗនៅក្រោមផ្ទះណុងរួចយើងចេញទៅហ្នឹង យើងចេញរត់គ្រាប់ផ្លោងទៅទៅដល់ក្រោលគោវិញគេលួចអស់រលីង។

ក៖ អូ៎!

ខ៖ ម៉ែខ្ញុំគេលួចអស់អើមានតែភាពសោកស្តាយណុងលំបេកលំបាកណុងហាស!

កៈ រួចយប់ឡើងចឹងទៅយើងរត់ចូលទៅគេងក្នុងត្រង់សេចឹងទៅរីមួយទាល់យន្តហោះមកអីចឹង?

ខៈ តាមតែមើលយន្តហោះមកពីមុនមកគេហៅអាចានស្រះហ្នឹងហាសអាចានស្រះហ្នឹងមកយកការហើយ!

កៈ អាទ្រុងជ្រូកហីអ៊ុំ?

ខៈ អត់ទេអាចានស្រះទេអាស្លាបកាត់អាស្លាបកាត់ហ្នឹងវាមកមុជយកៗបាញ់តែម៉ងហោស អើអាទ្រុងជ្រូកអានេះណុងវាមកយកការណ៍ហ្នឹងហើយវាមកយកការណ៍យើងណុងហើយអាស្លាបកាត់ហ្នឹងមកបាញ់យក។

កៈ អ៊ូ៎បាទអ៊ុំ!

ខៈ បងឪពុកខ្ញុំហោសឈ្មោះធុងដុននៅពាមហាសអាឡែវកូន កូនគាត់ច្រើនប្រាំពីរប្រាំបីនាក់ហោសចូលដល់ក្នុងត្រង់សេហើយហ្នឹងហាសស្រាប់តែមកមើលកូនចូលដល់ក្នុងត្រង់សេរាប់កូនថាវាអត់គ្រប់ចំនួនកូនហោសអើតមករកកូនហាស អាស្លាបកាត់ណុងបាញ់ងាប់ភ្លាម។

កៈ ឪពុកអ៊ុំហោស?

ខៈ ងាប់ម្ដាយធំខ្ញុំ។

កៈ អ៊ូ៎ម្ដាយធំហោស?

ខៈ ចាំងាប់ហ្នឹងត្រង់សេណុងភ្លាម។

កៈ អ៊ូ៎!

ខៈ វាឃើញវាបាញ់ងាប់ភ្លាមជាអឹមម្ដាយហាសទឹកចិត្តម្ដាយហាស!

កៈ បាទអ៊ុំបាទ!

ខៈ រួចអាស្លាបកាត់វាមកងោងៗបាញ់ត្រួសៗផាំងៗអើតមើលបន្តិចមើលកូន កូនទៅណាមកណាទៅគេឃើញយើងគេបាញ់គាត់សំលាប់ចោល។

ក៖ អូ៎បាទអ៊ុំ!

ខ៖ ម្ដាយធំខ្ញុំ។

ក៖ ចុះអើដល់ពេលបន្ទាប់ពីណុងមកដល់ចូលប៉ុលពតណោះអ៊ុំណោះ?

ខ៖ ចាំ!

ក៖ រួចចុះចូលប៉ុលពតគេជំលាសយើងទៅណាលអ៊ុំគេកៀរយើងទៅណាទៅ?

ខ៖ ខ្ញុំគេជំលាសទៅនៅកំពង់ទ្រាស។

ក៖ នៅណាវិញអ៊ុំ?

ខ៖ កំពង់ទ្រាសយើង..។

ក៖ អូ៎!

ខ៖ ទាល់មុខអាលែងហាន់ជ័យនេះ។

ក៖ បាទអ៊ុំបាទ!

ខ៖ ចាំខ្ញុំទៅនៅកំពង់ទ្រាសភូមិទីបី។

ក៖ គេអោយយើងធ្វើអីអ៊ុំពេលណុង?

ខ៖ អើក្មួយអើយតាមវ័យយើងហាសណាស់វ័យយើងម៉ែខ្ញុំនៅរោងបាយទៅគេអោយនៅរោងបាយ។

ក៖ បាទអ៊ុំ!

ខ៖ អើរួចទៅខ្ញុំអីកងចល័តហើយក្មួយខ្ញុំដើរកងចល័តដើរតាមមុខព្រួញហើយ!

ក៖ បាទអ៊ុំបាទ!

ខ៖ ចាំ!

កៈ ប៉ុន្តែអ៊ុំចុះអ៊ុំអាយុប៉ុន្មានទៅប៉ុលពត

ខៈ ខ្ញុំទើបដប់ប្រាំពីរដប់ប្រាំបីអីហើយ!

កៈ អូ៎!

ខៈ ដប់ប្រាំមួយដប់ប្រាំពីរហ្នឹងហើយចឹងប៉ុណ្ណឹង!

កៈ ចុះអ៊ុំនៅកងនារីហាសណោះអ៊ុំណោះ?

ខៈ កងនារី។

កៈ អូ៎!

ខៈ ចា៎!

កៈ ចុះគេប្រើយើងធ្វើអីទៅអ៊ុំ?

ខៈ អត់មានធ្វើអីតាមមុខព្រួញគេហ្នឹងទៅដើរទៅលើកទំនប់ជីកប្រឡាយហ្នឹង ថ្ងៃណាក៏ថ្ងៃបុណ្យចឹងហាសចំរៀងវាថ្ងៃណាក៏ថ្ងៃបុណ្យបុណ្យរៀងរាល់ថ្ងៃខ្ញុំចាំច្បាស់អាបុណ្យបទអាពតថ្ងៃណាក៏ថ្ងៃបុណ្យបុណ្យវាអោយយើងទៅធ្វើចឹងៗការងារពតកម្មក៏ថ្ងៃបុណ្យ។

កៈ អូ៎!

ខៈ អើថ្ងៃបុណ្យបុណ្យរាល់ថ្ងៃអើគ្មានពេលណាទេបុណ្យណុងបុណ្យរាល់ថ្ងៃហើយណុងហ្នឹងដើរតែតាមហ្នឹងព្រួញមុខព្រួញទៅវាផ្លាស់ទៅណាទៅវិល ល្មមបានមកជួបជុំម៉ែឪបួនខែ។

កៈ អូ៎!

ខៈ បួនខែ។

កៈ ចឹងមានន័យថាអ៊ុំជំលាសទៅច្រើនកន្លែងហើយអ៊ុំ?

ខៈ ចា៎គ្រាន់ត្រង់ថាភូមិយើងគេទុកអោយមួយភូមិនៅហ្នឹងហាស!

កៈ បាទ!

ខ៖ ដល់គ្រាន់តែយើងគេអោយចាត់តាំងទីណាៗទៅមួយខែពីរខែបីបួនខែទៅបានយើងចូលមកក្នុងភូមិម្តងទៅ។

ក៖ បាទអ៊ុំបាទ!

ខ៖ អើរួចទៅគេចាប់តាំងកងចល័តទៅទៀតហើយ!

ក៖ អូ៎!

ខ៖ ម៉េចគេហៅកងចល័តទ័ពលេខមួយហោស!

ក៖ អូ៎!

ខ៖ ចាំទៅហើយ!

ក៖ ចុះកន្លែងណាដែរអ៊ុំគិតថាពិបាកជាងគេអ៊ុំនៅពេលដែរគេជំលាសបាសកន្លែងណាដែរគិតថាកន្លែងដែរពិបាកជាងគេ?

ខ៖ អត់ទេក្មួយនៅសង្គមណុងវាត្រូវសង្គមចឹងហើយ!

ក៖ អូ៎ពិបាកទាំងអស់ហោស?

ខ៖ តាមសង្គមពិបាកទាំងអស់។

ក៖ ចឹងគ្រប់កន្លែងគឺពិបាកម៉ង?

ខ៖ ពិបាកទាំងអស់ម៉ងអត់មានរឿងអីស្រួលទេម៉ោងបួនអីឡើងកញ្ចែច្រេកក្រោកតំរង់ជួរ តំរង់ជួរហ្នឹងមានស្ត្រីមានតែបង្គីហើយហ្នឹងចបហ្នឹងកាន់រៀងៗខ្លួនទៅ។

ក៖ អូ៎!

ខ៖ តំរង់ជួរទៅទៅតាមមុខព្រួញយើងកាប់ដីកាប់អីហ្នឹងទៅ។

ក៖ បាទអ៊ុំបាទ!

ខ៖ ក្មួយ។

កៈ ចុះម្ហូបអាហារម៉េចដែរទៅអ៊ុំពេលយើងជាកងនារីចឹង?

ខៈ ក្មួយអើយក្មួយវាមិនដែរខ្ញុំមិនធ្លាប់ទេបងអើយថាខ្ញុំអើយដើរនិយាយប្រាប់កូន កូនអើយគេទៅជីកគេឆ្លៀតហាសឆ្លៀតដល់ពេលអាលែងយើងសំរាកការងារបន្តិចបន្តួចហ្នឹងឆ្លៀតទៅជីកទំពាំង ជីកទំពាំងរួចខ្ញុំហ្នឹងច្រើនមិត្តៗហ្នឹងនៅជិតខាងគេហុចមួយចំណិតពីរចំណិតមកហោសបងអើយស៊ីទទេមានអំបិលណាចុចថាវាឆ្ងាញ់អើយឆ្ងាញ់ដូចសាច់មាន់ ឆ្ងាញ់ហាសទំពាំងថាវស្រុះហាសវាស្រុះទៅស៊ីជាមួយបាយហ្នឹងហាសឆ្ងាញ់ហាសមួយជំនាន់ណុងឆ្ងាញ់ហាសអើក៏បបួលគ្នាមកដេកជិតៗកន្លែងយើងហ្នឹងជាមួយគ្នាហ្នឹងប្រាំប្រាំមួយនាក់អ៊ូយើងថ្ងៃហ្នឹងអាពេលយើងសំរាកការងារយើងទៅរកចូលព្រៃទំពាំងហោសទៅជីកទំពាំង អើតោះស្រាប់តែទៅវង្វេងផ្លូវក្មួយអើយវង្វេងផ្លូវក៏ហួសពេលវេលាដែរយើងមកជីកដីអោយអង្គការណុងហោសហួសរួចទៅមិត្តៗទាំងអស់ហ្នឹងហោស ដឹងតែប្រកែកគ្នាអើមិត្តឯងថាស្គាល់ផ្លូវៗចេញចូលឥឡូវវង្វេងហើយ វង្វេងហើយបន្ទោសមួយថាៗបន្ទោសគ្នានៅព្រៃគុម្ពឬស្សីណុងហាសវង្វេងខ្ញុំថាអើយកុំបន្ទោសគ្នាមិត្តហាសមិត្តខ្ញុំលើកតែដៃបួងសួងទេអើយលោកតាថែរក្សាព្រៃភ្នំហ្នឹងហាសព្រៃឬស្សីហ្នឹងហាសសុំជួយខ្ញុំអោយរកផ្លូវឃើញទៅវិញទៅ ខ្ញុំខ្លាចអង្គការជីកដីហ្នឹងគេឃើញគេបាត់ខ្ញុំហ្នឹងដឹងគេថាម៉េចអីម៉េចទេណាស់អ៊ូដឹងគេហៅយកទៅកសាងអីម៉េចៗហើយជួយអោយខ្ញុំរកផ្លូវឃើញទៅ ដើរទៅដើរមកឃើញតែផ្លែក្រមួយហ្នឹងដើរទៅដើរមកអត់ចេញទៅនៅឃើញតែផ្លែក្រហ្នឹងអាផ្លែក្រប៉ុណ្ណឹងខ្ញុំមិនដែរស្គាល់ណាដល់មួយជំនាន់ណុងខ្ញុំស្គាល់ផ្លែក្រ ដល់លើកដៃបួងសួងអាគេប៉ុន្មាននាក់ហ្នឹងដឹងតែបង្ខាំគ្នាឯងជជែកគ្នាហោសអញ់ស្គាយចឹងអញ់មិនមកទេវាថាវាស្គាល់ផ្លូវឥឡូវអត់ស្គាល់ផ្លូវវង្វេងនៅក្នុងហ្នឹងហោសមិនដឹងទៅណាមកណាទេឥឡូវម៉ោងប្រាំហើយនេះ នៅក្នុងរួចទៅដេកណាអីណាងាប់ហើយវង្វេងនៅដេកក្នុងព្រៃហ្នឹងហើយហោសមើលទៅវីវរខ្លាយកអស់ហើយរួចខ្ញុំថាកុំនិយាយមាត់អាក្រក់ៗពេកខ្ញុំចេះតែបួងសួងទៅ ខ្ញុំអត់ចង់រកឃើញថាម៉េចទេអោយតែឃើញថាផ្លូវត្រូសៗទៅខ្ញុំដើរចេញទៅហើយលោកតាលោកយាយអើយនាំផ្លូវទៅជួយអាណិតកូនចៅងងឹតល្ងង់ ហេតុតែអត់ឃ្លានហើយហ្នឹងហាសអត់ឃ្លានហើយបានចូលមកព្រៃហ្នឹងហាស ឥឡូវចូលមកវារវង្វេងផ្លូវស្រាប់តែឃើញផ្លូវត្រូសៗថាដើរមកនេះត្រូសៗហាសត្រូសៗស្រាប់ឃើញព្រៃកមួយ ឃើញព្រៃកអើឃើញព្រៃកគេដាក់ឬស្សគល់ឬស្សីតូចៗមាត់ព្រៃកណុងវែងដែរថាពីជញ្ជាំងខ្ញុំទៅសសរណុងហាសអើនាំគ្នាដើរម្នាក់ម្តងវើយកុំអើយធ្លាក់ព្រៃឬស្សីគល់ឬស្សីផងហោសឆ្លងវាលឆ្លងអីក៏ផុតម្នាក់មកផុតល្មមបានរួចឆ្លងព្រៃករួចទៅអូសចេញមកអ៊ូនោះទំនប់យើងហាសណុងហាសទំនប់យើងមើលឃើញហើយតើ អើមកថាចេញមកអើយល្បាកៗព្រៃឬស្សីហ្នឹងហាសពេញតាមអាជាយៗ

ទំនប់គេជីកណុងហាសស្រាប់ឃើញមិត្តៗយុវជន មិត្តៗយុវជនបួនប្រាំនាក់ទៅតាមយើងហាស!

ក៖ បាទអុំ!

ខ៖ អើតាមយើងស្រែកហៅចឹងហាសអើមិត្តនារីអឺអើយអើខ្ញុំថាណោះមិត្តយុវាជនដើររកយើងហើយតើនោះអើអ៊ូមាត់គេសុទ្ធតែស្រែកចឹងហាសអ្នកណាស្គាល់ឈ្មោះអ្នកណាហៅឈ្មោះអ្នកណុងហើយ ស្រីៗថានេះអ៊ូមិត្តអើយខ្ញុំចេញរួចហើយមិត្តអើរួចទៅបានគេធ្វើអើវាទំនប់វាខ្ពស់ដែរគេធ្វើកាប់ជញ្ជ្រាំភ្លៀងមកព្រេចៗដែរយើងរអិលនេះហោស គេធ្វើអោយមានហេតុៗអោយយើងឡើងជាន់ទៅលើទំនប់ណុងហាសបានមិត្តៗយុវជនប្រាំប្រាំមួយនាក់នារីៗឯងប្រាំប្រាំមួយនាក់នរណាស្គាល់មិត្តនារីណាហៅឈ្មោះនារីណុងទៅ អើមិត្តណាស្គាល់មិត្តណាហៅមិត្តណុងទៅប៉ុនគ្មានទេច្រើនតែស្គាល់បងខ្ញុំអ៊ូមិត្តអឺអើយនៅណាហៅៗទៅខ្ញុំក្រឡែកឃើញហោសខ្ញុំលឺហោស ណែខ្ញុំនៅណេះអើមកខ្ញុំមកតាមហើយបានបងអើយលំបាកណាស់ណាកុំហាសជីវភាពជំនាន់អាពតស៊ីបាយវាលតិចៗទេរួចធ្វើការពេញទំហឹងធ្វើការពេញទំហឹង។

ក៖ រួចចុះអើចឹងយើងហូបបាយដែរអត់ហូបបបរទេអុំណេះ?

ខ៖ បាយមួយវែកហ្នឹងហោស!

ក៖ អ៊ូ!

ខ៖ គោះចានហ្នឹងហោសរួចកំលាំងធ្វើការវែកដីចង់ងាប់ចង់រស់ហ្នឹងហោស!

ក៖ ចុះបើយើងឃ្លានចឹងយើងអត់ទៅជីកក្តួចជីកដំឡូងបន្ថែមទៀតទេហោសអុំហោស?

ខ៖ អើជីកទំពាំងនៅព្រៃឬស្សីទំពាំងណុងទៅរកទីណាការងារអង្គការគេដឹងតែពេលវេលាអើម៉ោងប៉ុន្មានម៉ោងប្រាំទៅដល់កន្លែងធ្វើការហើយណាស់ ម៉ោងដប់មួយមកដល់កន្លែងស៊ីបាយហាសម៉ោងមួយចុះធ្វើវិញអត់មានពេលអីណាអាពេលយើងឆ្លៀតម៉ាតិចហ្នឹងថាទៅរកទំពាំងគ្រាន់បានមួយពីរយកមកស៊ីវាឆ្ងាញ់ដូចសាច់មាន់ហ្នឹងហាស ទៅទទួលវង្វេងក្នុងព្រៃហ្នឹងទៅមានទៅរកមានក្តួចយើងមានណាយើងមានពេលវេលាណាដូចពេលដែរឯកជនដូចគេនាំយើងណា គេគ្រប់គ្រងយើងដីមួយកិបដូចគេវាស់ដីអោយដើរចឹងហាសយើងទៅហ៊ានឈានឆ្លងហួសកន្លែងគេណាបានក្បួយមួយជំនាន់ណុងហោស!

ក៖ អូ៎បាទអ៊ុំ!

ខ៖ ចាំគេវាសល់អោយយើងដើរធ្វើការងារកន្លែងណាទៅកន្លែងណុងប៉ុនណុង។

ក៖ អូ៎បាទចុះអើទាក់ទងពីឈឺវិញម៉េចទៅអ៊ុំចឹង?

ខ៖ អើឈឺមានអីមានតែថ្នាំពេទ្យគេផ្សំអាលែងដើមធម្មជាតិយើងហ្នឹង ថ្នាំដូចអាចម៍ទន្សាយហ្នឹងអូនឯងធ្លាប់ឃើញជំនាន់អាពតថ្នាំអាចម៍ទន្សាយទេ។

ក៖ ខ្ញុំដែរឃើញតែអង្ករលីរទេ?

ខ៖ ហានឹងអាចម៍ទន្សាយហាស!

ក៖ បើខ្ញុំមិនដែរឃើញ?

ខ៖ ខ្ញុំហាសខ្ញុំជំនាន់អាពតហាសគេហៅខ្ញុំធ្វើពេទ្យហាសខ្ញុំបានតែស្លឪសថបុរាណហ្នឹងទៀតហោស អើគេធ្វើឬសឈើធម្មជាតិហ្នឹងតើដើមសាវម៉ាវយើងហ្នឹងវល្លិ៍សាវម៉ាវយើងហ្នឹងវល្លិ៍ប្រមោយដំរីយើងហ្នឹង អូ៎អាគ្រាប់ថ្លែងស្អីហ្នឹងអូ៎ច្រើនហាសយកមកដាំហ្នឹងខ្វះត្នោតដាំនៅហ្នឹងខ្វះត្នោតខ្ញុំទៅគេរំងាស់ទាល់តែរីងទៅគេដូចជាសំបកក្តុលសំបកអីទេនេះណុងគេបុកអោយម៉ត់ទៅគេចូលយកមកជាមួយលាយហ្នឹងអាទឹកខាប់ហ្នឹងហាស បញ្ចូលគ្នាទៅសូន្យធ្វើថ្នាំអោយយើងលេបប៉ុនយើងលេបអាមួយជំនាន់សង្គមណុងជាណាស់ក្អួយណាស់។

ក៖ ជាដែរអ៊ុំ?

ខ៖ ជាហាស!

ក៖ ប៉ុន្តែត្រូវជំងឺគ្រប់មុខហោស?

ខ៖ ជាតើត្រូវជំងឺគ្រប់មុខហាស!

ក៖ ស្អីក៏ត្រូវដែរ?

ខ៖ ដើមឈើធម្មជាតិហ្នឹងឈឺក្បាល ក្តៅខ្លួនអីត្រូវតើក្អួយ។

ក៖ អូ៎!

ខ៖ ចាំគេមានចាត់តាំងមិត្តៗធ្វើអាលែងឧសថបុរាណហ្នឹងឧសថធម្មជាតិយើងហ្នឹង!

ក៖ បាទអ៊ុំ!

ខ៖ ចាំរួចបើមិត្តណាឈឺខ្លាំងទៅគេបញ្ជូនទៅពេទ្យប៉ពីរកាលជំនាន់ណុងគេហៅប៉ពីរប៉មួយប៉ពីរអីចឹងតាមជំងឺយើងទៅបើនៅតាមភូមិមានតែឧសថហ្នឹងតែម៉ង។

ក៖ បាទ!

ខ៖ ឧសថឆ្លងថ្នាំណុង។

ក៖ ចុះអ៊ុំគិតថាចឹងការងារយើងអីធ្វើម៉េចទៅអ៊ុំព្រឹកល្ងាចយប់ដែរទៅ?

ខ៖ យប់ដែរទៅយប់ជួនណាការងារដែរគេត្រូវប្រញុកគេអោយយើងជីកណោះអារណ្តៅអំពៅក្នុងម្នាក់គេអោយជីកប៉ុន្មានរណ្តៅអើយើងប្រឹងទៅឆាប់បានឡើងមកផ្ទះដេកទៅ ម៉្តែរណ្តៅមួយយប់អោយម៉្តែរណ្តៅរណ្តៅអំពៅមិនមែនតែថ្ងៃទេណាស់យប់ក៏វាប្រើយើងដែរណាស់ប៉ុលពតហាសម៉េចនិយាយចឹងក្មួយ។

ក៖ ចុះយើងគេងអត់ឆ្អែតចឹងធ្វើម៉េចទៅយើងមិនបាក់កំលាំងហើយ?

ខ៖ អត់ទេធម្មតាម៉ាជំនាន់ណុងធម្មតាតាមសង្គមវាអស់ហើយក្មួយស្រួលវាតាមសង្គមគេអស់ហើយណាស់ មានពិបាកអីទេតាមគេប្រើយើងបានចឹងហើយ!

ក៖ អូ៎!

ខ៖ យើងគេចទៅណាមិនរួចពីក្រញាំដៃគេទៅហើយអត់ឈឺអីទេដូចក្របី ដូចគោដូចក្របីរួចទៅគេទាំងអស់គេចូលទៅលួចហាសគេចូលទៅលួចក្នុងចំការអំពៅចំការចេកហាសខ្ញុំអត់ហ៊ានទេខ្ញុំអត់ហ៊ានទេខ្ញុំខ្លាចគេហាស!

ក៖ ខ្លាចគេយកទៅវៃចោល?

ខ៖ ខ្ញុំខ្លាចហាសគេថាមិត្តឯងអត់ហ៊ានទេ ទេអញ់អត់ហ៊ានទេខ្ញុំអត់ហ៊ានទេខ្ញុំខ្លាចណាស់ខ្ញុំលួចគេខ្ញុំអត់ចេះទេម៉ាជាតិហ្នឹងខ្ញុំលួចគេខ្ញុំអត់ចេះតែម៉ងអើអត់ចេះទេក្មួយ។

ក៖ អូ៎បាទអ៊ុំ!

ខ៖ សុខចិត្តអត់។

ក៖ ប៉ុន្តែបង..?

ខ៖ ខ្ញុំខ្លាចគេហាស!

ក៖ ប៉ុន្តែបងប្អូនគាត់នៅកន្លែងផ្សេង?

ខ៖ ចាំនៅមុខព្រួញដោយៗខ្លួនខ្ញុំមុខព្រួញទីមួយតែម៉ងប្អូនៗខ្ញុំមុខព្រួញវានៅអាខ្លះវានៅកុមារទេណាស់ អាខ្លះវានៅតាមភូមិចាំគេនៅតាមភូមិស្រួលហាស!

ក៖ បាទអ៊ុំ!

ខ៖ តែខ្ញុំមុខព្រួញខ្ញុំទ័ពស្រួច។

ក៖ អូ៎!

ខ៖ ចាំហៅទ័ពស្រួចតែម៉ងក្មួយឈ្មោះឈ្មុល។

ក៖ អូ៎ចុះអើម្ដាយហើយហ្នឹងបងៗអីដល់ពេលដែរពួកគាត់ដែរដាច់ប៉ុលពតហ្នឹងពួកគាត់ធ្វើម៉េចបានជួបជុំគ្នាវិញដោយសារពួកគាត់នៅឆ្ងាយៗហាសមែនទេអ៊ុំ?

ខ៖ ឆ្ងាយៗដល់នេះទៅខ្ញុំដឹងតែធ្វើការម៉ែខ្ញុំគេផ្លាស់គាត់ទៅនៅតំបែរគោកស្រុកវិញ មុនយើងនៅអីនេះទេណាស់មុនយើងនៅអីកំពង់ទ្រាសទេណាស់។

ក៖ បាទអ៊ុំ!

ខ៖ រួចទៅខាងខ្ញុំខ្ញុំឈឺខ្ញុំដេកព្យាបាលនៅស្រុកពាមហ្នឹងហាស លឺគេថាអើគេថាមីងគេផ្លាស់ទៅនៅអីតំបែរគោកស្រុកហើយមិត្តហាសយំនឹកម៉ែអើយម៉ែអើយមិត្តឯងជាទៅពុងគេបញ្ជូនទៅរកគាត់ហើយគេយកគាត់មកវិញហើយ អើរួចខ្ញុំបានឪពុកមាមួយផ្ទះនៅពាមហ្នឹងបានចេញពីពេទ្យមកបានឪពុកមាមើលអើនឹកម៉ែអើម៉ែខ្ញុំទៅនៅអីតំបែរគោកស្រុកដោយប្អូនទៅពីរនាក់ ប្អូនប្រុសមួយប្អូនស្រីពីរអើប្អូនស្រីមួយដែរទេរួចក្រៅពីណុងគេនៅតាមមុខព្រួញទាំងអស់។

ក៖ អូ៎បាទអ៊ុំ!

ខ៖ មុខព្រួញទាំងអស់រួចដល់ទៅក្នុយហាសបានគេអោយម៉ែខ្ញុំអ្នកណានៅស្រុកណានៅស្រុកណាវិលត្រលប់ចូលស្រុកវិញ ពេលណុងហាសខ្ញុំជួបជុំម៉ែខ្ញុំវិញចាំជួបជុំម៉ែវិញ។

ក៖ អ៎ូបាទអ៊ុំ!

ខ៖ ចាំ!

ក៖ ប៉ុន្តែធ្វើម៉េចបានយើងដឹងថាដាច់ប៉ុលពតទៅអ៊ុំមួយជំនាន់ណុង?

ខ៖ ប្រធានភូមិគេប្រាប់។

ក៖ អ៎ូគេប្រាប់យើងហោស?

ខ៖ ចាំថាស្រុកសន្តិភាពហើយខ្ញុំនៅជាមួយខ្ញុំនៅពាមជាមួយមាខ្ញុំនៅពេទ្យពាមហ្នឹងរួចខ្ញុំឃើញអាលែងបងជីដូនមួយខ្ញុំអីហ្នឹង គេដូចថាគេអោយអារម្មណ៍យើងល្អកុំនឹកម៉ែនឹកអីចឹងហាសអើបងខ្ញុំធ្វើខាងពានិចពានិចស្រុកគេថាអូនឯងចង់បានអីនេះបងមានហាស នេះយកអានេះហាសយកនោះអីចឹងហាសកន្លែងគេពានិចគេធំហាសណាស់ខ្ញុំអត់ចង់បានអីទេមិត្តបងខ្ញុំអត់ចង់បានអីទេ អើអត់ចង់បានអីរបស់គេទេអាពតដឹងគេបញ្ចូនដឹងគេវ៉ៃដាច់ខ្ញុំមើលឃើញគេបញ្ចូនឥវ៉ែតវ៉ាន់ទាំងកំនយកទៅឃ្លាំងណាវិញគេរើសពីឃ្លាំងពានិចនៅស្រុកណុងហោស អ៎ូប្រដាច់ប្រដាលពីដើមមានទាំងអស់បងហូរប្រម៉ូងមានសព្វបែបសព្វយ៉ាងខ្ញុំមើលឃើញទាំងអស់ រួចបងជីដូនមួយខ្ញុំគេអោយថាឡើងខុសគ្នាមួយថ្ងៃគេយកទៅវ៉ៃចោលថ្ងៃហ្នឹងហាសគេដាក់កាណូតយកទៅវ៉ៃចោលបងខ្ញុំ អើបងខ្ញុំស្រុកស្អែតសន្តិភាពហើយហ្នឹងហាសបងអើយឃើញជាក់ស្តែងខ្ញុំឃើញជាក់ស្តែង ខ្ញុំនៅស្រុកចំកន្លែងអាៗវាយកពួកយើងហ្នឹងយកទៅដាក់កាណូតបត់មួយកែងកោះពីរតិចហ្នឹងយកទៅវ៉ៃទំលាក់ទឹកតែម៉ងខ្ញុំថាវ៉ៃទំលាក់ទឹកអាកែងយើងកោះពីរហ្នឹង!

ក៖ បាទអ៊ុំ!

ខ៖ អើស្រែយំៗឈ្មោះចៃញ៉ក្នុយអើយអូនអើយបងទៅហើយអាមុំអាម៉ូវគេថាយកយើងទៅផ្លាស់ទៅធ្វើស្រែអំបិលអីណាៗចឹងហាសអាពតយកទៅវ៉ៃចោល យកឡើងលើកាណូតទៅកាណូតវង់ក្បាលកំពង់ទ្រាសហ្នឹងតិចកែងជ្រោយកោះពីរឡើងមកលើបន្តិចហ្នឹងជើងទាលស្រុតជើងទាលអីហ្នឹងតិចហ្នឹង អើយកទៅវ៉ៃចោលម៉ាភ្លេតកាណូតបកមួយភ្លេតមកវិញបកមកវិញដឹកដឹកហ្នឹងមិនជាស្អីដឹកសុទ្ធតែពួកអ្នកធ្វើការមួយជំនាន់ម៉ាគេចាត់តាំងណុងហាស មួយជំនាន់ម៉ាចាត់តាំងណុងខ្ញុំឃើញច្បាស់សុទ្ធតែមនុស្សល្អវាចាត់តាំងអោយគេធ្វើហើយសុទ្ធតែ

ដូរយកគេទៅវ៉ៃចោលហ្នឹងហាសមួយភ្លេតហ្នឹងណា ភូមិភាគៗអើអាខាងភូមិភាគយើងបូព៌ា ណាស់ខ្ញុំខាងកើតខាងបូព៌ាទេអាខាងពួកអាហ្នឹងគេហៅអីអាខាងនេះហ្នឹងទៅពីក្រោយហ្នឹងអា ហ្នឹងហាស!

កៈ អាកឺរ៉ាឌឺនហ្នឹង?

ខៈ អាកឺរ៉ាឌឺនហ្នឹងហាសអាហ្នឹងសាហាវហាស!

កៈ អ្នកជីតខាងអីខ្លាំងហាសអាណុងហោស?

ខៈ អើក្មេងៗតូចៗសំពាយកាំភ្លើងអូសដីទេប៉ុនមនុស្សចាស់យើងខ្លាចវាអត់ហ៊ានរត់ពីវាទេយក គ្នាវ៉ៃចោលពីក្នុងៗ។

កៈ បាទអ៊ុំបាទចុះអើនៅពេលដែរយើងមកជួបជុំគ្នាដំបូងយើងធ្វើម៉េចយើងរកផ្ទះឃើញទៅអ៊ុំ?

ខៈ អើគេអត់រុសទៅណា។

កៈ គេអត់រុសទេហោសចឹងមានន័យថាស្គាល់ផ្លូវស្គាល់អីមកដែរហោស?

ខៈ ស្គាល់ផ្លូវមក។

កៈ មានមនុស្សច្រើនមកហោសអ៊ុំ?

ខៈ មានចូលមក។

កៈ អូ៎!

ខៈ ចូលមកខ្ញុំមានមីមួយឈ្មោះមីឈូកៗណុងទៅវាហៅម៉ែខ្ញុំម្ដាយមីងហាស ថាមីងៗមីងឯង ទៅភ្នំពេញហោសវ៉ៃដាច់ណុងហាសម៉ែខ្ញុំថាគេមកភ្នមពេញគេចាប់ឡានយកផ្ទះថ្មគេគេធ្វើអ្នក មានសព្វថ្ងៃហ្នឹងហាស ថាហ៎េអញ់មកដល់ស្រុកដល់ភូមិហាលយអញ់អត់ទៅណាទេយើងមក ផ្ទះយើងយើងមនុស្សល្អយើងមនុស្សត្រង់ម៉ង រួចគេមនុស្សដូចថាគេដឹងហាសណាស់គេចង់ បានគេមានទាល់សព្វថ្ងៃហ្នឹងខ្លះដូចថាគេមានដោយសារចាប់ផ្ទះយកផ្ទះយកណុងហាស!

កៈ អូ៎!

ខ៖ យកផ្ទះយកអីមែនហាស!

ក៖ បាទមាសបានអីចឹងហាសណេះ?

ខ៖ អើគេទៅយកដីយកផ្ទះនៅអីភ្នំពេញហ្នឹងក្មួយហាសខ្ញុំវៃដាច់ណុងខ្ញុំទៅលក់នៅដល់ស្ពឺហោស ខ្ញុំដើរហាសទៅជាមួយម្តាយធំខ្ញុំទៅស្ពឺរទេះគោដាក់តែរបស់របរដែរយើងលក់រទេះគោព្រោះយើងអាណិតគោយើងដើរហោសក្មួយអលយឃើញតែគេដឹកជញ្ជូនឥវ៉ាន់ គេចេញពីផ្ទះថ្មមកប្រដាប់ប្រដាល់គេនៅផ្ទះថ្មណុងហាសអើយតុទូកៅអីរបស់គេល្អម៉ាស៊ីនដេរម៉ាស៊ីនអីចឹងទៅយកញូនរួចយើងហ្នឹងមិនចង់បានអីហ្នឹងគេទេទៅហើយចេះតែទៅហើយយប់ត្រង់ណាដេកត្រង់ណុងហើយៗ។

ក៖ អ៎ូបាទអ៊ុំបាទ!

ខ៖ ទៅអាលក់ដូរស្រូវអង្ករយកមកចិញ្ចឹមម៉ែខ្ញុំម៉ែមេម៉ាយហ្នឹងហាស!

ក៖ បាទអ៊ុំបាទ!

ខ៖ ម៉ែខ្ញុំអ្នកលក់អ្នកដូរ។

ក៖ អ៎ូចុះនៅពេលដែរយើងនៅពេលដែរដាច់ប៉ុលពតថ្មីៗយើងរកស៊ីអីទៅអ៊ុំដោយសារពេលណុងយើងធ្វើស្រែរួមណេះអ៊ុំណេះ?

ខ៖ អើធ្វើស្រែរួម។

ក៖ ប៉ុន្តែនៅពេលដែរយើងអត់ទោធ្វើស្រែយើងអត់ហើយណេះអ៊ុំ?

ខ៖ អត់អើរបស់យើងមានបានណា។

ក៖ អ៎ូ!

ខ៖ ស្រែរួមចែកគ្នា។

ក៖ ចុះពេលណាដែរយើងបានគេចែកស្រែអោយយើងអ៊ុំ?

ខ៖ អស់រយះយូរដែរដូចថាមួយឆ្នាំអីចឹងដែរ។

កៈ ចឹងហោសអុំ?

ខៈ ចា៎បានគេចែកស្រែ។

កៈ ប៉ុន្តែគេចែកតាមអារតាមអី?

ខៈ ចែកតាមអារតាមអារ។

កៈ អូ៎យើងបានច្រើនដែរណោះអុំណោះ?

ខៈ ចា៎គ្រួសារខ្ញុំបានគ្រាន់បើដែរ។

កៈ ចុះពេលហ្នឹងយើងមានការលំបាកអីទៅអុំ?

ខៈ លំបាកហាសណាស់ក្មួយហាសលំបាកហាសធ្វើស្រែហាស យើងអត់ទាន់មានគោពពែណាត្រឹមត្រូវដូចខ្ញុំប្រាប់ក្មួយឯងចឹងមិនហ៊ានបានយកអីហ្នឹងគេគេអ្នកយកគេចេះតែយកហាសណាស់។

កៈ បាទអុំ!

ខៈ រួចយើងអ្នកអត់យកវាពិបាកដែរហាស!

កៈ បាទ!

ខៈ ចា៎អូ៎ជំនាន់អាពតពិបាកហាសក្មួយអូ៎បើប្តីខ្ញុំប៉ុននិយាយហាសគាត់ចាំខ្ញុំស្រីខ្ញុំវង្វេងវង្វាន់ចា៎អត់វង្វេងវង្វាន់ទេក្មួយ។

កៈ អូ៎!

ខៈ អាពតសំលាប់ខ្លាំងហាសក្មួយ។

កៈ នៅពេលដែរដាច់ប៉ុលពតហ្នឹងអុំចាប់ផ្តើមធ្វើការហើយណោះអុំណោះ?

ខៈ ចា៎!

កៈ នៅពេលដែរដាច់ប៉ុលពតហ្នឹងអ៊ុំចាប់ផ្ដើមការហើយណេះនៅពេលធ្វើស្រែរួមហោសអ៊ុំ
កាលណុងអ៊ុំការហើយណេះ?

ខៈ ការហើយចាំ!

កៈ អ៊ូ!

ខៈ ការហើយ!

កៈ ពេលណុងអ៊ុំមានការលំបាកអីពេលដែរចាប់ដៃជាមួយប្ដីដំបូងៗ?

ខៈ ពិបាកតើក្មួយពិបាកអ៊ុំពិបាកអ៊ុំដើរតែលក់បានសល់តិចតួចអ៊ុំដើរលក់ផ្សំគ្នា។

កៈ បាទអ៊ុំ!

ខៈ អើអ៊ុំខែទឹកចឹងអ៊ុំមានដូងមានអីហ្នឹងទៅកំពង់ទ្រាសដូរពោតគេក្មួយយកមកចិញ្ចឹមកូនមុនៗ
អ៊ុំអត់ទាន់មានកូនមុនអត់ទាន់យកតាហ្នឹងអត់ទាន់មានទេ អើថាបានមួយពីរអីចឹងចុះណាស់។

កៈ បាទ!

ខៈ អើយកទៅយកមកពោតហ្នឹងអីទៅយកមកលាយបាយលាយអីទៅក្មួយ រួចតាហ្នឹងខែវស្សា
អីចឹងទៅគាត់ឡើងទៅភ្នំហានិជ័យណុងជីកក្ដួចជីកអី។

កៈ អ៊ូ!

ខៈ ជីកក្ដួចចាំយកមកផ្សំគ្នាទៅពិបាកហាសណាស់ក្មួយចិញ្ចឹមកូន។

កៈ បាទអ៊ុំបាទ!

ខៈ ចាំ!

កៈ ចុះអើដល់ពេលណាដែរយើងចាប់ផ្ដើមថាយើងរៀងសប្បាយហោសអ៊ុំ?

ខៈ យើងសប្បាយ។

កៈ យើងរៀងធូរធារហាស?

ខ៖ យើងរៀងធូរធារហោស?

ក៖ បាទអ៊ុំ!

ខ៖ មកជំនាន់ដូចថាសម្ដេចហ៊ុនសែនណុងគេមានបង្កើតជារោងចក្ររោងអីចឹងទៅ។

ក៖ ចឹងណោះអ៊ុំណោះ?

ខ៖ ចាំ!

ក៖ អូ៎!

ខ៖ ចាំ!

ក៖ នៅពេលណុងយើងចាប់ផ្ដើមអើ..?

ខ៖ ចាំ!

ក៖ ដូចថាអូ៎យើងធូរធារលែងមានសង្គ្រាមលែងមានអី?

ខ៖ រោងចក្រចឹងទៅប្ដីខ្ញុំនេះចៃផានៗនេះគាត់អោយប្ដីខ្ញុំបងពេជ្របាសបងពេជ្របងពេជ្រឯង
ទៅរកការងារធ្វើទៅថាចឹងហាស!

ក៖ បាទ!

ខ៖ ទៅរកការងារធ្វើទៅណែគ្មានលុយធ្វើសាហ៊ុយទេណាស់ខ្ញុំអោយខ្ចីបានយាយផានណុង
អោយខ្ចីទៅធ្វើការងារនេះនៅព្រែកលាបយើងនេះព្រែកលាបយើងហ្នឹង!

ក៖ ស្គាល់។

ខ៖ ចាំទៅគាត់មើលមើលឃើញអូ៎យចិនៗហាសដឹងតែអោយធ្វើទេតែឈប់អត់បានទេ។

ក៖ បាទអ៊ុំ!

ខ៖ អើរួចទៅរកការងារអត់បានធ្វើក៏ហួសទៅផ្ទះម្ដាយមីងយាយទូចហ្នឹងហាសម្ដាយជំទាវ
ឡៀកខេងហ្នឹងហាស!

ក៖ បាទអ៊ឺ!

ខ៖ ចាំទាក់ទងតាមហ្នឹងតាមហ្នឹងទៅបានជួបគាត់ហ្នឹងទៅគាត់ថាហែងសួរហែងមានកូនចៅប៉ុន្មាននាក់ចឹងហ្នឹងហាស!

ក៖ បាទអ៊ឺ!

ខ៖ អើមានកូនចៅប៉ុន្មាននាក់។

ក៖ អូ៎!

ខ៖ អើចឹងអោយកូនហែងមកអញ់មកអញ់ចិញ្ចឹមអញ់អីចឹង ចឹងទៅបានគាត់ជួយផ្តល់មករួចខ្ញុំគាត់ហៅប្តីខ្ញុំទៅនៅតាំងពីណុងមកណុងហាសហែងមកនៅហ្នឹងអញ់ទៅ។

ក៖ អូ៎!

ខ៖ អើហែងមកនៅចាំផ្ទះអោយពូខេងទៅ។

ក៖ បាទអ៊ឺ!

ខ៖ គេអោយហែងស៊ីអីៗចឹងហាសមើលការខុសត្រូវអីចឹងហាសគេជួយអីចឹងហាស។

ក៖ បាទអ៊ឺបាទ!

ខ៖ ស្រាប់តែគាត់ហៅតែមនុស្សល្អទេមនុស្សអត់ល្អដឹងមានមិនចេះធ្វើអីស៊ីផឹកពាលាអាវ៉ាសែពេញល្បែងអីគេអត់យកទេ រួចមនុស្សប្តីខ្ញុំល្អដឹងតែធ្វើដឹងតែរក។

ក៖ បាទអ៊ឺ!

ខ៖ អាពាពីសតាពាស់គេអត់ចេះហ្នឹងហើយដែរគេហៅគាត់យកទៅទាល់តែសព្វថ្ងៃហ្នឹងទៀតហាសគាត់អត់ទាន់មកណា។

ក៖ អូ៎!

ខ៖ អើយកទៅតាំងពីជំនាន់ណុងហាសជំនាន់អ៊ុំក្មួយឯងសួរខ្ញុំហ្នឹងហាស!

ក៖ បាទអ៊ុំបាទ!

ខ៖ អើ!

ក៖ អើ!

ខ៖ យកទៅហ្នឹងអើដឹងតែធ្វើដឹងតែរកគេយកទៅនៅជាមួយហ្នឹង!

ក៖ បាទអ៊ុំ!

ខ៖ នៅចាំផ្ទះអោយគេហ្នឹងចាំណុងគេអោយចាំតែគាត់គ្មានជួយអីទេ គ្មានអោយអីទេដឹងតែរកត្រីរកសាច់ហ្នឹងទៅអ៊ូទៅដំបូងគេអោយដែរអោយបានបួនខែមួយខែគេអោយម្ភៃប្រាំម៉ឺន។

ក៖ អ៊ូបាទអ៊ុំ!

ខ៖ ម្ភៃប្រាំម៉ឺនប្តីខ្ញុំក្មួយអើយគ្មានស៊ីអីទេគេអាចរៀងទិញទៅអង្ករស្លឹកគ្រៃទៅ ប៊ីចេងស្ករស៊ីប្រចាំខែទៅរួចទៅនៅសល់រួចទៅនៅសល់ហ្នឹងខ្ញុំជួយធ្វើមេហាសមាការណុងបញ្ជីដប់មួយម៉ឺន។

ក៖ បាទអ៊ុំ!

ខ៖ ខ្ញុំចេះលុយចេះឡើទុកឡើអីហ្នឹងទៅរួចទៅគេឃើញខ្ញុំចេះទុកចេះដាក់ចង់មានចង់បាន គេក៏ឈប់អោយខ្ញុំទៅជំទាវគេលែងអោយខ្ញុំទៅ។

ក៖ អ៊ូ!

ខ៖ ខ្ញុំទៅបានបួនខែហ្នឹង!

ក៖ បាទអ៊ុំ!

ខ៖ រួចខ្ញុំចេះតែរកស៊ីទៅខ្ញុំទុកខ្ញុំដាក់ចឹងទៅចេះទុកចេះដាក់ចឹងទៅ។

ក៖ អ៊ូបាទអ៊ុំ!

ខ៖ អើអាណាដែរលុយយើងត្រូវចំណាយអាលុយដែរយើងត្រូវទុកយើងរីសថាំគេញប្រវ័ញទុកដាក់ទៅ។

កៈ បាទអុំ!

ខៈ ចាំប្តីក៏មិនដឹងថាយើងចេះផង។

កៈ អុំ!

ខៈ រួចទៅគាត់ថាអញ់មើលឃើញគេរាយម៉ងដូចត្រូវដល់ហើយអញ់ចង់ទិញម៉ងដល់ហើយ ឯងហាសអញ់ចង់ទិញម៉ងបានលុយណាទិញម៉ងឯងរកចងការគេតិចមកខ្ញុំថាអើឯងមនុស្ស ឯងហោសមកពីស្រុកណាងដូចមិនស្ទូវស្រួលទេមើលទៅទាល់យើងមានទូកមានអីត្រឹមត្រូវ ហាស ហោសទៅដេកចាំម៉ងចាំអីហាសឯងតែខំហ្នឹងចោរលួចអស់ហើយអើស្រុកណាងវាច្រើន លួចហោស!

កៈ បាទអុំ!

ខៈ អើអ្នកទំនប់ថ្មីហោស!

កៈ អុំបាទអុំ!

ខៈ រួចគាត់ថាអើបើចង់ទេមិនបាច់ចងការគេទេខ្ញុំមានតែឯងចឹងហោស អើចឹងមោះខ្ញុំកាលណុ ងមានតែមាសៗអោយគាត់ពីរជីទៅទៅប្តីខ្ញុំអត់ទេលុយក៏មិនចេះកាន់បានមកអោយតែខ្ញុំទុក ហ្នឹង អើទិញស្អីៗគាត់ប្រើតែខ្ញុំហ្នឹង!

កៈ អុំ!

ខៈ ទិញទៅ។

កៈ បាទអុំបាទ!

ខៈ គាត់ដឹងតែនៅតែក្នុងភូមិហ្នឹងធ្វើអីរកអីក្នុងភូមិហ្នឹង គាត់ការងារគាត់កាប់ព្រៃកាប់អីសព្វ គ្រប់ហ្នឹងខ្ញុំហ្នឹងចេះទុកទៅគាត់រកឡើងផ្សារទិញនេះទិញនោះគាត់ប្រើខ្ញុំផ្តាំថាតាឯងអត់ចេះ ឡើងផ្សារអត់ចេះទិញអីប្រើតែខ្ញុំហាស ឯងហោសបើក្បាលឯងគេកាត់ថាផ្ញើរថាកាត់សក់អោ យគេឯងកាត់ផ្ញើរអោយគេកាត់អោយប៉ុនផ្ញើរទៅមិនកើតចាំតែពេលទៅកាត់សក់គាត់ជិះកង់ ទៅកាត់សក់រួចខ្ញុំខឹងហោស!

កៈ បាទ!

ខៈ អូ៎បើសិនតែកាត់កបានយកមកដាក់វិញបានតាណុងធ្វើរក្បាលអោយគេកាត់សក់ដៃរណុង ហោសកុំនិយាយអាក្រក់ម៉េសវីអើអាក្រក់ចឹងអាមនុស្សស្រីប្រើតែស្រីហោសទិញស្អីក៏ស្រីទិញ ម៉ងក៏ស្រីទិញសាច់ស្អីធ្វើឡបធ្វើត្រយឹនក៏មនុស្សស្រី រួចមនុស្សប្រុសអីអត់ចេះដើរទិញចឹងហោស!

កៈ បាទ!

ខៈ រួចប៉ុនគាត់ចេះឯងហាសទិញអារបស់ឯងលាមើលណាស់ធ្វើម៉េចក្រឡាកុំអោយឆាំងបន្លាក្រឡាអីគាត់ចេះនិយាយចឹងប្រាប់យើងគាត់ចេះអោយគាត់ដើរទៅទិញគាត់អត់ដៃរទៅទិញ គាត់ប្រើយើង។

កៈ អូ៎បាទអ៊ុំបាទ!

ខៈ រួចចឹងយកទៅយើងដឹងហាសយើងដឹងច្បាស់អញ់បើទិញមិនត្រូវតាហ្នឹងប្រើអញ់ទៀត ហើយចឹងធ្វើម៉េចម៉ាត្រូវម៉ង។

កៈ អូ៎!

ខៈ អើថាខ្ជិលហាសក្មួយឡើងចុះហាស!

កៈ បាទអ៊ុំបាទ!

ខៈ អើ!

កៈ អត់អីទេចឹងអ៊ុំខ្ញុំមានសំនួរពីរសំនួរទៀតអ៊ុំចឹងអើទាក់ទងពីកាលពីក្មេងអ៊ុំធ្លាប់មានគោលបំណងថាធំឡើងអ៊ុំចង់ធ្វើអីអត់អ៊ុំរីលក្ខណៈថាធ្វើពេទ្យ ធ្វើប៉ូលីស?

ខៈ ចង់តើក្មួយចង់។

កៈ កាលណុងអ៊ុំចង់ធ្វើអីគេ?

ខៈ ចង់ដាក់ពុកខ្ញុំហាសពុកខ្ញុំថាកូនហាសកូនប្រឹងរៀនហាសពុកខ្ញុំអោយតែកូនប្រឹងរៀនទេ កូនហាសមិនបានអីត្រឹមគ្រូបង្រៀនហាសកូនណាស់។

កៈ បាទអុំ!

ខៈ អើរួចវាធ្វើម៉េចបើស្រុកវាបាតុកម្មទៅគ្រូវារត់ខ្ចាត់ខ្ចាយអស់ទៅបានស្អីចង់ហាស!

កៈ ចង់ធ្វើគ្រូបង្រៀនហេសអុំ?

ខៈ ចង់ចាំបើសិនជាបើសិនជាស្រុកស្រួលបួលពុកខ្ញុំគាត់កូនគាត់ថាក្រក៏ដោយគាត់ថាក្រ
ដោយសារកូនក៏ក្រទៅរកបានអោយតែកូនរៀន។

កៈ អូ៎!

ខៈ គាត់ចង់អោយកូនមានការងារធ្វើហាសណាស់។

កៈ បាទអុំបាទ!

ខៈ ប៉ុនដល់តែទទួលស្រុកចឹងទៅបានអីចិត្តតើចិត្តចង់តើ!

កៈ អូ៎បាទអុំបាទ!

ខៈ អើបានត្រឹមមានតែចិត្តទេប៉ុន្តែទៅវាមិនរួចចឹងបានថាកុំប៉ងប្រាថ្នាទេវតាកំណត់ទេ។

កៈ បានអុំបាទ!

ខៈ ក្មួយ!

កៈ អើ!

ខៈ ដូចកូនខ្ញុំអាលែងគ្នាហ្នឹងចឹងហាសខ្ញុំហាសចង់អោយកូននៅរៀនៗកូននៅរៀនណាស់កូន
ឯងធ្វើពេទ្យហាសកូនណាស់ អើម្ដាយដើរតែលក់ដើរតែដូរយកមកដើម្បីដោះស្រាយជីវភាព
យើងអោយរួចមួយឆ្នាំៗណាស់ខ្ញុំដើរទាល់តែលក់ទាល់តែដូរទៅអើមកវិញកូនឈប់រៀនវាថា
ពិបាកស៊ីបាយហាសម៉ែអើយម៉ែនៅផ្ទះទៅ កូនគ្រាន់មកវិញបាយឆ្អិនបាយអីដល់ម៉ែដើរលក់
ដើរតែដូរចឹងខែលក់ហាសបងអើពិបាកបាយទឹកស៊ីពេកអាលែងខ្ញុំក៏នៅដាំបាយអោយប្អូនៗស៊ី
ទៅខ្ញុំឈប់ ខ្ញុំថាអត់ចេះតស៊ូទេកូនឯងឃើញដែរខាតអើអត់បានអីទេប៉ងប្រាថ្នាអោយអាបងធ្វើ
ពេទ្យហាស!

ក៖ បាទ!

ខ៖ អើអត់បានធ្វើទេ។

ក៖ អ៊ូ!

ខ៖ ចឹងបានខ្ញុំថាអើយហ្នឹងណោះមនុស្សប៉ងប្រាថ្នាទេវតាកំណត់អោយកូនអត់បានអីសោះ។

ក៖ បាទអ៊ឺបាទ!

ខ៖ ប៉ុនវាអត់ល្ងង់កូនខ្ញុំអត់ល្ងង់ទេអានៅជាមួយមេសព្វថ្ងៃកូនខ្ញុំចេះណាស់ ដាក់អីក៏យល់ចេះខាងអាម៉ាស៊ីនយើងអាម៉ាស៊ីនប្រើកាល្វតអីហ្នឹងចេះម៉ាញ៉េអីហ្នឹងដូចថាវាមិនលឺអីហ្នឹងវាចេះដោះមើលដោះអី នាឡិកាទិញអោយពាក់ហ្នឹងវាដោះមើលអាហ្នឹងម៉េចអីម៉េចបានវាដើរម៉េចបានវាអត់ដើរអាណុងចេះហាស!

ក៖ អ៊ូ!

ខ៖ ចេះសព្វថ្ងៃជំនាញវាហាស!

ក៖ បាទអ៊ឺបាទ!

ខ៖ ដុំឆក់អីហ្នឹងវាចេះមើលចេះអាងតែខូចតិចតួចវាធ្វើកើតរួចមនុស្សវាឆ្លាតក្មួយឯងដឹងទេ វាដូចថាវាប្រើម៉ាស៊ីនខូចប្រើម៉ាស៊ីនខូចដូចយើងយកទៅគេហាសអោយគេធ្វើអោយ អោយគេធ្វើអោយនិយាយថ្លៃគេអីចឹងៗទៅត្រូវយកប៉ុនណោះៗទៅណាស់ស្រាប់តែរួចទៅវាដោះដោះទៅដឹងវាជាងហើយណុង។

ក៖ បាទអ៊ឺ!

ខ៖ អ៊ូយកថ្លៃពេកទៅមិនបាច់ទេខ្ញុំលែងធ្វើវិញហើយ វាដោះតំរិះពីជាងស្រេចហើយធ្វើខ្លួនឯង!

ក៖ បាទអ៊ឺ!

ខ៖ អ៊ូអាណុង!

ក៖ ល្អហាសណោះ!

ខ៖ អើចេះក្មួយហាសកូនខ្ញុំខំតែព្រាត់ព្រាស់កូនខ្ញុំត្រូវមានហាស!

ក៖ បាទអ៊ុំ!

ខ៖ វាមានឡានដឹកអីវ៉ាវ៉ាដើរបាស់ដើរអីតើនោះបាស់វាទុកកេរ្តិ៍អោយស្នាដៃអោយប្អូនវាមួយនោះ។

ក៖ បាទអ៊ុំបាទ!

ខ៖ បាសវ៉ាវ៉ាចេះធ្វើផុងបាស់ផុងអីណុងណាត្រឹមត្រូវរបស់វាមានរូបថតមានរូបថតសដូចក្មួយឯងចឹងកូនខ្ញុំហ្នឹង!

ក៖ អ៊ូ!

ខ៖ អាទីមួយសដូចកូនចិនចឹង។

ក៖ បាទអ៊ុំ!

ខ៖ មកអាប្អូនៗខ្មៅៗហាស!

ក៖ បាទ!

ខ៖ ដូចកូនចិន។

ក៖ ចឹងអើខ្ញុំមានសំនួរចុងក្រោយមួយ..?

ខ៖ លំនាំដូចក្មួយឯងចឹងកូនខ្ញុំណុង។

ក៖ បាទអ៊ុំបាទចឹងខ្ញុំមានសំនួរចុងក្រោយមួយអ៊ុំ បើសិនចង់អោយអ៊ុំផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយអ៊ុំមានពាក្យពេចន៍អីផ្ដាំផ្ញើរទៅពួកគាត់អត់អ៊ុំ?

ខ៖ ខ្ញុំផ្ដាំផ្ញើររាល់តែថ្ងៃហ្នឹងហាសដាស់តឿនមីចៅៗរាល់ថ្ងៃហ្នឹងខ្ញុំផ្ដាំហាសចៅប្រឹងរៀនចៅណាស់ តំរិះវិជ្ជាហ្នឹងហើយដៃរចោរលួចមិនបានអើណាស់ចៅ។

ក៖ បាទអ៊ុំបាទ!

ខ៖ ចាំ!

ក៖ ត្រូវ!

ខ៖ ចោរវាអត់បានទេចៅត្រូវចេះត្រូវដឹងចៅដល់ធំពេញវ័យទៅចៅថ្នាក់អញ់ណានៅគ្រប់គ្រងចៅឯងរហូត។

ក៖ ត្រូវអ៊ុំត្រូវ!

ខ៖ អើយាយស្លាប់ទៅហើយរួចចៅឯងនេះត្រូវមានប្ដីមានស្អីបើចៅឯងចេះទុកចេះដាក់ចេះសន្សំចេះចង់មានចង់បានអាណុងហើយល្អគ្រួសារយើងចឹងៗប្រដៅដើរតែផ្លូវល្អចឹង។

ក៖ អ៊ូ!

ខ៖ រួចបើចៅឯងអត់ចេះអីដឹងអីដឹងចានមិនចានឆ្នាំងមិនឆ្នាំងបានប្ដីគាប់ប្រសើរមិនអីទេចៅប្ដីមិនគាប់គេជេរដៀលដល់ម៉ែដល់ជីដូនហាស!

ក៖ បាទអ៊ុំបាទត្រូវ!

ខ៖ ខ្ញុំនិយាយតែចឹងរាល់ថ្ងៃហ្នឹងសួរវាមើលនិយាយរោយមាត់ហាសក្មួយដូចនិយាយជាមួយក្មួយឯងចឹងហាស!

ក៖ អ៊ូ!

ខ៖ វាលតែកូនថាមិនដឹងស្អីទេម៉ែម៉ែអើយម៉ែកូនក៏ថាទៀតនាងឯងបានជីដូនល្អហាសណាស់ជីដូនហ្នឹងហាស ជីដូនចេះសព្វគ្រប់ដាំបាយធ្វើបាយធ្វើម្ហូបបោកខោអាវសព្វប្រដែលប្ដៅនាងឯង អើជីដូនសុខចិត្តអត់អញ់ហាសជីដូនអាភ័ព្វហាសវាថាចឹងជីដូនអញ់អាភ័ព្វហាសណាស់មិនដែរអីអញ់ស៊ីទេណាស់អញ់នៅជាមួយបងប្អូនមិនដឹងឈ្លោះគ្នាផងគាត់មកវ៉ៃមកជេរអញ់ម៉ែអញ់អីម៉ែអញ់ប៉ាអញ់ទៅស្រែទៅអីហ្នឹង មកយាយសុកហ្នឹងអាក្រក់ហាសមកជេរមកវ៉ៃអញ់អើអញ់ឈរមើលមុខគាត់មិនទាំងអោយអីអញ់ស៊ីផងរួចនាងឯងក៏ល្អអីល្អយ៉ាងហ្នឹង ប៉ុណ្ណឹងហើយអត់ចេះស្ដាប់ជីដូនប្រដៅផងហ្នឹងហាសមីម៉ាលីម៉ាផារីយាយម៉ែអញ់ល្អហាសនេះរាល់ថ្ងៃគាត់លះបង់អស់ដោយសារពួកនាងឯងនេះ មាត់គាត់អត់ហ៊ានពិសារផងអោយតែនាងឯងហ្នឹងហាសអើកូនខ្ញុំលាន់មាត់ម៉ែឯងល្អហ្នឹងចៅៗហាស ខ្ញុំថាអើចៅៗវាតបស្នងវាអាយុវាវែងបើ

ម៉ែមិនធ្វើអោយតំរាបអោយចឹងទេវាអត់ដឹងទេណាស់កូន កូនឯងកុំខឹងម៉ែធ្វើម៉េចទេចិត្តម៉ែចិត្តម៉ែល្អហ្នឹងកូនហ្នឹងចៅអើអោយចៅៗរៀនតាមគំរូជីដូនទៅវាមិនខុចទេ។

ក៖ បាទអ៊ុំបាទ!

ខ៖ ដូចខោអាវចឹងហាសខោអាវចឹងខ្ញុំអត់ទាន់បោកខោអាវទេ ខ្ញុំថាណោះខោអាវហាសកុំដាក់ឡេកឡាកណាស់មីតូចដាក់ដោយមីតូចបងឯងឃើញសំពាយហ្នឹងហាសអើមីធំដាក់ដោយមីធំស្រណុករើកកាយស្លៀកទៅរៀងៗខ្លួន។

ក៖ បាទល្អ!

ខ៖ អើកុំយកមកប្រឡូកប្រឡាកជាមួយគេណាស់អើ ហើយមីតូចណុងវារើមីតូចណុងវារពិសហោសមីធំវារើទៅរៀនទៅអីវាហ្នឹងសុទ្ធស្នាដៃជីដូនបោកអោយអត់មានស្អុយជាមួយឡូកឡាក់ទេ កញ្ចាស់កន្ទំមែនតែកញ្ចាស់កន្ទំស្អាត រួចបើចៅឯងរៀបបោះចោលតាពីសតាពាសអូយអាងតែខោអាវជជុះមួយមួយរយពីររយ ចុះយើងមានមួយរយពីររយក៏យើងគ្មានមួយរយពីររយយើងបានអីទៅទិញអីគេដែរចឹងចៅ។

ក៖ ត្រូវអ៊ុំត្រូវ!

ខ៖ ប្រដៅចឹងណាស់ក្មួយ។

ក៖ បាទអ៊ុំបាទប៉ុន្តែអ៊ុំធ្លាប់ទូន្មានព្រានប្រដៅគាត់ថាកុំអោយគាត់ដើរផ្លូវអត់ល្អក្នុងសង្គមដូចជក់គ្រឿងញៀនជក់អីអ៊ុំធ្លាប់ទូន្មានព្រានប្រដៅរាល់ថ្ងៃតើអ៊ុំណោះ?

ខ៖ ប្រាប់ប្រាប់ទាំងអស់។

ក៖ អូ៎!

ខ៖ ប្រាប់រួចប៉ុនកបដោយបុណ្យដោយធិមកូនខ្ញុំអត់មានទេ។

ក៖ បាទអ៊ុំ!

ខ៖ ស៊ិចស៊ីខើចលើខើចក្រោមក៏អត់មានដែរ។

ក៖ អូ៎!

ខ៖ ម៉ែវាណុងហាស!

ក៖ បាទ!

ខ៖ សង្គមគេចឹងហើយហ្នឹងហាសអើវាធ្វើរោងចក្រហោសវាស្រាប់តែអាវរូបក្រពើកូនខ្ញុំគ្រប់ពិណាកូនខ្ញុំអើពាក់លេចៗគួចវាហោស អត់ធ្លាប់ទេអត់ទេស៊ិចស៊ីលេចលើលេចក្រោមហោស មើលទៅខ្ញុំថាកូនឯងលាបម្ស៉ៅតិចៗទៅ អញ់ឃើញគេស្អាតៗហាសណាស់វាថាអាណាមិនស្រឡាញ់ទេហីទៅខ្ញុំមិនចេះទេម៉ែអើអាហ្នឹងម៉ែមីហ្នឹងហាសណាស់ អើខ្ញុំអត់ចេះទេម៉ែពិបាកលុបមុខហាសខ្ញុំធុញហាសអើ!

ក៖ បាទអ៊ុំបាទ!

ខ៖ អត់ចេះទេម៉ែវាហ្នឹងអត់ចេះទេ។

ក៖ បាទអ៊ុំ!

ខ៖ ដល់ពេលមានប្តីឥឡូវចេះ។

ក៖ ចេះហើយណេះអ៊ុំ?

ខ៖ ស្អាតខ្ញុំឃើញកូនស្អាតខ្ញុំល្អហាសខ្ញុំអរហាស អើស្មីចេះធ្វើខ្លួនហើយធ្វើខ្លះទៅម៉ែនៅពីក្រមុំអាត្រូវគ្រាប់ណាមិនស្រឡាញ់ទៅអោយតែមានតែលុយ។

ក៖ បាទអ៊ុំបាទ!

ខ៖ ដល់មានប្តីទៅចេះធ្វើខ្លួន។

ក៖ បាទអ៊ុំចឹងអ៊ុំមានពាក្យពេចន៍អីចង់ផ្តាំផ្ញើរទៅពួកគាត់ផ្សេងពីហ្នឹងទៀតអត់អ៊ុំ?

ខ៖ ពាក្យពេចន៍អី?

ក៖ អ៊ុំមានកូនចៅហាសអ៊ុំមានទូន្មានអីទៅកូនចៅផ្សេងពីហ្នឹងទៀតអត់?

ខ៖ ទូន្មានហ្នឹងហាសទូន្មានកូនទាំងអស់ទាំងហ្នឹងខ្ញុំរាល់ថ្ងៃទូន្មានថាកូនប្រឹងធ្វើប្រឹងរកដើម្បីអោយមាន។

កៈ បាទអ៊ុំបាទ!

ខៈ សង្គមហ្នឹងគេរកតែអ្នកមានគេរកតែអ្នកចេះអ្នកដឹងទេ។

កៈ បាទអ៊ុំបាទ!

ខៈ អើសុំកូនឆ្លៀតពេលវេលាឪកាសណាស់រកស៊ីទាន់មានឪកាសរក។

កៈ បាទអ៊ុំបាទ!

ខៈ តែឪកាសគ្មានរកមិនបានហើយកូនប្រឹងទៅត្រង់ណារួច។

កៈ ត្រូវអ៊ុំត្រូវ!

ខៈ ចាំចឹងជូនកូនទាន់ឪកាសគេរកបានរកទៅអត់ខុសទេ។

កៈ បាទអ៊ុំបាទ!

ខៈ ប្រាប់ហើយបើឪកាសរកមិនបានហើយប្រឹងធ្វើម៉េចបើវាផុតឪកាសហើយចឹងជូនពរដូចមីស្មីក៏ដោយ សុខខេងខ្ញុំក៏ដោយឪអាប៉ូក៏ដោយសូមកូនឪកាសរកបានចេះទុកចេះដាក់អោយមានអោយបានទៅ។

កៈ បាទអ៊ុំបាទ!

ខៈ ចាំម្តាយមានតែប៉ុណ្ណឹងម្តាយអត់មានចង់បានអីពីកូនទេ។

កៈ បាទអ៊ុំបាទ!

ខៈ អើ!

កៈ ចឹង..?

ខៈ មានតែកូនមានសធារអោយម៉ែក៏ម៉ែមានសាធុជួយជូនពរកូនអោយកូនបានសេចក្តីសុខសេចក្តីចំរើន។

កៈ បាទអ៊ុំបាទចឹង..?

ខ៖ ចាំ!

ក៖ មានតែប៉ុណ្ណឹងទេណេះអ៊ុំណេះ?

ខ៖ មានតែប៉ុណ្ណឹងទេកូន។

ក៖ អូ៎បាទចឹងអើចុងក្រោយប្រហែលជាខ្ញុំសុំការអនុញ្ញាតិពីអ៊ុំដើម្បីដាក់ការសម្ភាសដែរអ៊ុំបានពិភាក្សាជាមួយខ្ញុំមួយហ្នឹង..?

ខ៖ ចាំ!

ក៖ ដាក់ទៅក្នុងវេបសាយសាលាដើម្បីតំកល់ទុកអោយកូនៗចៅៗរបស់អ៊ុំបានទេអ៊ុំ អើខ្ញុំហ្នឹងដាក់ការសម្ភាសរបស់អ៊ុំមួយហ្នឹងដែរអ៊ុំជជែកជាមួយខ្ញុំហ្នឹង..?

ខ៖ ចាំ!

ក៖ ទៅក្នុងវេបសាយសាលាដើម្បីតំកល់ទុកអោយកូនចៅបាស?

ខ៖ ចាំ!

ក៖ បានតើណេះអ៊ុំណេះ?

ខ៖ ចាំបានហើក្មួយ?

ក៖ អូ៎បាទអ៊ុំបាទ!

ខ៖ ចាំរួចបើខ្ញុំចង់អោយកូនខ្ញុំលឺពាក្យហ្នឹងហាសធ្វើទៅម៉េចទៅកូនខ្ញុំនៅបារាំងអីធ្វើម៉េច..។

ក៖ អូ៎!

ខ៖ អោយបានទាក់ទងតាមក្មួយអាចបាន?

ក៖ ចាំខ្ញុំទាក់ទងទៅគាត់ហើយចាំខ្ញុំប្រាប់គាត់អោយចឹងហាស?

ខ៖ ទាក់ទងម៉េចបើក្មួយអត់ស្គាល់លេខគេចឹងធ្វើម៉េចក្មួយហាស!

ក៖ អើអាហ្នឹងហើយតិចទៀតខ្ញុំហ្នឹងប្រាប់អ៊ុំតាមក្រោយហ្នឹងចឹងហាសណាស់អ៊ុំ?

ខ៖ ចាំ!

ក៖ ចឹងអរគុណច្រើនអ៊ុំ?

ខ៖ ចាំ។